សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ

និង វិទ្យាសាស្ត្រសេដ្ឋកិច្ច


**សារណាបញ្ចប់ការសិក្សា**

# សមាហរណកម្មសេដ្ឋកិច្ច និងកំណែទម្រង់គោលនយោបាយម៉ាក្រូសេដ្ឋកិច្ចប្រទេសកំពុងអភិវឌ្ឍន៍

(ករណីសិក្សា៖ ប្រទេសកម្ពុជា)

ស្រាវជ្រាវពីថ្ងៃទី ០២ ខែមេសា ឆ្នាំ ២០១៨ ដល់ថ្ងៃទី ៣១ ខែឧសភា ឆ្នាំ ២០១៨


តាក់តែងឡើងដោយ

និស្សិតឈ្មោះ **ហ្វៃ មេសា**

សាស្ត្រាចារ្យណែនាំ

លោកស្រី **ឡុង ម៉ាមីឌី**



ថ្នាក់បរិញ្ញាបត្រ សេដ្ឋកិច្ចអភិវឌ្ឍន៍

ជំនាន់ទី ២

ឆ្នាំចូលសិក្សា ២០១៤

ឆ្នាំសរសេរសារណា ២០១៨

# សេចក្តីថ្លែងអំណរគុណ

ក្នុងនាមខ្ញុំជានិស្សិតនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ជំនាន់ទី ១៧ ក្រុម $E_4DC_2$ បរិញ្ញាបត្រសេដ្ឋកិច្ចអភិវឌ្ឍន៍បានធ្វើការសិក្សាស្រាវជ្រាវសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាប័ត្រ ក្រោមប្រធានបទ «**សមាហរណកម្មសេដ្ឋកិច្ច និងកំណែទម្រង់គោលនយោបាយម៉ាក្រូសេដ្ឋកិច្ចប្រទេសកំពុងអភិវឌ្ឍន៍ (ករណីសិក្សាប្រទេសកម្ពុជា)**» បានបញ្ចប់ជាស្ថាពរ។

ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមចូលរួមសម្តែងនូវការដឹងគុណយ៉ាងជ្រាលជ្រៅបំផុតដែលមិនអាចកាត់ថ្លៃបាន ចំពោះអ្នកមានគុណរបស់ខ្ញុំទាំងទ្វេ។ ការស្គាល់ខុស ស្គាល់ត្រូវ និងការអប់រំដែលខ្ញុំទទួលបានមកដល់ថ្ងៃនេះ គឺមានការទំនុកបំរុង និងការខិតខំប្រឹងប្រែងរបស់លោកទាំងពីរ។

យ៉ាងណាមិញ ខ្ញុំក៏មិនភ្លេចនូវការដឹងគុណយ៉ាងធំធេងដល់លោកគ្រូ អ្នកគ្រូ និងសាស្ត្រាចារ្យដែលបានអប់រំ ទូន្មាន ប្រៀនប្រដៅ និងបង្ហាត់បង្ហាញខ្ញុំ ចាប់តាំងពីពេលដែលខ្ញុំចាប់ផ្តើមសិក្សាតាំងពីថ្នាក់មតេយ្យរហូតមកដល់បញ្ចប់ថ្នាក់បរិញ្ញាប័ត្រនេះ។

ជាពិសេសជាងនេះទៅទៀតនោះ ខ្ញុំសូមថ្លែងអំណរគុណដល់លោកស្រីសាស្ត្រាចារ្យ **ឡុង ម៉ាមីឌី** ដែលបានបង្រៀនមុខវិជ្ជា ម៉ាក្រូសេដ្ឋកិច្ច I ម៉ាក្រូសេដ្ឋកិច្ច II និងមុខវិជ្ជា សេដ្ឋកិច្ចអន្តរជាតិដល់រូបខ្ញុំបាទនៅឆ្នាំទី ២ និងទី ៣។ ហើយលោកស្រីសាស្ត្រាចារ្យក៏បានជួយជ្រោមជ្រែងខ្ញុំពេញទំហឹងអស់ពីកម្លាំងកាយចិត្ត ផ្តល់ជាអនុសាសន៍ល្អៗ និងធ្វើជាបង្គោលដឹកនាំខ្ញុំធ្វើការស្រាវជ្រាវសារណាបញ្ចាប់ថ្នាក់បរិញ្ញាប័ត្រនេះរហូតដល់ទីបញ្ចប់។

ជាទីបញ្ចប់ ខ្ញុំសូមប្រសិទ្ធិពរជ័យទាំង ៤ប្រការ គឺ អាយុ វណ្ណៈ សុខៈ និងពលៈ រួមទាំងសិរីសួស្តីជ័យមង្គល វិបុលសុខ និងសេចក្តីចម្រើន ចូរកើតមានដល់លោកអ្នកមានគុណទាំងទ្វេ និងអ្នកទាំងឡាយដែលបានជួយជ្រោមជ្រែង ក្នុងការស្រាវជ្រាវនេះគ្រប់ៗគ្នា កុំបីអាក់ខានឡើយ។

# អារម្ភកថា

**«សមាហរណកម្មសេដ្ឋកិច្ច»** បានក្លាយជានយោបាយសេដ្ឋកិច្ចដ៏ចម្បងនៅទូទាំងពិភពលោក។ ប្រទេសជាច្រើន មិនថាប្រទេសអភិវឌ្ឍន៍ ឬកំពុងអភិវឌ្ឍន៍ បាននាំគ្នាចូលរួម និងបង្កើតជាសមាហរណកម្មនេះឡើយ ជាលក្ខណៈសាកល ឬតំបន់ទៅតាមការចង់បានរបស់ពួកគេ។ យ៉ាងណាមិញគោលនយោបាយមួយនេះ បាននាំមកនូវគុណសម្បត្តិ និងគុណវិបត្តិស្របពេលជាមួយគ្នា ទៅលើគ្រប់ផ្នែកទាំងអស់មិនថា នយោបាយ សេដ្ឋកិច្ច និងសង្គមនោះទេ។

ដោយឡែក ក្នុងចំណោមប្រទេសកំពុងអភិវឌ្ឍន៍ជាច្រើន ប្រទេសកម្ពុជាក៏ជាប្រទេសមួយដែលគាំទ្រដល់សមាហរណកម្មសេដ្ឋកិច្ចនេះផងដែរ។ ជាលទ្ធផល នយោបាយសេដ្ឋកិច្ចនេះហើយ បានធ្វើឲ្យប្រទេសដែលជាសមាជិកអាស៊ានមួយនេះ បានប្រែមុខប្រែមាត់ ក៏ដូចជាកែប្រែគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចរបស់ខ្លួន។ ក្នុងនោះ កំណែទម្រង់គោលនយោបាយសារពើពន្ធកម្ពុជា បានធ្វើឲ្យមានការប្រែប្រួលដល់ការចំណាយ និងចំណូលប្រទេស ឬនិយាយជារួម សេដ្ឋកិច្ចជាតិតែម្តង។

ដោយសង្ឃឹមយ៉ាងមុតមាំ កិច្ចការស្រាវជ្រាវនេះ នឹងអាចចូលរួមជាបច្ច័យក្នុងការអភិវឌ្ឍន៍ប្រទេស ក៏ដូចជាការរៀបចំគោលនយោបាយ របស់រដ្ឋាភិបាល អ្នកស្រាវជ្រាវ ក៏ដូចជាផ្តល់ជាចំណេះដឹងបន្ថែមទៅលើការសិក្សាជំនាញសេដ្ឋកិច្ចអភិវឌ្ឍន៍នេះផងដែរ។

# មាតិកា

**ទំព័រ**

បញ្ជីពាក្យកាត់ v
បញ្ជីតារាង vi
បញ្ជីក្រាហ្វិក vii
បញ្ជីឧបសម្ព័ន្ធ viii

## សេចក្តីផ្តើម

១. លំនាំ និងចំណូលបញ្ហា ១
២. ចំណោទបញ្ហា ១
៣. គោលបំណងនៃការស្រាវជ្រាវ ២
៤. សារៈសំខាន់នៃការស្រាវជ្រាវ ២
៥. ទំហំ និងដែនកំណត់ ៣
៦. វិធីសាស្ត្រនៃការស្រាវជ្រាវ ៣
៧. រចនាសម្ព័ន្ធនៃស្រាវជ្រាវ ៤

## ជំពូកទី១

## ទ្រឹស្តីពាក់ព័ន្ធ

១. ទ្រឹស្តីសមាហរណកម្មសេដ្ឋកិច្ច ៥
១.១. អ្វីទៅជាសមាហរណកម្ម ៥
១.២. ប្រភេទនៃសមាហរណកម្មសេដ្ឋកិច្ច ៧
១.២.១. តំបន់ពាណិជ្ជកម្មសេរី ៧
១.២.២. សហភាពពន្ធគយរួម ៧
១.២.៣. ទីផ្សាររួម ៧
១.២.៤. សហភាពសេដ្ឋកិច្ច ៨
១.២.៥. សមាហរណកម្មសេដ្ឋកិច្ចទាំងស្រុង ៨
១.៣. ការអនុវត្តនៃសមាហរណកម្មសេដ្ឋកិច្ចក្នុងពិភពលោក ៨
១.៣.១. កិច្ចព្រមព្រៀងទូទៅលើពន្ធនាំចូល និងពាណិជ្ជកម្ម ៩
១.៣.២. សហភាពអឺរ៉ុប ១០

១.៣.៣. សហគមន៍ប្រជាជាតិអាស៊ីអាគ្នេយ៍ ........ ១២
១.៣.៤. អង្គការពាណិជ្ជកម្មពិភពលោក ........ ១៦
២. ម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច ........ ១៨
២.១. ម៉ាក្រូសេដ្ឋកិច្ច ........ ១៨
២.១.១. ប្រវត្តិនៃប្រព័ន្ធម៉ាក្រូសេដ្ឋកិច្ចទំនើប ........ ១៩
២.១.២. បញ្ហាដែលត្រូវដោះស្រាយក្នុងម៉ាក្រូសេដ្ឋកិច្ច ........ ២១
២.១.៣. សារៈសំខាន់នៃម៉ាក្រូសេដ្ឋកិច្ច ........ ២២
២.២. គោលនយោបាយម៉ាក្រូសេដ្ឋកិច្ច ........ ២៣
២.២.១. គោលនយោបាយហិរញ្ញវត្ថុ ........ ២៤
២.២.២. គោលនយោបាយសារពើពន្ធ ........ ២៤
២.៣. ផលិតផលក្នុងស្រុកសរុបដុល(ផសស) ........ ២៦
២.៣.១. ភាពទូទៅនៃផសស ........ ២៧
២.៣.២. ធាតុផ្សំនៅក្នុងផសស ........ ២៧
៣. ប្រទេសកំពុងអភិវឌ្ឍន៍ ........ ២៨

## ជំពូកទី២

## ប្រទេសកំពុងអភិវឌ្ឍន៍ និងសមាហរណកម្ម

១. លក្ខខណ្ឌដូចគ្នានៃសេដ្ឋកិច្ចប្រទេសកំពុងអភិវឌ្ឍន៍ ........ ២៩
១.១. កម្រិត GDP ក្នុងម្នាក់ទាប និងអត្រានៃភាពក្រីក្រខ្ពស់ ........ ២៩
១.២. ភាពអាស្រ័យលើវិស័យកសិកម្ម និងការប្រើប្រាស់ធនធានធម្មជាតិច្រើនលើសលប់ ........ ២៩
១.៣. ផលិតភាពតូច និងឧស្សាហកម្មដែលផ្តោតលើកម្លាំងពលកម្ម ........ ៣០
១.៤. អត្រាកំណើតខ្ពស់ ឬប្រជាជនច្រើន ........ ៣០
១.៥. ភាពបត់បែននៃថ្លៃ ........ ៣២
១.៦. វិសមភាពនៃការអភិវឌ្ឍន៍ ........ ៣២
២. ប្រទេសកំពុងអភិវឌ្ឍន៍ចូលសមាហរណកម្ម ........ ៣៣
២.១. កត្តាជម្រុញឲ្យប្រទេសកំពុងអភិវឌ្ឍន៍ចូលសមាហរណកម្មសេដ្ឋកិច្ច ........ ៣៣
២.១.១. ការធ្វើពាណិជ្ជកម្ម ........ ៣៣
២.១.២. ការអភិវឌ្ឍន៍ ........ ៣៥

២.១.៣. នយោបាយ និងសន្តិសុខ ..... ៣៥
២.២. ផលប្រយោជន៍របស់ប្រទេសកំពុងអភិវឌ្ឍន៍ចូលសមាហរណកម្មសេដ្ឋកិច្ច ..... ៣៦
២.២.១. ការបង្កើតពាណិជ្ជកម្ម ..... ៣៦
២.២.២. បង្កើនវិនិយោគទុន ..... ៣៧
២.២.៣. ការកើនឡើងនៃជំនាញ ..... ៣៨
២.២.៤. ការកើនឡើងនៃទម្ងន់នៃការចរចារ ..... ៣៩
២.៣. ផលអវិជ្ជមានរបស់ប្រទេសកំពុងអភិវឌ្ឍន៍ចូលសមាហរណកម្មសេដ្ឋកិច្ច ..... ៤០
២.៣.១ ការបង្វែរពាណិជ្ជកម្ម ..... ៤១
២.៣.២. ការបាត់បង់ចំណូលពន្ធ ..... ៤១
២.៣.៣. កំណែទម្រង់ស្ថាប័ន ..... ៤២
៣. សមាហរណកម្មសេដ្ឋកិច្ចរបស់ប្រទេសកំពុងអភិវឌ្ឍន៍ទៅក្នុងអង្គការសេដ្ឋកិច្ច និងប្លុកសេដ្ឋកិច្ចធំៗ ..... ៤៣

## **ជំពូកទី៣**

## **កំណែទម្រង់គោលនយោបាយសារពើពន្ធ - ករណីសិក្សាប្រទេសកម្ពុជា**

១. សមាហរណកម្មសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា ..... ៤៥
២. លក្ខខណ្ឌទូទៅនៃប្រព័ន្ធម៉ាក្រូសេដ្ឋកិច្ចប្រទេសកម្ពុជា ឆ្នាំ ២០០៨ ដល់ ២០១៧ ..... ៤៦
២.១. ដំណាក់កាលនៃការវិវត្តន៍នៃសេដ្ឋកិច្ច ..... ៤៨
២.២. ការប្រែបម្រួលរចនាសម្ព័ន្ធសេដ្ឋកិច្ច ..... ៤៨
៣. ប្រព័ន្ធសារពើពន្ធកម្ពុជា ..... ៤៩
៣.១. ពន្ធគយ ..... ៥០
៣.២. ពន្ធដារ ..... ៥១
៣.៣. ការរៀបចំកញ្ចប់ថវិកាជាតិ ..... ៥២
៤. ការធ្វើកំណែទម្រង់គោលនយោបាយសារពើពន្ធ ..... ៥៣
៤.១. វិសោធនកម្មលើច្បាប់ស្តីពីសារពើពន្ធ ..... ៥៣
៤.២. ការទម្លាក់អត្រាពន្ធនាំចូល ..... ៥៤
៤.៣. ទំនាក់ទំនងយ៉ាងស្អិតរមួតជាមួយនឹងកម្មវិធីជាតិនានា ..... ៥៥
៤.៤. ការវិវត្តន៍នៃប្រព័ន្ធថវិកាជាតិ ..... ៥៦
៤.៥. ការវិវត្តន៍នៃថវិកាជាតិ ..... ៥៧

៥. លទ្ធផលនៃកំណែទម្រង់ ........ ៥៨
៥.១. ឱនភាព ឬឧត្តមភាព ........ ៥៨
៥.២. ចីរភាពថវិកាជាតិ និងកម្ចីបរទេស ........ ៥៩
៦. បញ្ហាប្រឈម និងហានិភ័យនៃសេដ្ឋកិច្ចកម្ពុជា ........ ៦២

## ជំពូកទី៤

## ពិភាក្សា

១. ការពិភាក្សាទៅលើចំណាយ C ........ ៦៣
២. ការពិភាក្សាទៅលើចំណាយ G ........ ៦៣
៣. ការពិភាក្សាទៅលើចំណាយ I ........ ៦៣
៤. ការពិភាក្សាទៅលើចំណាយ (X-M) ........ ៦៤
៥. ការសន្ទត់ជារូម ........ ៦៥

## សេចក្តីសន្និដ្ឋាន និងអនុសាសន៍

១. សេចក្តីសន្និដ្ឋាន ........ ៦៦
២. អនុសាសន៍ ........ ៦៧

**ឯកសារយោង**

**ឧបសម្ព័ន្ធ**

# បញ្ជីពាក្យកាត់

**ផសស៖** ផលិតផលក្នុងស្រុកសរុបដុល

**អាស៊ាន៖** សមាគមន៍ប្រជាជាតិអាស៊ីអាគ្នេយ៍

**អគរ៖** អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា

**AANZFTA៖** តំបន់ពាណិជ្ជកម្មសេរីអាស៊ាន–អូស្ត្រាលី–ណូវែលហ្សេឡង់

**ACFTA៖** កិច្ចសហប្រត្តិបត្តិការ សេដ្ឋកិច្ចទូលំទូលាយរវាងអាស៊ាន និងសាធារណរដ្ឋប្រជាមានិតចិន

**AIFTA៖** តំបន់ពាណិជ្ជកម្មសេរីរវាង ប្រទេសសមាជិកអាស៊ាន និងប្រទេសឥណ្ឌា

**AJCEP៖** ភាពជាដៃគូសេដ្ឋកិច្ចទូលំទូលាយរវាង ប្រទេសជាសមាជិកអាស៊ាននិងប្រទេសជប៉ុន

**AKFTA៖** កិច្ចសហប្រត្តិការសេដ្ឋកិច្ចទូលំទូលាយ រវាងអាស៊ាន និងសាធារណរដ្ឋកូរ៉េ

**ATICH៖** ពាណិជ្ជកម្មទំនិញអាស៊ាន

**FDI៖** Foreign Direct Investment

**GATT**៖ General Agreement on Tariffs and Trade

**GDP**៖ Gross Domestic Product

**RCEP៖** ភាពជាដៃគូសេដ្ឋកិច្ចគ្រប់ ទូលំទូលាយតំបន់

**WTO**៖ World Trade Organization

# បញ្ជីតារាង

ទំព័រ

តារាងទី ១៖ កម្រិតពន្ធនាំចូលជាមធ្យមរបស់ប្រទេសអភិវឌ្ឍន៍មួយចំនួននៅក្នុង
ពិភពលោក បើធៀបនឹងឆ្នាំ ២០០៧ (គិតជា%)........១០
តារាងទី ២៖ ទិន្នន័យសូចនាករសេដ្ឋកិច្ចមួយចំនួនរបស់សហភាពអឺរ៉ុប........១២
តារាងទី ៣៖ ការបែងចែកកម្លាំងពលកម្មតាមវិស័យ........៣០
តារាងទី ៤៖ ការកើនឡើងនៃប្រជាជន(គិតពីឆ្នាំ ១៩៩០ ដល់២០០៩)........៣១
តារាងទី ៥៖ ទំហំពាណិជ្ជកម្មទំនិញ និង GDP ពិត ចាប់ពីឆ្នាំ ២០១៤ ដល់២០១៩
(គិតជា%)........៣៤
តារាងទី ៦៖ ទំហំ និងអត្រាវិនិយោគទុនក្រៅប្រទេសដែលចូលមកក្នុងប្រទេស
ពីឆ្នាំ ២០១៤ ដល់២០១៦ (គិតជា ពាន់លានដុល្លាអាមេរិក និង %)........៣៨
តារាងទី ៧៖ សមាជិកភាពថ្មីរបស់ GATT និង WTO ចាប់ពីឆ្នាំ ១៩៨៥ ដល់ ២០១០........៤៤
តារាងទី ៨៖ សូចនាករសេដ្ឋកិច្ចប្រទេសកម្ពុជា ឆ្នាំ២០១៨........៤៧
តារាងទី ៩៖ អត្រាពន្ធគយនៅកម្ពុជា (គិតជា%នៃតម្លៃទំនិញ)........៥០
តារាងទី ១០៖ អត្រាពន្ធនាំចូលតាមប្រភេទមុខទំនិញសំខាន់ៗមួយចំនួន........៥១
តារាងទី ១១៖ ចំណូលពន្ធប្រមូលដោយអគ្គនាយកដ្ឋានពន្ធដារ (គិតជាពាន់លានរៀល)........៥៤
តារាងទី ១២៖ សង្ខេបចំណូល និងចំណាយជាតិតាមច្បាប់........៥៨
តារាងទី ១៣៖ ការប៉ាន់ស្មានទំហំពាណិជ្ជកម្ម និងការវិនិយោគ........៦៤
តារាងទី ១៤៖ ស្ថិតិនៃការនៃចេញ និងនាំចូល (គិតជា លានដុល្លាអាមេរិក)........៦៥

# បញ្ជីក្រាហ្វិក

**ទំព័រ**


ក្រាហ្វិកទី ១៖ អត្រាកំណើន GDP របស់សហភាពអឺរ៉ុប(គិតជា%)........................................................១២
ក្រាហ្វិកទី ២៖ រង្វាយតម្លៃអត្រាកំណើន GDP អាស៊ានធៀបនឹង GDP
សរុបពិភពលោក(គិតជា%)........................................................................................................១៥
ក្រាហ្វិកទី ៣៖ រង្វាយតម្លៃកំណើន GDP ពិតរបស់ក្រុមប្រទេស កម្ពុជា ឡាវ មីយ៉ាន់ម៉ា
វៀតណាម (គិតជា%).................................................................................................................១៥
ក្រាហ្វិកទី ៤៖ ទំហំពាណិជ្ជកម្មរបស់ប្រទេសនៅតាមតំបន់នានាក្នុងពិភពលោក
(គិតជាពាន់លានដុល្លាអាមេរិក)..................................................................................................១៧
ក្រាហ្វិកទី ៥៖ គំនូសបំព្រួញនៃការកើនឡើងនូវទម្ងន់នៃការចរចារ.................................................៤០
ក្រាហ្វិកទី ៦៖ ការចូលរួមនៃវិស័យផ្សេងៗក្នុងការកើនឡើងនៃ GDP ប្រទេសកម្ពុជា
(គិតពីឆ្នាំ ២០១០ ដល់២០១៦)..................................................................................................៤៩
ក្រាហ្វិកទី ៧៖ ឱនភាពសារពើពន្ធកម្ពុជា ឆ្នាំ២០០៨ ដល់ ២០១៦ (គិតជា%នៃ GDP)..................៥៩
ក្រាហ្វិកទី ៨៖ ស្ថិតិចំនួនទឹកប្រាក់បំណុលបរទេសរបស់កម្ពុជា
(គិតជាលានដុល្លាអាមេរិក)........................................................................................................៦១
ក្រាហ្វិកទី ៩៖ ស្ថិតិបំណុលសាធារណៈកម្ពុជាធៀបនឹងផសស(គិតជា %)...................................៦១

# បញ្ជីឧបសម្ព័ន្ធ

ឧបសម្ព័ន្ធទី ១៖ សូចនាករម៉ាក្រូ និងហេដ្ឋារចនាសម្ព័ន្ធរបស់ប្រទេសដែលមានចំណូលទាប
ឧបសម្ព័ន្ធទី ២៖ ចំណែកនៃការងារក្រៅផ្លូវការក្នុងសេដ្ឋកិច្ច(គិតជា % ធៀបនឹង GDP)
ឧបសម្ព័ន្ធទី ៣៖ តុល្យការ និងលំហូរវិនិយោទុន
ឧបសម្ព័ន្ធទី ៤៖ ការធ្លាក់ចុះនៃការនាំចេញផលិតផលវាយនភណ្ឌ
ឧបសម្ព័ន្ធទី ៥៖ ការវិវត្តន៍នៃប្រព័ន្ធថវិកា

# សេចក្តីផ្តើម

## ១. លំនាំ និងចំណោទបញ្ហា

សមាហរណកម្មសេដ្ឋកិច្ចបានក្លាយទៅជានយោបាយសេដ្ឋកិច្ចដ៏ចម្បងនៅក្នុងពិភពលោក នៅក្នុងរយៈពេល ៦០ ឆ្នាំចុងក្រោយនេះ។ ក្នុងនោះ នៅក្នុងទសវត្សទី៥០ ប្រទេសមួយចំនួននៅ ក្នុងទ្វីបអឺរ៉ុបបានផ្តួចផ្តើមគំនិតបង្កើតសមាហរណកម្ម តាមរយៈការបង្កើតក្រុមហ៊ុនសហគមន៍ថាមពលធ្យូងថ្ម និងដែក (The European Coal and Steel Community)។ ពីមួយឆ្នាំ ទៅមួយឆ្នាំ សហគមន៍នេះបានរីកចម្រើន ហើយបានប្រែអភិវឌ្ឍខ្លួនបន្តិចម្តងៗ ក្លាយទៅជាសហភាពអឺរ៉ុប នៅឆ្នាំ ២០០៣។ ស្រដៀងគ្នានេះដែរ ដែរសមាគមន៍ប្រជាជាតិអាស៊ីអាគ្នេយ៍ ឬអាស៊ាន ក៏បានអភិវឌ្ឍខ្លួនចាប់តាំងពីឆ្នាំ ១៩៦៧ ដែលមានតែ ៥ប្រទេស រហូតមកដល់ ១០ប្រទេសដូចពេលបច្ចុប្បន្ន។

បច្ចុប្បន្ន មិនថាប្រទេសកំពុងអភិវឌ្ឍន៍ ឬ ប្រទេសអភិវឌ្ឍន៍នោះទេ ពួកគេបាន និងកំពុងសម្រេចឲ្យបានការចូលជាសមាជិកនៃសមាហរណកម្មធំៗដែលមានប្រយោជន៍ បើទោះបីជាពួកគេដឹងថាសមាហរណកម្មនេះ នឹងជះឥទ្ធិពលទាំងវិជ្ជមាន និងអវិជ្ជមានទៅលើ នយោបាយ សេដ្ឋកិច្ច និងសង្គមរបស់ពួកគេក៏ដោយ។ ក្នុងផ្នែកសេដ្ឋកិច្ច ចំពោះប្រទេសកំពុងអភិវឌ្ឍន៍ ការទទួលបានសមាជិកភាពនេះនឹងទាមទារឲ្យពួកគេធ្វើកំណែទម្រង់គោលនយោបាយក្នុងស្រុកជាច្រើន ជាពិសេសគឺគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចរបស់ប្រទេសពួកគេតែម្តង។

ចំពោះប្រទេសកម្ពុជាយើងវិញ ប្រទេសកំពុងអភិវឌ្ឍន៍នេះបានធ្វើសមាហរណកម្មចូលទៅក្នុងអាស៊ាន នៅឆ្នាំ១៩៩៩ និង អង្គការពាណិជ្ជកម្មពិភពលោក នៅឆ្នាំ២០០៤។ ជាលទ្ធផល កម្ពុជាបានធ្វើកំណែទម្រង់ក្នុងស្រុកជាច្រើនដើម្បីដើរឲ្យទាន់ការរីកចម្រើននៃសមាហរណកម្ម និងការអភិវឌ្ឍន៍នៃពិភពលោក។ ក្នុងចំណោមកំណែទម្រង់គោលនយោបាយជាច្រើន កូនពៅរបស់អាស៊ានមួយនេះក៏បានធ្វើកំណែទម្រង់គោលនយោបាយម៉ាក្រូសេដ្ឋកិច្ច ពោលគឺគោលនយោបាយសារពើពន្ធរបស់ខ្លួន ដើម្បីឲ្យស្របតាមលក្ខខណ្ឌនៃសមាហរណកម្មសេដ្ឋកិច្ចផងដែរ។

## ២. ចំណោទបញ្ហានៃការស្រាវជ្រាវ

ប្រទេសដទៃ ក៏ដូចជាប្រទេសកម្ពុជា សុទ្ធតែចង់ចូលជាសមាហរណកម្មសេដ្ឋកិច្ចដែលមានប្រយោជន៍សម្រាប់ខ្លួន។ ប៉ុន្តែ គេមិនអាចមើលរំលងនូវឥទ្ធិពលរបស់វា ទៅលើគោលនយោបាយក្នុងស្រុករបស់ប្រទេសកំពុងអភិវឌ្ឍន៍នោះទេ។ ជាពិសេស ស្របពេលដែលសារពើពន្ធរបស់ប្រទេសទាំងនោះមានសភាពខ្វះខាតហើយនោះ ការកាត់បន្ថយពន្ធនាំចូលដែលបណ្តាលមកពីកិច្ចព្រមព្រៀងសមាហរណកម្មទាំងនោះ នឹងធ្វើឲ្យថវិកាជាតិកាន់តែថយចុះមួយកម្រិតទៀត។

សារណាដែលមានប្រធានបទថា **«សមាហរណកម្មសេដ្ឋកិច្ច និងកំណែទម្រង់គោលនយោបាយម៉ាក្រូសេដ្ឋកិច្ចរបស់ប្រទេសកំពុងអភិវឌ្ឍន៍ (ករណីសិក្សាលើប្រទេសកម្ពុជា)»** ដែលគួរឲ្យចាប់អារម្មណ៍នេះ ត្រូវបានសិក្សាស្រាវជ្រាវ និងបកស្រាយដោយផ្អែកទៅសំណួរស្រាវជ្រាវគឺ៖

« **តើសមាហរណកម្មសេដ្ឋកិច្ចមានដំណើរការយ៉ាងដូចម្ដេច ហើយមានដំណើរឥទ្ធិពលទៅលើគោលនយោបាយសារពើពន្ធ និងសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជាយ៉ាងដូចម្ដេច?** »

## ៣. គោលបំណងនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះត្រូវបានធ្វើឡើងក្នុងគោលបំណងសំខាន់ៗដូចខាងក្រោម៖

- យល់ដឹងពីដំណើរការនៃការចូលសមាហរណកម្មសេដ្ឋកិច្ចរបស់ប្រទេសកំពុងអភិវឌ្ឍន៍
- សិក្សាពីឥទ្ធិពលនៃសមាហរណកម្មសេដ្ឋកិច្ចទៅលើប្រទេសកំពុងអភិវឌ្ឍន៍ និងជាពិសេសគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចរបស់កម្ពុជា
- សិក្សាពីការវិវត្តន៍នៃគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច ជាពិសេសនយោបាយសារពើពន្ធរបស់ប្រទេសកម្ពុជា
- ពិនិត្យមើលលើឥទ្ធិពលរបស់សមាហរណកម្មសេដ្ឋកិច្ចមកលើសេដ្ឋកិច្ចកម្ពុជា
- ចូលរួមជាបច្ច័យសម្រាប់ការស្រាវជ្រាវដើម្បីចូលរួមក្នុងការអភិវឌ្ឍន៍នៃប្រទេសកម្ពុជា
- ចងក្រងធ្វើជាឯកសារសម្រាប់ជាប្រយោជន៍ដល់ការស្រាវជ្រាវពាក់ព័ន្ធនានា និងការស្រាវជ្រាវនាពេលក្រោយទៀត។

## ៤. សារៈសំខាន់នៃការស្រាវជ្រាវ

ដោយសារតែ ប្រទេសកម្ពុជាបានផ្សារភ្ជាប់អនាគតរបស់ខ្លួនជាមួយនឹងសមាហរណកម្មសេដ្ឋកិច្ចដែរនោះ ការសិក្សាស្រាវជ្រាវនេះមានសារៈសំខាន់ដូចខាងក្រោម៖

- ផ្ដល់ជាចំណេះដឹងលម្អិតលើផ្នែកកំណែទម្រង់គោលនយោបាយសារពើពន្ធ និងការវិវត្តន៍នូវគោលនយោបាយនេះនៅកម្ពុជា
- ដឹងពីឥទ្ធិពលរបស់សមាហរណកម្មសេដ្ឋកិច្ចមកលើគោលនយោបាយសារពើពន្ធរបស់ប្រទេសកម្ពុជា
- តាមរយៈការសិក្សាយ៉ាងលម្អិតទៅលើករណីសិក្សារបស់ប្រទេសកម្ពុជា នឹងបង្ហាញយ៉ាងច្បាស់នូវបែបបទ ឬគម្រូសេដ្ឋកិច្ចដែលកម្ពុជាកំពុងប្រើប្រាស់នោះ
- ការសិក្សានេះ អាចយកទៅប្រើប្រាស់ក្នុងការវាយតម្លៃទៅលើកំណែទម្រង់ និងគម្រូកំណែទម្រង់ដែលបានប្រើប្រាស់ក្នុងពេលសព្វថ្ងៃ

- ធ្វើជាជំនួយក្នុងការសម្រេចចិត្តរបស់អ្នកបង្កើតគោលនយោបាយសេដ្ឋកិច្ចរបស់ប្រទេសកំពុងអភិវឌ្ឍន៍ដទៃទៀត ដោយយកកម្ពុជាជាគម្រូ។

## ៥. ទំហំ និងដែនកំណត់

ចំពោះទំហំ និងដែនកំណត់របស់ការសិក្សាស្រាវជ្រាវនេះ មានដូចខាងក្រោម៖

- សិក្សាទៅលើសមាហរណកម្មធំៗក្នុងពិភពលោកដែលមានដូចជា សហភាពអឺរ៉ុប, អាស៊ាន, អង្គការពាណិជ្ជកម្មពិភពលោក និង GATT ជាដើម
- ការសិក្សានឹងផ្តោតទៅលើតែប្រទេសកំពុងអភិវឌ្ឍន៍ ដោយជ្រើសរើសយកប្រទេសកម្ពុជាជាករណីយ៉ាងលម្អិត
- ការស្រាវជ្រាវនេះ នឹងផ្តោតសំខាន់ទៅលើកំណែទម្រង់គោលនយោបាយសារពើពន្ធ(ដែលជាគោលនយោបាយមួយរបស់គោលនយោបាយម៉ាក្រូ)តែប៉ុណ្ណោះ ដោយផ្តោតលើចំណាយ(G) និងចំណូល(T)របស់រដ្ឋាភិបាល។
- សារណានឹងផ្តោតលើការចំណូល និងចំណាយថ្នាក់ជាតិ,
- ចំពោះចំណូលពន្ធ T ការសិក្សានេះ នឹងផ្តោតទៅលើពន្ធនាំចូល ឬ ពន្ធគយ
- ពេលវេលាក្នុងការសិក្សាទៅលើករណីប្រទេសកម្ពុជា គឺចាប់ពីឆ្នាំ ២០០៨ ដល់ ២០១៧ ហើយមានទិន្នន័យព្យាករណ៍មួយចំនួនទៀតក្នុងឆ្នាំ ២០១៨។

## ៦. វិធីសាស្ត្រនៃការស្រាវជ្រាវ

❖ សម្រាប់ការប្រមូលទិន្នន័យ ការស្រាវជ្រាវនេះនឹងប្រព្រឹត្តទៅដោយ៖

- ប្រើប្រាស់វិធីសាស្ត្រស្រាវជ្រាវបែបគុណវិស័យ(Qualitative Approach)
- ប្រើប្រាស់ទិន្នន័យទី ២(Secondary Data)
- ប្រភេទទិន្នន័យដែលយកមកសិក្សាមានដូចជា៖ ឯកសារផ្សព្វផ្សាយជាសាធារណៈ, បទសម្ភាសន៍, ឯកសារនៅក្នុងអ៊ីនធើណេត, Journal Article, Research Paper, ទិន្នន័យស្ថិតិ និងលេខមួយចំនួនទៀតក្រោមទម្រង់ជាសូចនាករសេដ្ឋកិច្ចផ្សេងៗ
- ឯកសារមានប្រភពមកពី៖ ស្ថាប័នរដ្ឋ(មានដូចជា៖ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, វិទ្យាស្ថានជាតិស្ថិតិ និងធនាគារជាតិកម្ពុជាជាដើម), អង្គការអន្តររដ្ឋាភិបាលមួយចំនួន(ដូចជា៖ ធនាគារពិភពលោក, និង មូលនិធិហិរញ្ញវត្ថុពិភពលោក), អ្នកនិពន្ធជាតិ និងអន្តរជាតិ, និងគេហទំព័រមួយចំនួនដែលអាចជឿទុកចិត្តបាន។

❖ សម្រាប់ការវិភាគទិន្នន័យ អត្ថបទស្រាវជ្រាវនេះនឹងប្រើប្រាស់ ម៉ូឌែលផសស ដែលគេនិយមប្រើប្រាស់គឺ GDP = C + G + I +(X-M) ដើម្បីធ្វើការកំណត់ពីឥទ្ធិពលរបស់សមាហរណកម្មសេដ្ឋកិច្ចមកលើសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា។

## ៧. រចនាសម្ព័ន្ធស្រាវជ្រាវ

អត្ថបទសារណាស្រាវជ្រាវក្រោមប្រធានបទ «សមាហរណកម្មសេដ្ឋកិច្ច និងកំណែទម្រង់គោលនយោបាយម៉ាក្រូសេដ្ឋកិច្ចរបស់ប្រទេសកំពុងអភិវឌ្ឍន៍ (ករណីសិក្សាលើប្រទេសកម្ពុជា)» ត្រូវបានបែងចែកជា ៦ផ្នែកធំៗគឺ៖

- **សេចក្តីផ្តើម៖** ជាផ្នែកដំបូងគេដែលបរិយាយអំពី លំនាំបញ្ហា ចំណូលបញ្ហា ចំណោទបញ្ហា ទំហំ និងដែនកំណត់ គោលបំណងនៃការស្រាវជ្រាវ វិធីសាស្ត្រនៃការស្រាវជ្រាវ និងរចនាសម្ព័ន្ធនៃការស្រាវជ្រាវ។
- **ជំពូកទី១ - ទ្រឹស្តីពាក់ព័ន្ធ៖** ផ្នែកនេះបង្ហាញពីការរំលឹកនូវទ្រឹស្តីមួយចំនួនដែលទាក់ទងនឹងសមាហរណកម្មសេដ្ឋកិច្ច, ម៉ាក្រូសេដ្ឋកិច្ច, គោលនយោបាយម៉ាក្រូសេដ្ឋកិច្ច, និយមន័យប្រទេសកំពុងអភិវឌ្ឍន៍, និងម៉ូឌែលផលិតផលក្នុងស្រុកសរុបដុល។
- **ជំពូកទី២ - ប្រទេសកំពុងអភិវឌ្ឍន៍ និងសមាហរណកម្មសេដ្ឋកិច្ច៖** ជំពូកនេះនឹងបកស្រាយពីលក្ខណៈដូចគ្នារបស់ប្រទេសកំពុងអភិវឌ្ឍន៍, និងការចូលសមាហរណកម្មរបស់ពួកគេ។
- **ជំពូកទី៣ - កំណែទម្រង់គោលនយោបាយសារពើពន្ធ - ករណីសិក្សាប្រទេសកម្ពុជា៖** ជំពូកទី៣នេះ នឹងសិក្សាយ៉ាងលម្អិតទៅលើប្រទេសកម្ពុជា ទាំងលក្ខណៈទូទៅនៃម៉ាក្រូសេដ្ឋកិច្ច, ដំណើរការនៃការធ្វើកំណែទម្រង់គោលនយោបាយសារពើពន្ធរបស់កម្ពុជា, និងលទ្ធផលនៃការធ្វើកំណែទម្រង់នោះ។
- **ជំពូកទី ៤ - ជំពូកពិភាក្សា៖** ជំពូកនេះនឹងធ្វើការសំយោគនូវទិន្នន័យដែលស្រាវជ្រាវបានហើយនិងពិភាក្សាឥទ្ធិពលរបស់សមាហរណកម្មសេដ្ឋកិច្ចទៅលើសេដ្ឋកិច្ចកម្ពុជាទាំងមូលតាមរយៈការប្រើប្រាស់ម៉ូឌែលផសស។
- **សេចក្តីសន្និដ្ឋាន និងអនុសាសន៍៖** ផ្នែកចុងក្រោយនៃអត្ថបទសារណាមួយនេះ នឹងធ្វើការសង្ខេបឡើងវិញនូវលទ្ធផលដែលយើងរកឃើញពីការស្រាវជ្រាវ និងផ្តល់ជាអនុសាសន៍ក្នុងក្របខ័ណ្ឌនៃការការស្រាវជ្រាវនេះ។

# ជំពូកទី១
# ទ្រឹស្តីពាក់ព័ន្ធ

## ១. ទ្រឹស្តីសមាហរណកម្មសេដ្ឋកិច្ច

### ១.១. អ្វីជាសមាហរណកម្ម?

«**សមាហរណកម្ម ឬ Integration**» ជាពាក្យបច្ចេកទេសដែលត្រូវបានគេយកទៅប្រើប្រាស់ក្នុងការសិក្សាសង្គមវិទ្យា(Sociology) មុនពេលដែលត្រូវបានគេយកមកប្រើប្រាស់ក្នុងវិស័យសេដ្ឋកិច្ច។ ជាទូទៅ ពាក្យថាសមាហរណកម្ម ត្រូវបានគេសម្តៅទៅលើការបង្រួបបង្រួមផ្នែកផ្សេងៗនៃសង្គមឲ្យទៅជាបណ្តុំធំមួយ ឬជាការកំណត់នូវផ្នែកផ្សេងៗដែលជាប់ទាក់ទងទៅនឹងបណ្តុំធំមួយ។ យ៉ាងណាមិញ សមាហរណកម្មសង្គម គឺជាគោលគំនិតក្លាសិចមួយនៅក្នុងសង្គមវិទ្យា ដែលត្រូវបានគេប្រើដើម្បីរួមបញ្ចូលគ្រប់ប្រភេទមនុស្សទាំងអស់ទៅក្នុងសង្គមរួបរួមមួយតាមរយៈការលុបបំបាត់រណាំងច្បាប់ (ដូចជាការកំណត់វណ្ណៈជាដើម) និងតាមរយៈយន្តការលុបបំបាត់ការរើសអើងភេទ និងពូជសាសន៍នៅក្នុងសង្គម ទាំងនៅក្នុងវិស័យរដ្ឋ និងវិស័យឯកជន។

ដោយឡែកគោលគំនិត **សមាហរណកម្មសេដ្ឋកិច្ច** ត្រូវបានសេដ្ឋវិទូពេញនិយមយកមកប្រើប្រាស់នៅក្នុងទសវត្សឆ្នាំ ១៩៥០ ដែលមានរបត់ថ្មីនៃសេដ្ឋកិច្ចអន្តរជាតិ និងពាណិជ្ជកម្មអន្តរជាតិក្រោយពីសង្គ្រាមលោកលើកទី ២ ត្រូវបានបញ្ចប់ទៅ។ ដើមឡើយ ពាក្យថា សមាហរណកម្មសេដ្ឋកិច្ចត្រូវបានអ្នកសេដ្ឋកិច្ចភាគច្រើនយកទៅប្រើប្រាស់ក្នុងបរិបទនៃរចនាសម្ព័ន្ធរបស់ក្រុមហ៊ុន ដែលសម្តៅទៅលើការដាក់បញ្ចូលគ្នា ឬការធ្វើសមាហរណកម្មសហគ្រាសច្រើន ឲ្យទៅជាសហគ្រាសធំមួយតាមរយៈការធ្វើសមាហរណកម្មផ្តេក[1] និងសមាហរណកម្មបញ្ឈរ[2] (Horizontal integration and Vertical Integration)។ យ៉ាងណាមិញនៅក្នុងអំឡុងពេលចាប់បដិសន្ធិនៃគោលគំនិត សមាហរណកម្មសេដ្ឋកិច្ចនេះ សេដ្ឋវិទូជាច្រើនបានអះអាង និងឲ្យនិយមន័យខុសៗគ្នាទៅលើគោលគំនិតនេះដូចជា៖

- សេដ្ឋវិទូហូឡង់ Jan Tinbergen៖ «សមាហរណកម្មសេដ្ឋកិច្ចជាការលុបបំបាត់ការរើសអើង និងការរឹតបណ្តឹងរបស់ស្ថាប័ន ដើម្បីបង្កើតឲ្យមានសេរីភាពនៃប្រតិបត្តិការសេដ្ឋកិច្ច»។

[1] សមាហរណកម្មផ្តេក កើតឡើងនៅពេលក្រុមហ៊ុនចង់គ្រប់គ្រងដំណាក់កាលផ្សេងៗគ្នានៃផលិតកម្មដែលមាននៅក្នុងក្រុមហ៊ុនតែមួយ

[2] សមាហរណកម្មបញ្ឈរ កើតឡើងនៅពេលមានការដាក់បញ្ចូលគ្នារវាងក្រុមហ៊ុនពីរ ឬច្រើនមានដំណាក់កាលផលិតដូចគ្នាដែលស្ថិតនៅក្នុងប្រភេទឧស្សាហកម្មតែមួយចូលគ្នា

- សេដ្ឋវិទូ Pinder៖ «សមាហរណកម្មសេដ្ឋកិច្ចជាការដាក់បញ្ចូលផ្នែកផ្សេងៗចូលទៅជាផ្នែកធំ»។
- សេដ្ឋវិទូ Mennis និង Sauvant៖ «សមាហរណកម្មសេដ្ឋកិច្ចជាដំណើរការដែលព្រំដែនរបស់រដ្ឋជាប់គ្នាជាងមុន ដែលឆ្ពោះទៅរកការបង្កើតនូវប្រព័ន្ធទូលំទូលាយមួយ»។
- សេដ្ឋវិទូ Pelkmans៖ «សមាហរណកម្មសេដ្ឋកិច្ចជាការលុបបំបាត់នូវព្រំដែនសេដ្ឋកិច្ចរវាងប្រទេស ២ ឬច្រើន»។
- សេដ្ឋវិទូ Balassa៖ «សមាហរណកម្មសេដ្ឋកិច្ចជាដំណើរការនៃការលុបបំបាត់នូវការរើសអើងរវាងប្រទេស»។

ដោយហេតុថាមានការបកស្រាយខុសគ្នានេះហើយ ទើបបានជាយើងពិបាកនឹងឲ្យនិយមន័យពាក្យសមាហរណកម្មសេដ្ឋកិច្ចណាស់។ យ៉ាងណាមិញ ទ្រឹស្តីរបស់ Balassa ដែលថា «សមាហរណកម្មសេដ្ឋកិច្ចជាដំណើរការនៃការលុបបំបាត់នូវការរើសអើងរវាងប្រទេស» ទទួលបានការពេញនិយម ហើយត្រូវបានអ្នកស្រាវជ្រាវជាច្រើនយកធ្វើជាគោលគំនិតក្នុងការសិក្សារ។ គោលគំនិតនេះមានអត្ថន័យមិនចង្អៀតពេល ហើយក៏មិនទូលាយពេកដែរ។ វាមានន័យដែលអាចក្តោបទៅលើវិស័យផ្សេងៗទៀត ព្រោះសមាហរណកម្មនៅលើវិស័យណាមួយនឹងជះឥទ្ធិពលនាំឲ្យមានសមាហរណកម្មលើវិស័ផ្សេងទៀត។ មួយវិញទៀត សមាហរណកម្មក្នុងពេលបច្ចុប្បន្ននេះ មិនត្រឹមតែលុបបំបាត់នូវការរើសអើងផ្នែកសេដ្ឋកិច្ចនោះទេ ថែមទាំងលុបបំបាត់ការរើសអើងផ្នែកនយោបាយ(សមាហរណកម្មសេដ្ឋកិច្ចរបស់ចិនកុំម្មុយនីស្ត និងប្រទេសប្រជាធិបតេយ្យ) និងផ្នែកសង្គម(សមាហរណកម្មសេដ្ឋកិច្ចរវាងប្រទេសស្បែកខ្មៅ និងស្បែកសនៅក្នុងអង្គការពាណិជ្ជកម្មពិភពលោក)ថែមទៀតផង។ យ៉ាងណាក៏ដោយ សមាហរណកម្មសេដ្ឋកិច្ចសម្តៅជាទូទៅ ទៅលើការលុបបំបាត់នូវរណាំង ឬធាតុអវិជ្ជមាននានា (មានរណាំងពន្ធ និងរណាំងមិនមែនពន្ធ[3]) ដែលប្រទេសនីមួយៗធ្លាប់ដាក់លើគ្នាពីមុនមក ហើយតាមរយៈការលុបបំបាត់រណាំងនៃសមាហរណកម្មទាំងនេះ វានឹងជម្រុញឲ្យមានពាណិជ្ជកម្មសេរី និងបង្កើតឲ្យមានការបែកចែក ឬការលែកម្លាំងពលកម្មដ៏មានប្រសិទ្ធភាពនៅក្នុងប្លុកប្រទេសដែលជាសមាជិក។

[3] រណាំងមិនមែនពន្ធ មាន អជ្ញាប័ណ្ណនាំចូល (import licensing), បទបញ្ញត្តិវង្វាយតម្លៃទំនិញ (rules for the valuation of goods at customs), អធិការកិច្ចមុនលើការនាំចូល (pre-shipment inspection: further checks on import), ច្បាប់នៃប្រភព (rules of origin), វិធានការវិនិយោគ (investment measures)

## ១.២. ប្រភេទនៃសមាហរណកម្មសេដ្ឋកិច្ច

### ១.២.១. តំបន់ពាណិជ្ជកម្មសេរី ( Free Trade Area )

តំបន់ពាណិជ្ជកម្មសេរី ត្រូវបានសេដ្ឋវិទូជាច្រើនចាត់ទុកថាជាដំណាក់កាលដំបូងនៃសមាហរណកម្មសេដ្ឋកិច្ចមួយ ហើយក៏ជាសមាហរណកម្មសេដ្ឋកិច្ចមួយប្រភេទដែលងាយក្នុងការបង្កើតជាងប្រភេទសមាហរណកម្មណាណាទាំងអស់។ ជាទូទៅ តំបន់ពាណិជ្ជកម្មសេរីនេះត្រូវបានគេបង្កើតឡើងក្រោយពីមានកិច្ចព្រមព្រៀង ឬសន្ធិសញ្ញាដោយប្រទេសដែលមានគំនិតដូចគ្នាក្នុងការបង្កើតតំបន់នេះឡើង។ សមាហរណកម្មប្រភេទនេះ ទាមទារឲ្យប្រទេសសមាជិកលុបចោលនូវពន្ធនាំចូល ឬកូតាពាណិជ្ជកម្មរវាងគ្នានិងគ្នា។ យ៉ាងណាមិញ ប្រទេសសមាជិកនៃតំបន់ពាណិជ្ជកម្មសេរីមានឯករាជ្យភាពផ្ទាល់ខ្លួនក្នុងការកំណត់ពន្ធនាំចូល ឬកូតាទៅលើប្រទេសដ៏ទៃទៀតដែលក្រៅពីប្រទេសសមាជិក (ROW)។ វានឹងធ្វើឲ្យថ្លៃទំនិញដែលនាំចូលពីប្រទេសដទៃឡើងថ្លៃជាងថ្លៃទំនិញដែលនាំចូលដោយប្រទេសជាសមាជិក។ ក្នុងករណីនេះ ដើម្បីកំណត់ឲ្យបាននូវភាពពិតប្រាកដ និងប្រសិទ្ធិភាពនៃការធ្វើសមាហរណកម្ម ប្រទេសសមាជិកគប្បីបង្កើតឡើងនូវប្រព័ន្ធ ឬច្បាប់កំណត់ប្រភពនៃទំនិញឲ្យបានច្បាស់ដើម្បីបែងចែកយ៉ាងច្បាស់លាស់រវាងទំនិញ និងសេវាកម្មដែលបង្កើតឡើងដោយប្រទេសជាសមាជិក និងប្រទេសដទៃ។ និយាយឲ្យខ្លីទៅ តំបន់ពាណិជ្ជកម្មសេរីបំបាត់ពន្ធនាំចូលរវាងប្រទេសសមាជិក ប៉ុន្តែផ្តល់សិទ្ធិឲ្យពួកគេកំណត់ពន្ធនាំចូលទៅលើប្រទេសដទៃ (ROW)។

### ១.២.២. សហភាពពន្ធគយរួម ( Custom Union )

សហភាពពន្ធគយរួម គឺជាដំណាក់កាលបន្ទាប់ពីតំបន់ពាណិជ្ជកម្មសេរី។ បន្ថែមពីលើលក្ខខណ្ឌដែលមានរបស់តំបន់ពាណិជ្ជកម្មសេរី សហភាពពន្ធគយរួមអនុវត្តប្រព័ន្ធយកពន្ធរួមមួយទៅលើទំនិញ ឬសេវាកម្មនាំចូលទាំងឡាយរបស់ប្រទេសដែលមិនមែនជាសមាជិក។ និយាយឲ្យខ្លី សមាជិករបស់សហភាពពន្ធគយយកពន្ធនាំចូលក្នុងតម្លៃ ឬបរិមាណដូចគ្នាទៅលើទំនិញ ឬសេវាកម្មរបស់ប្រទេសដែលមិនមែនជាសមាជិក។

### ១.២.៣. ទីផ្សាររួម ( Common Market )

ទីផ្សាររួម ជាដំណាក់កាលបន្ទាប់ពីសហភាពពន្ធគយ ដែលក្នុងនោះប្រទេសដែលជាសមាជិក មិនត្រឹមតែមានប្រព័ន្ធពន្ធគយរួមនោះទេ កត្តាផលិតកម្មដែលមិនមែនជាផលិតផល មានដូចជា ពលកម្ម និងមូលធន ត្រូវបានចល័តដោយសេរី និងមិនមានការរឹតត្បិតរវាងប្រទេសសមាជិក។

ពោលគឺ ប្រទេសសមាជិកទាំងអស់ប្រមូលផ្តុំគ្នា ហើយធ្វើចរាចរណ៍ផលិតផល សេវាកម្ម និងកត្តាផលិតកម្ម ដូចនៅក្នុងប្រទេសតែមួយ។

**១.២.៤. សហភាពសេដ្ឋកិច្ច** ( Economic Union )

សមាហរណកម្មក្នុងសហភាពសេដ្ឋកិច្ចនេះកាន់តែស៊ីជម្រៅជាងទីផ្សាររួមទៅទៀត។ បន្ទាប់ពីមានប្រព័ន្ធពន្ធគយ និងមានចរាចរដោយសេរីនៃផលិតផល សេវាកម្ម និងកត្តាផលិតកម្មនៅក្នុងប្រទេសជាសមាជិកហើយនោះ ប្រទេសដែលជាសមាជិកនៃសហភាពសេដ្ឋកិច្ចដាក់ចេញនូវគោលនយោបាយសេដ្ឋកិច្ចជាតិដើម្បីសម្រេចឲ្យបាននូវសុខដុមនីយកម្មនៅក្នុងតំបន់ទៀតផង។

**១.២.៥. សមាហរណកម្មសេដ្ឋកិច្ចទាំងស្រុង** ( Total Economic Integration )

សហភាពអ៊ឺរ៉ុបត្រូវបានអ្នកសេដ្ឋកិច្ចភាគច្រើនចាត់ទុកថាជាសមាហរណកម្មសេដ្ឋកិច្ចទាំងស្រុង ដែលក្នុងនោះសហភាពអ៊ឺរ៉ុបមាននូវ នយោបាយហិរញ្ញវត្ថុរួម នយោបាយសារពើពន្ធរួម និងគោលនយោបាយសង្គមផ្សេងៗទៀតរួមដែលក្នុងនោះវាហាក់ដូចជាប្រទេសទាំងអស់នៅក្នុងសហភាពអ៊ឺរ៉ុបបានបង្រួបបង្រួមគ្នាឲ្យទៅជាប្រទេសតែមួយ។ ជាមួយគ្នានេះផងដែរ ក្រៅពីមានគោលនយោបាយរួមហើយនោះ សមាហរណកម្មសេដ្ឋកិច្ចទាំងស្រុង ទាមទារឲ្យមាននូវស្ថាប័នថ្នាក់លើជាតិដែលមានអំណាចខ្ពស់បំផុតមួយ(Supra-National Authority) ដើម្បីធ្វើការគ្រប់គ្រង ត្រួតពិនិត្យ និងអនុវត្តនូវគោលនយោបាយទាំងនោះផងដែរ។ ក្នុងនោះ នៅក្នុងសហភាពអ៊ឺរ៉ុប មានទីប្រឹក្សានៃសហភាពអ៊ឺរ៉ុប(Council of European Union) ដែលជាអ្នកដើរតួជាស្ថាប័នអំណាចខ្ពស់បំផុតដូចដែលបានរៀបរាប់ខាងលើ។

ទោះជាណាក្តី បើយើងពិនិត្យដោយយកចិត្តទុកដាក់ទៅលើសមាហរណកម្មទាំង ៥ខាងលើ យើងសង្កេតឃើញថា តំបន់ពាណិជ្ជកម្មសេរី, សហភាពពន្ធគយ, ទីផ្សាររួម ជាសមាហរណកម្មដែលផ្តោតទៅលើការធ្វើសមាហរណកម្មទីផ្សារដោយហេតុថា វាទាំង ៣ មានគោលបំណងក្នុងការបង្កើតឲ្យបាននូវទីផ្សាររួមគ្នាមួយរវាងប្រទេសសមាជិក និងការពារទីផ្សារនោះ។ រីឯ សហភាពសេដ្ឋកិច្ច និងសមាហរណកម្មសេដ្ឋកិច្ចទាំងស្រុង ជាសមាហរណកម្មនយោបាយសេដ្ឋកិច្ចជាន់ខ្ពស់រវាងប្រទេសជាសមាជិក ដោយបង្កើតបានជាសមាហរណកម្មពេញលេញមួយ។

## ១. ៣. ការអនុវត្តនៃសមាហរណកម្មសេដ្ឋកិច្ចក្នុងពិភពលោក

ទោះបីជាក្នុងនេះបានរៀបរាប់មកពីខាងដើមថា ទ្រឹស្តីសមាហរណកម្មសេដ្ឋកិច្ចត្រូវបានអ្នកសេដ្ឋកិច្ចកំណត់ថាចាប់ផ្តើមនាំគ្នានៅក្នុងអំឡុងឆ្នាំ ១៩៥០យ៉ាងណាក្តី ប៉ុន្តែគេសង្កេតឃើញថាសមាហរណកម្មសេដ្ឋកិច្ចចាប់លេចរូបរាងឡើងតាំងពីក្រោយការបញ្ចប់សង្គ្រាមលោកលើកទី ២

មកម្ល៉េះ ពោលគឺការបង្កើត កិច្ចព្រមព្រៀងទូទៅលើពន្ធនាំចូល និងពាណិជ្ជកម្ម(General Agreement on Tax and Trade GATT) នៅឆ្នាំ ១៩៤៧មកម្ល៉េះ។

### ១.៣.១. កិច្ចព្រមព្រៀងទូទៅលើពន្ធនាំចូល និងពាណិជ្ជកម្ម( General Agreement on Tariffs and Trade ឬ GATT )

កិច្ចព្រមព្រៀងទូទៅលើពន្ធនាំចូល និងពាណិជ្ជកម្ម ត្រូវបានគេចាប់ផ្តើមចរចារបង្កើតឡើងនៅឆ្នាំ ១៩៤៧ និងត្រូវបានចូលជាធរមាននៅថ្ងៃទី ៣០ មិថុនា ឆ្នាំ១៩៤៨។ កិច្ចព្រមព្រៀងនេះត្រូវបានគេបង្កើតឡើងក្នុងគោលបំណងលុបបំបាត់ចោលនូវរបាំងពាណិជ្ជកម្មដើម្បីបង្កើនពាណិជ្ជកម្មអន្តរជាតិ និងទប់ស្កាត់បញ្ហាគោលនយោបាយគាំពារនិយមជ្រុលដែលអាចបង្កឲ្យទៅជាវិបត្តិសេដ្ឋកិច្ចពិភពលោក ដូចជា៖ បញ្ហា Great Depression[4] និងសង្គ្រាមលោកលើកទី ២ជាដើម[5]។ ក្នុងនាមជាកត្តាលីករជម្រុញពាណិជ្ជកម្មអន្តរជាតិ GATT មានគោលការណ៍សំខាន់ៗ ៣ គឺ៖ ក្រុមប្រទេសដែលត្រូវបានគេអនុគ្រោះ(Most Favored Nation), លុបបំបាត់ចោលការកំហិតលើបរិមាណនៃការនាំចេញ និងនាំចូល[6], និងការលុបបំបាត់ពន្ធនាំចូលលើផលិតផលរបស់ប្រទេសកំពុងអភិវឌ្ឍន៍[7]។

---

[4]ប្រទេសអាមេរិក និងប្រទេសនៅអឺរ៉ុបជាច្រើនបាននាំគ្នាប្រើប្រាស់គោលនយោបាយគាំពារនិយមជ្រុលដើម្បីការពារផលិតផលក្នុងស្រុករបស់ខ្លួនរហូតដល់ធ្វើឲ្យមានការផ្គត់ផ្គង់កើនលើសតម្រូវការហួសកម្រិត

[5] នៅក្នុងដំណាក់កាលចាប់ផ្តើមនៃសង្គ្រាមលោកលើកទី ២ ប្រទេសអឺរ៉ុបជាច្រើនបាននាំគ្នាប្រើប្រាស់គោលនយោបាយគាំពារនិយមការពារផលិតផលក្នុងស្រុករបស់ខ្លួន បដិសេធទំនិញនាំចូលរបស់ជប៉ុនដែលធ្វើឲ្យទំនិញរបស់ប្រទេសជប៉ុនជាច្រើនបាត់បង់ទីផ្សារ ហើយវាក្លាយទៅជាមូលហេតុសេដ្ឋកិច្ចដែលធ្វើឲ្យប្រទេសសម្រេចចិត្តធ្វើសង្គ្រាម

[6] លើកលែងករណីមួយចំនួនដូចជា៖ នៅពេលដែលការផ្គត់ផ្គង់ទំនិញកសិកម្មលើសកំណត់, ដើម្បីរក្សាតុល្យការចំណាយ, និងដើម្បីគាំពារដល់ឧស្សាហកម្មក្មេងខ្ចី

[7] ទើបតែត្រូវបានគេបន្ថែមចូលនៅឆ្នាំ១៩៦៥ ដោយសារតែចំនួនរបស់ប្រទេសកំពុងអភិវឌ្ឍន៍ចូលមកក្នុងGATT កើនឡើង

តារាងទី ១៖ កម្រិតពន្ធនាំចូលជាមធ្យមរបស់ប្រទេសអភិវឌ្ឍន៍មួយចំនួននៅក្នុងពិភពលោកបើធៀប នឹងឆ្នាំ២០០៧ (គិតជា%)

| *Country* | *1913* | *1925* | *1931* | *1952* | *2007*[a] |
|---|---|---|---|---|---|
| Belgium | 6 | 7 | 17 | n.a. | 5.2 |
| France | 14 | 9 | 38 | 19 | 5.2 |
| Germany | 12 | 15 | 40 | 16 | 5.2 |
| Italy | 17 | 16 | 48 | 24 | 5.2 |
| United Kingdom | n.a. | 4 | 17 | 17 | 5.2 |
| United States | 32 | 26 | 35 | 9 | 3.5 |

Source: Data for 1913, 1925, 1931, and 1952 are from Irwin (2002, table 5.1, p. 153). Data for 2007 are from WTO (2008c).

n.a. = Not available.

a. Tariff levels for each European Community member country represent the EC-wide import tariff rate.

យ៉ាងណាមិញ បន្ទាប់ពីមានការពិភាក្សាគ្នាជាបន្តបន្ទាប់ចំនួន ៨ដង ចាប់ពីឆ្នាំ ១៩៤៧មក កិច្ចព្រមព្រៀងទូទៅនៃពន្ធនាំចូល និងពាណិជ្ជកម្មនេះត្រូវបានគេធ្វើសមាហរណកម្មខ្លឹមសារសំខាន់ និងសំយោគ ហើយបន្ថែមគោលការណ៍ផ្សេងៗ ដើម្បីបង្កើតជាអង្គការពាណិជ្ជកម្មពិភពលោក នៅឆ្នាំ ១៩៩៤។

**១.៣.២. សហភាពអឺរ៉ុប** ( European Union )

ក្រោយសង្គ្រាមលោកលើទី ២ត្រូវបានបញ្ចប់ ដើម្បីរកដំណោះស្រាយបញ្ចៀសនូវបញ្ហាសង្គ្រាមលោកម្តងទៀត មេដឹកនាំអឺរ៉ុបបាននាំគ្នាជួបពិភាក្សាគ្នាដើម្បីរិះរកនូវដំណោះស្រាយដែលអាចធ្វើបាន។ ស្របពេលជាមួយគ្នានេះដែរ ប្រទេសអឺរ៉ុបទាំងនោះក៏កំពុងតែខិតខំស្តារសេដ្ឋកិច្ចរបស់ខ្លួនផងដែរ ដោយផ្តោតលើការស្តារសេដ្ឋកិច្ចតាមបែបឧស្សាហកម្ម។ តាមរយៈការប្រើប្រាស់ម៉ូឌែលឧស្សាហកម្មនេះ ប្រទេសអឺរ៉ុបទាំងនោះនាំគ្នាគិតគូរលើបញ្ហាថាមពល(ធ្យូងថ្ម) និងវត្ថុធាតុដើមឧស្សាហកម្មសំខាន់គឺ ដែក ជាកត្តាសំខាន់ដើម្បីស្តារសេដ្ឋកិច្ច និងឧស្សាហកម្មនានា។ ឆ្នាំ ១៩៥០ សហគមន៍ធ្យូងថ្ម និងដែកអឺរ៉ុប (The European Coal and Steer Community) ដែលមានប្រទេសហត្ថលេខីចំនួន ៦គឺ៖ ប៊ែលស៊្សិក, បារាំង, អាល្លឺម៉ង់ខាងលិច, អ៊ីតាលី, លុចហ្សំបួរ និង ហូឡង់ ត្រូវបានបង្កើតឡើងដើម្បីគ្រប់គ្រងការផ្គត់ផ្គង់ធ្យូងថ្ម និងដែក និងដើម្បីការពារសង្គ្រាមពាណិជ្ជកម្មលើផលិតផលទាំង ២។ ពេលនេះហើយ ដែលសេដ្ឋកិច្ចវិទូជាច្រើនបានសន្មត់ថា ជាការកកើតឡើងនូវចលនាសមាហរណកម្មមួយនៅអឺរ៉ុប ដែលគ្រានោះ អ្នកសេដ្ឋកិច្ចអឺរ៉ុបមានសុទិដ្ឋិនិយមយ៉ាងខ្លាំងថា វានឹងក្លាយជាសមាហរណកម្មដែលអាចនាំអឺរ៉ុប និងពិភពលោកទាំងមូលទៅរកសន្តិភាពយ៉ាងយូរអង្វែង។

ក្នុងដំណាក់កាលនេះ ការប្រើប្រាស់នយោបាយថ្នាក់ទាប(Low Politics)[8]ដើម្បីរកសុខសន្តិភាព និងការអភិវឌ្ឍន៍ឲ្យពិភពលោក ត្រូវបានអ្នកនយោបាយ និងអ្នកសេដ្ឋកិច្ចជាច្រើនអបអរសាទរទូទាំងពិភពលោក។ ដោយសារតែការរីកលូតលាស់នៃសហគមន៍ធ្យូងថ្ម និងដែកអឺរ៉ុប សហគមន៍នេះបានឈានជើងមួយជំហានទៀតដោយបានក្លាយខ្លួនទៅជា សហគមន៍សេដ្ឋកិច្ចអឺរ៉ុប (European Economic Community) ដែលត្រូវបានគេចាត់ទុកជាទីផ្សាររួមមួយ ក្រោយពីការចុះសន្ធិសញ្ញាទីក្រុងរ៉ូម (Treaty of Rome) នៅឆ្នាំ ១៩៥៧។ បន្ទាប់ពីមានការបញ្ឈប់ការយកពន្ធលើគ្នាក្នុងការដោះដូរពាណិជ្ជកម្មរវាងគ្នា និងគ្នា ក្នុងទសវត្សទី ៧0 សមាជិកនៃសហគមន៍សេដ្ឋកិច្ចនេះមានកំណើនសេដ្ឋកិច្ចគួរឲ្យកត់សម្គាល់។ តមកទៀត សហគមន៍សេដ្ឋកិច្ចនេះក៏ចាប់ផ្តើមពង្រីកខ្លួនជាបន្តបន្ទាប់ ពី៦ប្រទេស ទៅ ៩ប្រទេស(ឆ្នាំ ១៩៧៣ ដាណឺម៉ាក, អៀកឡង់ និងចក្រភពអង់គ្លេស ចូលជាសមាជិក) ទៅជា ១០ប្រទេស(ក្រិច ចូលនៅឆ្នាំ ១៩៨១) និងជាបន្តបន្ទាប់រហូតទៅដល់ ២៨ប្រទេសនៅឆ្នាំ ២០១៣ បើទោះបីជាមានវិបត្តិផ្សេងៗកើតឡើងដូចជា វិបត្តិប្រេងឆ្នាំ ១៩៧០, ការដួលរលំកំផែងប៊ែកឡាំងឆ្នាំ ១៩៨៩, វិបត្តិសេដ្ឋកិច្ចឆ្នាំ ២០០៨ ក៏ដោយ។ ជាមួយគ្នានេះ គេអាចសន្និដ្ឋានបានថា សហភាពអឺរ៉ុបរហូតមកដល់បច្ចុប្បន្ននេះបានឆ្លងកាត់តំណាក់កាល ៦សំខាន់ៗគឺ៖

- ដំណាក់ដំបូងនៃសហប្រតិបត្តិការ (ឆ្នាំ ១៩៤៥ ដល់១៩៥៩)
- ដំណាក់កាលអភិវឌ្ឍន៍សេដ្ឋកិច្ច (ឆ្នាំ ១៩៦0 ដល់១៩៦៩)
- ដំណាក់កាលពង្រីកខ្លួន (ឆ្នាំ ១៩៧0 ដល់១៩៧៩)
- ដំណាក់កាលផ្លាស់ប្តូរមុខមាត់ថ្មីរបស់អឺរ៉ុប (ឆ្នាំ ១៩៨0 ដល់១៩៨៩)
- ដំណាក់កាលបង្រួបបង្រួមអឺរ៉ុប (ឆ្នាំ ១៩៩0 ដល់១៩៩៩)[9]
- ដំណាក់កាលសហប្រតិបត្តិការដ៏ស៊ីជម្រៅ និងរឹងមាំ (ឆ្នាំ ២000 ដល់២00៩)[10]
- ដំណាក់កាលជួបបញ្ហាប្រឈម (ឆ្នាំ ២0១0 ដល់បច្ចុប្បន្ន)។

[8] នយោបាយថ្នាក់ទាប(Low Politics) ជាប្រភេទគោលនយោបាយដែលផ្តោតលើការអភិវឌ្ឍន៍លើវិស័យសេដ្ឋកិច្ច និងសង្គមដើម្បីឲ្យប្រទេសមានការអភិវឌ្ឍន៍ ស្របពេលដែលនយោបាយថ្នាក់ខ្ពស់(High Politics) ផ្តោតលើការថែរក្សាសន្តិសុខរបស់ប្រទេស

[9] ឆ្នាំ ១៩៩២ សហគមន៍សេដ្ឋកិច្ចអឺរ៉ុប បានប្រែក្លាយទៅជាសហភាពអឺរ៉ុបបន្ទាប់ពីមានការចុះសន្ធិសញ្ញា Maastricht

[10] ជាដំណាក់កាលដែលសហភាពអឺរ៉ុបបានបង្កើតរូបិយបណ្ណរួមមួយ នៅថ្ងៃទី ០១ មករា ២០០២

ក្រាហ្វិកទី ១៖ អត្រាកំណើន GDP របស់សហភាពអឺរ៉ុប(គិតជា%)




តារាងទី ២៖ ទិន្នន័យសូចនាករសេដ្ឋកិច្ចមួយចំនួនរបស់សហភាពអឺរ៉ុប

| European Union GDP | Last | Previous | Highest | Lowest | Unit |
|---|---|---|---|---|---|
| GDP Annual Growth Rate | 2.40 | 2.70 | 4.60 | -5.40 | percent |
| GDP | 17277.70 | 16491.86 | 19137.01 | 359.03 | USD Billion |
| Gross Fixed Capital Formation | 761999.40 | 752512.60 | 770898.60 | 505340.10 | EUR Million |
| GDP Constant Prices | 3594710.90 | 3580422.40 | 3594710.90 | 2403452.00 | EUR Million |
| GDP Growth Rate | 0.40 | 0.70 | 1.30 | -2.60 | percent |
| GDP Per Capita | 36593.03 | 35809.95 | 36593.03 | 10056.66 | USD |
| GDP Per Capita Ppp | 37204.61 | 36357.07 | 37204.61 | 24875.04 | USD |

ប្រភពៈគេហទំព័រ https://tradingeconomics.com/european-union/gdp-annual-growth-rate

### ១.៣.៣. សមាគមន៍ប្រជាជាតិអាស៊ីអាគ្នេយ៍ (Association of Southeast Asian Nations)

សមាគមន៍ប្រជាជាតិអាស៊ីអាគ្នេយ៍ ឬហៅកាត់ថាអាស៊ានគឺជាសមាហរណកម្មសេដ្ឋកិច្ច ដែលមានលក្ខណៈជាតំបន់ពាណិជ្ជកម្មសេរីនៅក្នុងតំបន់អាស៊ីភាគអាគ្នេយ៍ដែលត្រូវបានបង្កើតឡើង ដោយស្ថាបនិក ៥គឺៈ ប្រទេសថៃ, សឹង្ហបុរី, ឥណ្ឌូនេស៊ី, ហ្វីលីពីន និងម៉ាឡេស៊ី។ អាស៊ានត្រូវបាន បង្កើតឡើងបន្ទាប់ពីមានការចុះសន្ធិសញ្ញាទីក្រុងបាងកក ឆ្នាំ១៩៦៧ ក្នុងគោលបំណងបង្កើន សហប្រតិបត្តិការនៅក្នុងវិស័យសេដ្ឋកិច្ច, សង្គម, បច្ចេកទេស, អប់រំ និងវិស័យផ្សេងៗទៀតនៅក្នុង តំបន់។ ជាមួយគ្នានេះដែរ សមាហរណកម្មនេះក៏មានគោលបំណងក្នុងការពង្រឹងសុខសន្តិភាព និង

ស្ថេរភាពនៅក្នុងតំបន់តាមរយៈការគោរពគ្នាទៅវិញទៅមកនូវគោលការណ៍យុត្តិធម៌ និងនីតិរដ្ឋ ក៏ដូចជាគោលការណ៍សន្តិភាពផ្សេងទៀតផងដែរ។ ដើម្បីធានាឲ្យបាននូវសុខសុវត្ថិភាព ស្ថេរភាព និងការអភិវឌ្ឍន៍នៅក្នុងតំបន់ សមាជិកនៅក្នុងក្របខណ្ឌអាស៊ានបានមូលមតិគ្នា និងបានចុះសន្ធិសញ្ញាជាបន្តបន្ទាប់គ្នាជាច្រើនដូចជា៖ សេចក្តីប្រកាសបង្កើតជាតំបន់សន្តិភាព, សេរីភាព និងអព្យាក្រឹត្យភាព (Declaration on the Zone of Peace, Freedom, and Neutrality (ZOPFAN) ឆ្នាំ1971), សន្ធិសញ្ញាមិត្តភាព និងសហប្រតិបត្តិការនៅអាស៊ីអាគ្នេយ៍ (Treaty of Amity and Cooperation in Southeast Asia (TAC) ឆ្នាំ1976), សន្ធិសញ្ញាអាស៊ីអាគ្នេយ៍គ្មានអាវុធនុយក្លេអ៊ែរ (Treaty on the Southeast Asia Nuclear Weapon-Free Zone (SEANWFZ) ឆ្នាំ១៩៩៥) និងការបង្កើតជាវេទិកាតំបន់អាស៊ាន (ASEAN Regional Forum ឆ្នាំ១៩៩៤) ដើម្បីជម្រុញឲ្យមានសហប្រតិបត្តិការស៊ីជម្រៅនៅក្នុងតំបន់ទៀតផង។ បើនិយាយដាច់ដោយឡែកទៅលើផ្នែកសេដ្ឋកិច្ចវិញ គួរឲ្យកត់សម្គាល់អាស៊ានបានបង្កើតឡើងនូវតំបន់ពាណិជ្ជកម្មសេរីអាស៊ានមួយ (ASEAN Free Trade Area ឬ AFTA) នៅឆ្នាំ១៩៩២ ក្នុងគោលបំណងជម្រុញឲ្យមានការអភិវឌ្ឍន៍សេដ្ឋកិច្ច និងជម្រុញពាណិជ្ជកម្មសេរីនៅក្នុងតំបន់តាមរយៈការទម្លាក់ និងលុបបំបាត់របាំងពាណិជ្ជកម្មរវាងប្រទេសដែលជាសមាជិក។ តាមរយៈតំបន់ពាណិជ្ជកម្មសេរីអាស៊ាននេះ សហគមន៍អាស៊ានមានគោលបំណងចង់បង្កើតឡើងនូវសមាហរណកម្មសេដ្ឋកិច្ចដ៏ស៊ីជម្រៅមួយដែលមានសាមគ្គីភាពរវាងប្រទេសសមាជិក។ ដើម្បីជាជំនួយក្នុងការសម្រេចបាននូវគោលបំណងដ៏ធំនេះ អាស៊ានបានដាក់ចេញនូវយន្តការសេដ្ឋកិច្ចពិសេសៗមួយចំនួនដូចជា៖ កិច្ចព្រមព្រៀងពាណិជ្ជកម្មទំនិញអាស៊ាន(ASEAN Trade in Goods Agreement ឬ ATIGA), កិច្ចព្រមព្រៀងវិនិយោគទូលំទូលាយរបស់អាស៊ាន (ASEAN Comprehensive Investment Agreement ឬ ACIA), និង កិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ានស្តីពីសេវាកម្ម (ASEAN Framework Agreement on Services ឬ AFAS) ជាដើម។ បន្ថែមពីលើកិច្ចព្រមព្រៀងសេដ្ឋកិច្ចក្នុងតំបន់ អាស៊ានបានបង្កើតនូវដៃគូសហប្រតិបត្តិការសេដ្ឋកិច្ច ដែលត្រូវបានគេស្គាល់ថាជាដៃគូសន្ទនា ឬ ASEAN + ដែលក្នុងនោះមាន៖

- ASEAN +1៖ អាស៊ាន-អូស្ត្រាលី, អាស៊ាន-ចិន, អាស៊ាន-កាណាដា, អាស៊ាន-ឥណ្ឌា, អាស៊ាន-ជប៉ុន, អាស៊ាន-សាធារណរដ្ឋកូរ៉េ, អាស៊ាន-ញូវហ្សេឡែន, អាស៊ាន-រុស្ស៊ី, អាស៊ាន-អាមេរិក, និងអាស៊ាន-សហភាពអឺរ៉ុប ឬអាស៊ាន-អង្គការសហប្រជាជាតិ
- ASEAN +3៖ អាស៊ាន ជាមួយនឹង ចិន, ជប៉ុន, និងសាធារណៈរដ្ឋកូរ៉េ
- East Asia Summit៖ អាស៊ាន ជាមួយនឹងដៃគូសន្ទនាទាំង ១០ក្នុងពេលតែមួយ។

គួរឲ្យចាប់អារម្មណ៍ដែរនោះ អាស៊ានដែលជាសមាហរណកម្មសេដ្ឋកិច្ចមិនសូវទទួលបានការទទួលបានការចាប់អារម្មណ៍កាលពីពេលកើតដំបូង ពោលគឺអំឡុងទសវត្សទី ៧០នោះ បានវិវត្តខ្លួន និងសមត្ថភាពបន្តិចម្តងៗរហូតក្លាយជាសមាហរណកម្មសំខាន់មួយដែលប្រទេសលើពិភពលោកមិនអាចមើលរំលង។ ក្រោយពីការបង្កើតឡើងនៅឆ្នាំ ១៩៦៧ សហគមន៍នេះហាក់ដូចជាមិនមានសកម្មភាពពង្រីកខ្លួន ជាលទ្ធផលដុំកំភួនគួរឲ្យកត់សម្គាល់នោះទេ គេត្រូវរងចាំរហូតដល់អំឡុងឆ្នាំ ១៩៨០ និង១៩៩០ ពោលគឺក្រោយពេលសង្គ្រាមត្រជាក់ត្រូវបានបញ្ចប់ទើបគេឃើញមានការទទួលយកនូវសមាជិកថ្មីនៅក្នុងតំបន់រួមមាន ប្រទេសប្រ៊ុយនេ, វៀតណាម, មីយ៉ាន់ម៉ា, ឡាវ, និងកម្ពុជា ដែលធ្វើឲ្យសមាហរណកម្មក្នុងតំបន់នេះកាន់តែមានសក្តានុពលទាំងនៅក្នុងតំបន់ និងក្នុងឆាកអន្តរជាតិ ដែលប្រែក្លាយអាស៊ីអាគ្នេយ៍ពីទីតាំងសមរភូមិទៅជាតំបន់សេដ្ឋកិច្ចដ៏មានសក្តានុពល។ ជាមួយនឹងទីផ្សារដ៏ធំដែលមានរហូតដល់ ១០ប្រទេស និងមានទំហំប្រជាសាស្ត្រដល់ទៅប្រមាណ ៧០០លាននាក់ វាអំណោយផលដល់ការវិវត្តន៍នៃសេដ្ឋកិច្ចក្នុងតំបន់នេះយ៉ាងខ្លាំង។ អាស៊ានបានក្លាយជាតំបន់ដែលមានការអភិវឌ្ឍន៍សេដ្ឋកិច្ចដ៏លឿនបំផុត និងជាតំបន់ដ៏សំខាន់នៃភូមិសាស្ត្រនយោបាយ និងសេដ្ឋកិច្ច ដែលមហាអំណាចក្នុងពិភពលោកមិនអាចមើលរំលង ហើយខិតខំប្រជែងគ្នាយកឥទ្ធិពលដើម្បីប្រយោជន៍សេដ្ឋកិច្ច និងនយោបាយការបរទេសរាងៗខ្លួនផងដែរ។ មិនត្រឹមតែប៉ុណ្ណោះ អាស៊ាននៅមានទស្សនៈវិស័យវែងឆ្ងាយដែលព្យាយាមពង្រួញគម្លាតសេដ្ឋកិច្ចរវាងសមាជិក និងអភិវឌ្ឍតំបន់នេះឲ្យមានចីរភាពសេដ្ឋកិច្ចទៀតផង។

ក្រាហ្វិកទី ២៖ រង្វាយតម្លៃអត្រាកំណើន GDP អាស៊ានធៀបនឹង GDP សរុបពិភពលោក(គិតជា%)




ប្រភពពីលេខាធិការដ្ឋាន អាស៊ាន

ក្រាហ្វិកទី ៣៖ រង្វាយតម្លៃកំណើន GDP ពិតរបស់ក្រុមប្រទេស កម្ពុជា ឡាវ មីយ៉ាន់ម៉ា វៀតណាម (គិតជា%)




ប្រភពពីលេខាធិការដ្ឋានអាស៊ាន

### ១.៣.៤. អង្គការពាណិជ្ជកម្មពិភពលោក

អង្គការពាណិជ្ជកម្មពិភពលោក (World Trade Organization ឬ WTO) គឺជាអង្គការពិភពលោកតែមួយគត់ដែលធ្វើការទាក់ទងទៅនឹងបទបញ្ញត្តិពាណិជ្ជកម្មរវាងប្រទេស និងប្រទេស(សម្តៅលើប្រទេសដែលជាសមាជិក)។[11] អង្គការពិភពលោកមួយនេះដើរតួជាបណ្តុំនៃប្រព័ន្ធនយោបាយសេដ្ឋកិច្ចអន្តរជាតិមួយដែលផ្តោតលើការចរចារ ប្រតិបត្តិការ និងត្រួតពិនិត្យឡើងវិញនូវគោលនយោបាយសេដ្ឋកិច្ចដោយប្រទេសដែលជាសមាជិកដើម្បីធ្វើអភិបាលកិច្ចទៅលើនយោបាយពាណិជ្ជកម្មរបស់ពួកគេឲ្យសមស្របទៅតាមនយោបាយសេដ្ឋកិច្ចសកល។ នៅក្នុងនោះ អង្គការពាណិជ្ជកម្មពិភពលោកមានគោលការណ៍ ២សំខាន់ៗគឺៈ ការធ្វើសេរីភាវូបនីយកម្មទីផ្សារ និងការមិនរើសអើង(សម្តៅទៅលើទំនិញ និងសេវាកម្មដែលក្នុងនោះត្រូវបានចែកចេញជា ២ទៀតគឺ គោលការណ៍ក្រុមប្រទេសដែលត្រូវបានអនុគ្រោះ[12] និងគោលការណ៍ការគាំពារជាតិ[13])។ ដោយមាន GATT ជាគម្រូ WTO នៅតែព្យាយាមពង្រីកវិសាលភាពនៃការលុបបំបាត់របាំងពន្ធ និងរបាំងមិនមែនពន្ធ ហើយថែមទាំងដើរតួយ៉ាងសំខាន់ជាអ្នកបង្កើតទំនុកចិត្តក្នុងការធ្វើពាណិជ្ជកម្មរវាងប្រទេស និងប្រទេស, ជាកន្លែងដែលរដ្ឋសមាជិកយកធ្វើជាតុចរចារ, និងជាអ្នកស្វែងរកយុត្តិធម៌នៅពេលមានបណ្តឹងពាណិជ្ជកម្មកើតឡើង។ មកដល់ក្នុងពេលបច្ចុប្បន្ន នៅក្នុងអង្គការពាណិជ្ជកម្មពិភពលោកនេះមានសមាជិកប្រមាណ ១៥៩ប្រទេស និងមាន ២៤ប្រទេសកំពុងចរចារស្នើសុំសមាជិកភាពជាសមាជិកក្នុងអង្គការនេះ។ គួរឲ្យកត់សម្គាល់ WTO បានឆ្លងកាត់នូវដំណាក់កាលចរចារសេដ្ឋកិច្ចដ៏យូរមួយគឺ វគ្គដូហា (DOHA Round) ដែលត្រូវបានសេដ្ឋវិទូជាច្រើនចាត់ទុកវគ្គនេះថាជាវគ្គដែលស្មុគស្មាញបំផុតមួយដែលស៊ីពេលអស់ទៅ ៥ឆ្នាំ(ចាប់ពីឆ្នាំ២០០១ ដល់២០០៦)។ នៅក្នុងវគ្គនេះ មានការខ្វែងមតិគ្នារវាងក្រុមប្រទេសជាសមាជិក(ក្រុមប្រទេសអភិវឌ្ឍន៍ និងក្រុមប្រទេសកំពុងអភិវឌ្ឍន៍) ក្នុងការបើកសេរីទីផ្សារលើផ្នែកឧស្សាហកម្ម និងកសិកម្ម ពោលគឺ ប្រទេសអភិវឌ្ឍន៍ទាមទារឲ្យមានការបើកយ៉ាងសេរីនូវទីផ្សារផលិតផលឧស្សាហកម្ម តែមិនព្រមបើកទីផ្សារកសិកម្ម រីឯប្រទេសកំពុងអភិវឌ្ឍន៍ទាមទារឲ្យមានការ

[11] ដកស្រង់ចេញពីគេហទំព័រអង្គការពាណិជ្ជកម្មពិភពលោក https://www.wto.org/english/thewto_e/whatis_e/whatis_e.htm

[12] ជាគោលការណ៍មួយដែលហាមរដ្ឋាភិបាលមិនឲ្យប្រើប្រាស់គោលនយោបាយពាណិជ្ជកម្មពិសេសណាមួយដើម្បីផ្តល់ផលប្រយោជន៍ឲ្យទៅប្រទេសណាមួយ ពោលគឺឲ្យរដ្ឋាភិបាលប្រើប្រាស់គោលនយោបាយពាណិជ្ជកម្មអព្យាក្រឹត្យទៅកាន់គ្រប់ប្រទេសទាំងអស់

[13] ជាគោលការណ៍ហាមមិនឲ្យរដ្ឋាភិបាលប្រើប្រាស់ប្រព័ន្ធពន្ធ, បទបញ្ញត្តិ និងគោលនយោបាយក្នុងស្រុកដើម្បីផ្តល់ផលប្រយោជន៍ដល់ក្រុមហ៊ុនក្នុងស្រុក ហើយរឹតត្បិតក្រុមហ៊ុនក្រៅស្រុក

បើកសេរីទីផ្សារផលិតផលកសិកម្ម តែមិនព្រមបើកទីផ្សារផលិតផលឧស្សាហកម្ម។ នេះវាបង្ហាញឲ្យឃើញពីបញ្ហានៅក្នុងសមាហរណកម្មសេដ្ឋកិច្ចនៅពេលដែលមានសមាជិកកាន់តែច្រើនផងដែរ។ យ៉ាងណាមិញ អង្គការពាណិជ្ជកម្មពិភពលោកនៅតែដើរតួនាទីជាអង្គការដ៏សំខាន់មួយដើម្បីឲ្យបណ្តាប្រទេសដែលជាសមាជិកធ្វើការចរចារគ្នា និងបង្កើតនូវគោលនយោបាយរួបរួមមួយដើម្បីដឹកនាំសេដ្ឋកិច្ចពិភពលោកឆ្ពោះទៅរកការអភិវឌ្ឍន៍ទាំងអស់គ្នា។

ក្រោយពីសមាហរណកម្ម ៩សំខាន់ៗដែលរៀបរាប់ខាងលើ នៅមានសមាហរណកម្មផ្សេងៗទៀតដូចជា៖

- តំបន់ពាណិជ្ជកម្មសេរីអាមេរិកខាងជើង(North American Free Trade Area ឬ NAFTA)៖ មាន៣ប្រទេសគឺ សហរដ្ឋអាមេរិក, ម៉ិចសិក្វ, និងកាណាដា ត្រូវបានគេបង្កើតឡើងនៅ ថ្ងៃទី០១ មករា ១៩៩៤។
- តំបន់ពាណិជ្ជកម្មសេរីអាព្រិក (African Free Trade Zone ឬ AFTZ)៖ មាន ២៦ប្រទេសនៅទ្វីបអាព្រិក ដែលត្រូវបានបង្កើតឡើងនៅឆ្នាំ ២០០៨ជាដើម។

ក្រាហ្វិកទី ៩៖ ទំហំពាណិជ្ជកម្មរបស់ប្រទេសនៅតាមតំបន់នានាក្នុងពិភពលោក (គិតជាពាន់លានដុល្លាអាមេរិក)




ប្រភពពីអង្គការពាណិជ្ជកម្មអន្តរជាតិ

# ២. ម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច

## ២.១. ម៉ាក្រូសេដ្ឋកិច្ច

នៅក្នុងការសិក្សាសេដ្ឋកិច្ច ក៏ដូចជានៅក្នុងប្រព័ន្ធគ្រប់គ្រងសេដ្ឋកិច្ចជាក់ស្តែង អ្នកសេដ្ឋកិច្ចនិយមបែងចែកប្រព័ន្ធសេដ្ឋកិច្ចជា ២ផ្នែកធំៗ គឺ៖ ម៉ាក្រូសេដ្ឋកិច្ច និងមីក្រូសេដ្ឋកិច្ច។ ជាមួយគ្នានេះដែរ គេអាចធ្វើការវែកញែកប្រព័ន្ធទាំង ២នេះ តាមរយៈការឲ្យនិយមន័យលើពាក្យទាំង ២ថា៖

- **ម៉ាក្រូសេដ្ឋកិច្ច** ជាការសិក្សាទៅលើឥរិយាបថ ឬចារឹកលក្ខណៈរបស់សេដ្ឋកិច្ចទាំងមូលរបស់ប្រទេស ឬតំបន់មួយ។[14]
- **មីក្រូសេដ្ឋកិច្ច** ជាការសិក្សាទៅលើឥរិយាបថ ឬចារឹកលក្ខណៈរបស់តួអង្គសេដ្ឋកិច្ចនីមួយៗនៅក្នុងសង្គមដែលមានដូចជា បុគ្គលម្នាក់ ឬសហគ្រាសមួយ។[15]

ម្យ៉ាងវិញទៀត បើនិយាយឲ្យស្រួលស្តាប់ ម៉ាក្រូសេដ្ឋកិច្ចសិក្សាពីបណ្តុំនៃតួអង្គសេដ្ឋកិច្ចទាំងអស់បញ្ចូលគ្នា។ ក្នុងនោះវាសិក្សាយ៉ាងលម្អិតទៅលើ ទំហំនៃទំនិញ ឬសេវាកម្មផលិតក្នុងស្រុកសរុប (ដែលហៅថា ផលិតផលក្នុងស្រុកសរុបដុល GDP), ប្រាក់ចំនូលសរុប, ភាពមានការងារធ្វើ, កម្រិតថ្លៃ, និងអតិផរណាជាដើម។ ជាមួយនឹងការសិក្សាទៅលើប្រធានបទតូចៗដែលបានរៀបរាប់ខាងលើហើយនោះ ម៉ាក្រូសេដ្ឋកិច្ចនឹងធ្វើការវិភាគទៅលើភាពខុសគ្នា និងទំនាក់ទំនងរបស់ប្រធានបទនីមួយៗទៅនឹងប្រព័ន្ធសេដ្ឋកិច្ចធំ និងស្វែងយល់ពីដំណើរការនៃប្រព័ន្ធសេដ្ឋកិច្ច។ ជាមួយគ្នានេះដែរ ដោយហេតុថាមានប្រធានបទតូចៗដែលសំខាន់ជាច្រើន(ដែលចាត់ទុកថាជាអថេរ)នៅក្នុងម៉ាក្រូសេដ្ឋកិច្ច ដូច្នេះហើយសេដ្ឋវិទូបានបង្កើតនូវគម្រូសេដ្ឋកិច្ចជាច្រើនដើម្បីសិក្សាពីទំនាក់ទំនងរបស់អថេរទាំងនោះ ព្រោះគេមិនអាចយកអថេរទាំងអស់មកសិក្សាក្នុងពេលតែមួយនោះទេ។ ដូចគ្នាដែរ នៅក្នុងការគ្រប់គ្រងសេដ្ឋកិច្ច និងការអភិវឌ្ឍន៍សេដ្ឋកិច្ចរបស់ប្រទេសមួយ អ្នកសេដ្ឋកិច្ចមិនអាចធ្វើការអភិវឌ្ឍន៍សេដ្ឋកិច្ចដោយជម្រុញគ្រប់វិស័យទាំងអស់ក្នុងពេលតែមួយនោះទេ គឺគេនិយមជ្រើសរើសយកវិស័យដែលមានសក្តានុពលក្នុងការអភិវឌ្ឍន៍យកទៅអភិវឌ្ឍមុនវិស័យផ្សេងៗទៀត ហើយគេនឹងអូសទាញនូវវិស័យដែលពាក់ព័ន្ធនឹងវិស័យសក្តានុពលនោះឲ្យមានកំណើនស្របពេលជាមួយគ្នា។ ហេតុដូច្នេះហើយ ជាលទ្ធផល ការជ្រើសរើសនូវគម្រូណាមួយយកមកប្រើប្រាស់វានឹងជះឥទ្ធិពលយ៉ាងខ្លាំងទៅលើគោលនយោបាយសេដ្ឋកិច្ច និងលទ្ធផលដែលនឹងទទួលបានបន្ទាប់ពីអនុវត្តនូវគម្រូ

[14] ដកស្រង់ចេញពីគេហទំព័រដែលមានអាស័យដ្ឋាន៖ https://www.britannica.com/topic/macroeconomics
[15] ដកស្រង់ចេញពីគេហទំព័រដែលមានអាស័យដ្ឋាន៖ https://www.britannica.com/topic/microeconomics

នោះ ពោលគឺ បើរដ្ឋាភិបាលជ្រើសរើសយកគម្រូមួយដែលមានវិស័យសក្តានុពលណាមួយវិស័យ និង អ្នកបម្រើការក្នុងវិស័យនោះនឹងទទួលបានផលចំនេញច្រើនជាងវិស័យផ្សេងទៀត។

| **ម៉ាក្រូសេដ្ឋកិច្ចសិក្សាពី៖** | **មីក្រូសេដ្ឋកិច្ចសិក្សាពី៖** |
|---|---|
| ទំនិញ ឬសេវាកម្មទាំងអស់ | ទំនិញ ឬសេវាកម្មណាមួយ |
| តួអង្គសេដ្ឋកិច្ចទាំងអស់ | តួអង្គសេដ្ឋកិច្ចមួយ |
| តម្រូវការ និងការផ្គត់ផ្គង់សរុប | តម្រូវការ និងការផ្គត់ផ្គង់របស់តួអង្គ |
| ថ្លៃរួម ឬកម្រិតថ្លៃ | ថ្លៃទំនិញ ឬសេវាកម្មមួយ |
| អត្រានិកម្មភាព | |
| អតិផរណា | |
| អត្រាប្តូរប្រាក់ | |
| អត្រាការប្រាក់ -ល- | |

### ២.១.១. ប្រវត្តិនៃប្រព័ន្ធម៉ាក្រូសេដ្ឋកិច្ចទំនើប

ប្រព័ន្ធម៉ាក្រូសេដ្ឋកិច្ចទំនើបត្រូវបានគេសន្មត់ថាបានចាប់បដិសន្ធិឡើងបន្ទាប់ពីមានការកើតឡើងនូវវិបត្តិ Great Depression[16] នៅសហរដ្ឋអាមេរិកក្នុងកំឡុងឆ្នាំ ១៩៣០។ គួររំលឹកផងដែរថា មុនពេលមានបញ្ហា Great Depression ទ្រឹស្តីសេដ្ឋកិច្ចក្លាសិកបានគ្របដណ្តប់នៅលើពិភពលោកយ៉ាងច្រើនទសវត្ស។ ក្នុងនោះទ្រឹស្តីក្លាសិកប្រើប្រាស់នូវបែបបទ Laissez-Faire និងមានគម្រូសេដ្ឋកិច្ច ៣ធំៗ។ គម្រូទីមួយរបស់ទ្រឹស្តីនេះនិយាយពីគម្រូតុល្យការនៃតម្រូវការ និងការផ្គត់ផ្គង់កម្លាំងពលកម្មដែលក្នុងនោះ ដោយមានការបកស្រាយគួបផ្សំនឹងបច្ចេកទេសនៃការផលិត ទ្រឹស្តីក្លាសិកបានពន្យល់យ៉ាងច្បាស់ពីបែបបទដែលកម្លាំងពលកម្មបានក្លាយជាធាតុចូល(Input)ក្នុងការបង្កើតឲ្យទៅជាទំនិញ ឬសេវាកម្មចុងក្រោយ។ គម្រូទីពីររបស់ទ្រឹស្តីនេះបកស្រាយពីការកំណត់ទៅលើទំនាក់ទំនងនៃកម្រិតថ្លៃ និងអត្រាការប្រាក់។ ទ្រឹស្តីនេះបានបកស្រាយថា ថ្លៃអាស្រ័យទៅលើការផ្គត់ផ្គត់បរិមាណរូបិយវត្ថុដែលចរាចរនៅក្នុងសេដ្ឋកិច្ច។ គម្រូទីបីរបស់ទ្រឹស្តីក្លាសិកធ្វើការកំណត់ទៅលើអត្រាការប្រាក់ ដែលតុល្យការអត្រាការប្រាក់គឺជាអត្រាដែលស្មើនឹងចំនួនលុយដែលអ្នកខ្ចីចង់ខ្ចី និងដែល

[16] Great Depression ជាវិបត្តិសេដ្ឋកិច្ច និងសង្គមមួយនៅក្នុងប្រទេសឧស្សាហកម្មលេចចេញពីសហរដ្ឋអាមេរិកមុនគេដែលបានកើតឡើងពីឆ្នាំ ១៩២៩ ដល់ ១៩៣៩។ មូលហេតុនៃវិបត្តិនេះបណ្តាលមកពីការកើនឡើងនូវការផ្គត់ផ្គង់លើសពីតម្រូវការ ដែលធ្វើឲ្យប្រជាជនអាមេរិកប្រមាណ ១៥លាននាក់បាត់បង់ការងារធ្វើ ហើយធនគារពាណិជ្ជជិតពាក់កណ្តាលនៅអាមេរិកក្ស័យធុន។

អ្នកផ្តល់កម្ចីព្រមផ្តល់ឲ្យ។ និយាយឲ្យខ្លីទៅទ្រឹស្តីសេដ្ឋកិច្ចក្លាសិកមានលំនឹងតុល្យការ ៣គឺ៖ លំនឹងនៃភាពមានការងារធ្វើ, លំនឹងនៃការចរាចររូបិយវត្ថុ, និងលំនឹងនៃកម្ចី ស្របពេលដែលទ្រឹស្តីក្លាសិកនេះ មិនបានចង្អុលបង្ហាញឲ្យលម្អិតពីទំនាក់ទំនាក់ពិតប្រាកដរវាងលំនឹងទាំង ៣នេះទេ។ ក្នុងនោះផងដែរមានការលើកឡើងជាគំនិតរិះគន់ពីភាពជាក់ស្តែងនៃទ្រឹស្តីក្លាសិក មួយចំនួនផងដែរ ដូចជា៖

- ផលិតផលដែលទទួលបានពីការផលិតអាចកើតឡើងដោយមានទំនាក់ទំនងនឹងការប្រែប្រួលនយោបាយពន្ធ មិនមែនទាក់ទងតែនឹងតម្រូវការ និងការផ្គត់ផ្គង់របស់ធាតុចូលនោះទេ។
- អតិផរណានឹងក្លាយជាបញ្ហាដ៏ធ្ងន់ធ្ងរនៅពេលដែលមានការកើនឡើងខ្លាំងនូវការផ្គត់ផ្គង់លុយ។
- ការចំនាយរបស់រដ្ឋច្រើនជ្រុលនឹងបង្កឲ្យមានការកើនឡើងខ្ពស់នូវអត្រាការប្រាក់ដែលជះឥទ្ធិពលដល់វិស័យឯកជន។

ក្នុងអំឡុងពេលនៃវិបត្តិ Great Depression នេះ សេដ្ឋវិទូអង់គ្លេសម្នាក់ គឺលោក John Maynard Keynes បានបោះពុម្ពផ្សាយសៀវភៅមួយក្បាលដែលមានឈ្មោះថា «The General Theory of Employment, Interest and Money» ប្រែថា «ទ្រឹស្តីបទទូទៅនៃភាពមានការងារធ្វើ ការប្រាក់ និងរូបិយវត្ថុ» នៅឆ្នាំ១៩៣៦ ដែលក្នុងនោះលោកបានពន្យល់បកស្រាយពីវិបត្តិ Great Depression តាមបែបបទថ្មីមួយដែលស្តែងឲ្យឃើញពីបញ្ហា និងភាពទន់ខ្សោយរបស់ទ្រឹស្តីសេដ្ឋកិច្ចបែបក្លាសិក (ជាទ្រឹស្តីដែលរដ្ឋាភិបាលអាមេរិកប្រើប្រាស់នៅពេលនោះ) ស្របពេលដែលសេដ្ឋវិទូក្លាសិកយល់ឃើញថាវាគ្រាន់តែជា Business Cycle មួយដែលនឹងធូរស្រាលក្នុងពេលឆាប់ៗ ដែលនេះផ្ទុយពីភាពពិតជាក់ស្តែងក្នុងពេលដែលប្រជាជនអាមេរិកជាច្រើនលានអ្នកកំពុងអត់ការងារធ្វើ ទំនិញលក់មិនចេញហើយវិបត្តិនេះចេះតែអូសបន្លាយពេល។ លោក Keynes យល់ឃើញថាវិបត្តិនាពេលនោះកើតឡើងមកពីការប្រើប្រាស់បែបបទ Laissez-Faire ជ្រុះពេក។ លោកបានអះអាងថា កម្មវិធីបង្កើតឱកាសការងារមួយដែលបង្កើតដោយរដ្ឋនឹងកាត់បន្ថយភាពអត់ការងារធ្វើ ទោះបីជាវាបង្កើតឲ្យមានឱនភាពថវិកាជាតិយ៉ាងណាក្តី។ ការអះអាងនេះបានក្លាយទៅជាដំណោះស្រាយមួយកម្រិតទៅលើវិបត្តិឆ្នាំ ១៩៣០។ ត្រង់នេះ វាបានក្លាយទៅជាទ្រឹស្តីសេដ្ឋកិច្ចថ្មីមួយនៃប្រព័ន្ធម៉ាក្រូសេដ្ឋកិច្ចដែលត្រូវបានគេដាក់ឈ្មោះថា ទ្រឹស្តី Keynesian ហើយបន្ទាប់មក បែបបទសេដ្ឋកិច្ចដែលអនុញ្ញាតិឲ្យរដ្ឋលូកដៃចូលទៅក្នុងទីផ្សារក្នុងកម្រិតជាក់លាក់មួយ ដើម្បីទប់ស្កាត់បញ្ហាសេដ្ឋកិច្ចត្រូវបានប្រទេសជាច្រើនអនុវត្តតាមរហូតមកដល់សព្វថ្ងៃ។

### ២.១.២. បញ្ហាដែលត្រូវដោះស្រាយក្នុងម៉ាក្រូសេដ្ឋកិច្ច

ទោះបីជាមានប្រធានបទតូចៗ និងសំខាន់ជាច្រើននៅក្នុងម៉ាក្រូសេដ្ឋកិច្ចក៏ដោយក្តី ប៉ុន្តែ គេសង្កេតឃើញថាសេដ្ឋវិទូបានជ្រើសយកប្រធានបទមួយចំនួនធ្វើជាប្រធានបទគោលក្នុងការដោះស្រាយដែលមានដូចជា៖

- កំណើនសេដ្ឋកិច្ច៖ ជាការកើនឡើងនៃទំហំទំនិញ ឬសេវាកម្មដែលសេដ្ឋកិច្ចបានបង្កើតឡើងដោយធៀបនឹងរយៈពេលច្បាស់លាស់ណាមួយ។ គេអាចវាស់កំណើនសេដ្ឋកិច្ចបានតាមរយៈការប្រៀបធៀប Nominal GDP ឬReal GDP
- វដ្តសេដ្ឋកិច្ច៖ គឺជាការឡើងចុះនៃសេដ្ឋកិច្ច។ វាបង្ហាញពីការឡើង ឬចុះនៃផលិតផលសរុបរបស់ GDP ដែលត្រូវបានគេបែងចែកជា ២ដំណាក់កាលសំខាន់ៗគឺ៖ ដំណាក់កាលឡើង (ឡើងពីចំណុចមួយទៅចំណុចអតិបរមានៃGDP) និងដំណាក់កាលធ្លាក់ចុះ(ចុះពីចំណុចអតិបរមាទៅកាន់ចំណុចអប្បបរមានៃGDP)។
- ភាពគ្មានការងារធ្វើ ឬនិកម្មភាពការងារ៖ ជាបាតុភូតដែលកម្លាំងពលកម្មដែលមានសមត្ថភាពបំពេញការងារទទួលបានប្រាក់ឈ្នួលស្មើនឹងអ្នកដែលគ្មានការងារ ឬអាចនិយាយបានដោយសាមញ្ញថា គ្មានការងារធ្វើ។ និកម្មភាពការងារនេះ ឆ្លុះបញ្ចាំងយ៉ាងពេញទំហឹងទៅលើសុខុមាលភាពរបស់សេដ្ឋកិច្ច ប្រជាជន ក៏ដូចជាសង្គមទាំងមូលតែម្តង ព្រោះថាអត្រានិកម្មភាពការងារខ្ពស់នឹងបង្ហាញពីភាពអវិជ្ជមាននៃការអភិវឌ្ឍន៍សេដ្ឋកិច្ចដែលធ្វើឲ្យប្រជាជនគ្មានការងារធ្វើ និងបង្កើតជាវិបត្តិសង្គមជាច្រើនដូចជា៖ ចោរកម្ម និងភាពក្រីក្រជាដើម។ និកម្មភាពការងារនេះត្រូវបានគេបែងចែកជា ៣ធំៗគឺ៖
    - និកម្មភាពបណ្តោះអាសន្ន (Frictional Unemployment)៖ កើតឡើងពីការចេញចូល ឬផ្លាស់ប្តូរការងារនៅក្នុងទីផ្សារការងាររបស់កម្លាំងពលកម្ម ដែលវានឹងមិនជះឥទ្ធិពលខ្លាំងដល់បញ្ហាសេដ្ឋកិច្ចនោះទេ។
    - និកម្មភាពជាប្រព័ន្ធ (Structural Unemployment)៖ កើតឡើងពីការប្រែប្រួលទីផ្សារការងារដែលមានការកើនឡើងនូវបច្ចេកវិទ្យាខ្លាំង និងការប្រកួតប្រជែងអន្តរជាតិ។ ការប្រកួតប្រជែងអន្តរជាតិអាចបណ្តាលឲ្យក្រុមហ៊ុន ឬសហគ្រាសមួយចំនួនមានបញ្ហារហូតដល់ក្ស័យធុន ដែលធ្វើឲ្យកម្មកររបស់ខ្លួនបាត់បង់ការងារ និងប្រាក់ចំនូល។

- និកម្មភាពខួប (Cyclical Unemployment)៖ កើតពីការប្រែប្រួល ឬការធ្លាក់ចុះនៃសេដ្ឋកិច្ចរបស់ប្រទេសទាំងមូលដែលធ្វើឲ្យកម្លាំងពលកម្មបាត់បង់ការងារក្នុងរយៈពេលវែង និងបង្កើតជាវិបត្តិសង្គមដ៏ធ្ងន់ធ្ងរ។

- អតិផរណា៖ ជាការធ្លាក់ចុះនូវតម្លៃនៃរូបិយវត្ថុ ឬការកើនឡើងនៃថ្លៃ ដែលគេរមែងដឹងតាមរយៈការកើនឡើងនូវថ្លៃទំនិញ និងសេវាកម្មផ្សេងៗ។
- អត្រាការប្រាក់៖ ជាអត្រាក្នុងកម្រិតណាមួយដែលធនាគារគិតថ្លៃជាថ្នូរនៃការផ្តល់កម្ចី។ វាមានឥទ្ធិពលក្នុងការចរាចរលុយនៅក្នុងសេដ្ឋកិច្ច ក៏ដូចជាឥទ្ធិពលទៅលើការសម្រេចចិត្តរបស់អ្នកជំនួញក្នុងវិស័យឯកជនផងដែរ ព្រោះថាបើអត្រាការប្រាក់មានការកើនឡើងខ្ពស់ នោះអ្នកវិនិយោគនឹងមានការរារែកក្នុងការខ្ចីប្រាក់ដើម្បីមកពង្រីកអាជីវកម្មរបស់ខ្លួនដែលវានឹងធ្វើឲ្យបរិមាណផលិតផលសរុបទាំងអស់ក្នុងសេដ្ឋកិច្ចនៅនឹងថ្កល់ជាលក្ខណៈម៉ាក្រូ។

**២.១.៣. សារៈសំខាន់នៃម៉ាក្រូសេដ្ឋកិច្ច**

- វាធ្វើឲ្យយើងយល់ច្បាស់ពីដំណើរការវិវត្តន៍នៃសេដ្ឋកិច្ចនៅក្នុងប្រព័ន្ធសេដ្ឋកិច្ចដ៏ស្មុគស្មាញដូចក្នុងពេលបច្ចុប្បន្ននេះដោយមានជំនួយពីសុចនាករមួយចំនួនដូចជាចំនូលជាតិសរុប, អត្រានិកម្មភាព, តម្រូវការនិងការផ្គត់ផ្គង់សរុបជាដើម។
- វានឹងជួយឲ្យអ្នកសេដ្ឋកិច្ចសម្រេចបាននូវគោលដៅនៃការអភិវឌ្ឍន៍សេដ្ឋកិច្ចដូចដែលបានគ្រោងទុក។
- វាចូលរួមក្នុងការវិភាគរកកម្លាំងចលករ កត្តា ឬវិស័យដែលមានសក្តានុពលដែលចូលរួមក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ច។ ហើយវាក៏អាចវិភាគឲ្យដឹងពីបញ្ហា ឬវិបត្តិដែលសេដ្ឋកិច្ចនឹងប្រឈមនាពេលខាងមុខផងដែរ។
- តាមរយៈការអនុវត្តគម្រូសេដ្ឋកិច្ចមួយច្បាស់លាស់ វានឹងនាំមកនូវស្ថេរភាពថ្លៃ និងអាចវិភាគពីការឡើងចុះនៃសកម្មភាពសេដ្ឋកិច្ច។
- វាចូលរួមចំណែកក្នុងការបង្កើតនូវយន្តការដែលអាចវាស់វែង ឬគ្រប់គ្រងអតិផរណាក្នុងកម្រិតមួយដែលអាចទទួលយកបាន។
- វានឹងពន្យល់ឲ្យយើងដឹងច្បាស់ពីកត្តាដែលប៉ះពាល់ដល់តុល្យការនៃការចំនាយរបស់រដ្ឋ ក៏ដូចជាកំណត់នូវកត្តាដែលធ្វើឲ្យមានឱនភាពថវិកាជាតិផងដែរ។
- វាជួយដោះស្រាយបញ្ហាសេដ្ឋកិច្ចផ្សេងៗ ជាលក្ខណៈម៉ាក្រូដូចជា៖ ភាពក្រីក្រ, និកម្មភាពការងារ, អតិផរណា, បរិផរណាជាដើម។

- វានឹងចូលរួមក្នុងការបង្កើតជាគោលនយោបាយសេដ្ឋកិច្ចដ៏ត្រឹមត្រូវ និងអាចបន្សីទៅនឹងគោលនយោបាយសេដ្ឋកិច្ចពិភពលោកទៀតផង។

## ២.២. គោលនយោបាយម៉ាក្រូសេដ្ឋកិច្ច

ដូចដែលបានរាប់រៀបពីខាងលើ មានប្រធានបទតូចៗ និងសំខាន់ជាច្រើនដែលត្រូវដោះស្រាយនៅក្នុងម៉ាក្រូសេដ្ឋកិច្ច ហេតុដូចនេះ វាទាមទារឲ្យមានគោលនយោបាយដ៏ត្រឹមត្រូវដើម្បីធ្វើការដឹកនាំ អនុវត្ត និងត្រួតពិនិត្យមើលនូវប្រព័ន្ធម៉ាក្រូសេដ្ឋកិច្ចឲ្យបានល្អ។ គោលនយោបាយម៉ាក្រូសេដ្ឋកិច្ចមានគោលបំណងសំខាន់ៗ ៥គឺ៖

- ភាពមានការងារធ្វើពេញលេញ (Full Employment)
- ស្ថេរភាពថ្លៃ (Price Stability)
- កំណើនសេដ្ឋកិច្ច (Economic Growth)
- តុល្យការនៃការចំណាយ និងស្ថេរភាពអត្រាប្តូរប្រាក់ (Balance of Payment and Exchange rate Stability)
- វត្ថុបំណងសង្គម ឬសុខុមាលភាពសង្គម(Social Objectives)។

នៅក្នុងប្រព័ន្ធម៉ាក្រូសេដ្ឋកិច្ចសម័យទំនើប អ្នកសេដ្ឋកិច្ចរមែងធ្វើការបង្កើត និងបែងចែកគោលនយោបាយសេដ្ឋកិច្ចជា ២ធំៗគឺ គោលនយោបាយហិរញ្ញវត្ថុ និងគោលនយោបាយសារពើពន្ធ។ យ៉ាងណាមិញ យើងគប្បីយល់ពីពាក្យគន្លឹះសំខាន់ៗ ២ គឺ៖ នយោបាយ និងគោលនយោបាយ។

តាមរយៈវចនានុក្រមសម្តេចជួន ណាត នយោបាយ(Politic) មានន័យថាជាឧបាយក្នុងការណែនាំ, កលល្បិច ឬមេគំនិតដែលគេផ្តើមឡើង ដើម្បីដឹកនាំជនដទៃឲ្យប្រព្រឹត្តទៅរកទីដៅយ៉ាងនេះ ឬយ៉ាងនោះ។ នយោបាយចង់សម្តៅទៅលើទ្រឹស្តីបង្គោលដែលដឹកនាំស្ថាប័នមួយ ឬការអនុវត្តន៍របស់រដ្ឋាភិបាល អ្នកនយោបាយ រឺគណៈបក្ស។ វាបង្ហាញពីលក្ខណៈនៃប្រព័ន្ធក្បាលម៉ាស៊ីនដឹកនាំជាន់ខ្ពស់ថាដើរតាមប្រព័ន្ធមួយណា។

គោលនយោបាយ(Policy)៖ ចង់សម្តៅទៅលើ របៀប ឬវិធីដែលត្រូវបានគេប្រើប្រាស់ដើម្បីសម្រេចឲ្យបានគោលដៅដែលបានកំណត់ទុក។ និយាយឲ្យស្រួលស្តាប់គឺវាបង្ហាញពីផែនការក្នុងការដឹកនាំដើម្បីសម្រេចគោលដៅ។[17]

[17] ដកស្រង់ចេញពីគេហទំព័រដែលមានអាស័យដ្ឋាន៖ https://dictionary.cambridge.org/grammar/british-grammar/politics-political-politician-or-policy

### ២.២.១. គោលនយោបាយហិរញ្ញវត្ថុ

គោលនយោបាយហិរញ្ញវត្ថុ ជាគោលនយោបាយសេដ្ឋកិច្ចទាំងឡាយណាដែលធ្វើឲ្យមានការប្រែប្រួលចំនួនលុយដែលចរាចរណ៍នៅក្នុងសេដ្ឋកិច្ច។ គោលនយោបាយហិរញ្ញវត្ថុធ្វើឲ្យមានការប្រែប្រួលអត្រាការប្រាក់ អត្រាប្តូរប្រាក់ រួមនឹងការផ្គត់ផ្គង់ និងតម្រូវការលុយនៅក្នុងសេដ្ឋកិច្ចផងដែរ។ ជាមួយគ្នានេះដែរ គោលនយោបាយនេះត្រូវបានអនុវត្ត និងត្រួតពិនិត្យតាមដានដោយធនាគារជាតិរបស់រដ្ឋ ដោយមានស្ថាប័នអន្តរការីហិរញ្ញវត្ថុ(មានដូចជាធនាគារពាណិជ្ជ, សមាគមន៍សន្សំ និងកម្ចី, ធនាគារសន្សំ, Credit Union, Money Market Mutual Fund, និង ស្ថាប័នហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើ) ដែលដើរតួជាសារៈជួយសម្រួលក្នុងការចរាចរលុយរបស់តួអង្គសេដ្ឋកិច្ចក្នុងសង្គមពីមួយទៅមួយ។

នៅក្នុងប្រទេសនីមួយៗ គេមិននិយមក្នុងការបោះពុម្ពលុយថ្មីច្រើនដើម្បីទូទាត់នៅក្នុងសេដ្ឋកិច្ចនោះទេ ព្រោះវានឹងបណ្តាលឲ្យទៅជាអតិផរណាខ្ពស់នៅក្នុងសេដ្ឋកិច្ចនោះ ផ្ទុយទៅវិញគេនិយមបង្កើតលុយបន្ថែមពីលើលុយដែលមានចរាចរស្រាប់ក្នុងសេដ្ឋកិច្ច។ ក្នុងករណីនេះ អ្នកសេដ្ឋកិច្ចប្រើប្រាស់ឧបករណ៍ ៣សំខាន់ៗគឺៈ

១. អត្រាទុនបម្រុងកាតព្វកិច្ច(Required Reserve Ration)៖ ជាអត្រានៃប្រាក់តម្កល់ដែលត្រូវបានរក្សាទុករបស់គណនីបញ្ញើ និងមិនឲ្យធនាគារពាណិជ្ជយកប្រាក់តម្កល់នេះផ្តល់ជាកម្ចីនោះទេ។ អត្រានេះត្រូវបានកំណត់ដោយធនាគារកណ្តាលរបស់រដ្ឋ។

២. ការបញ្ចុះអត្រាការប្រាក់របស់ធនាគារកណ្តាល(Discount Rate)៖ ជាអត្រាការប្រាក់ដែលធានាគារកណ្តាលយល់ព្រមផ្តល់កម្ចីឲ្យទៅធនាគារពាណិជ្ជនៅពេលដែលធនាគារពាណិជ្ជខ្វះទុនក្នុងការបង្វិល។

៣. ប្រតិបត្តិការទីផ្សារបើក(Open Market Operation)៖ សម្តៅទៅលើធនាគារកណ្តាលទិញមូលប័ត្រ ឬប័ណ្ណបំណុលពីធនាគារពាណិជ្ជ ឬសាធារណជន។

### ២.២.២. គោលនយោបាយសារពើពន្ធ

គោលនយោបាយសារពើពន្ធជាគោលនយោបាយដែលរដ្ឋប្រើប្រាស់ដើម្បីធ្វើឲ្យមានការប្រែប្រួលចំនាយ និងចំនូលរបស់រដ្ឋ។ តាមរយៈគោលនយោបាយនេះ រដ្ឋធ្វើការប្រែប្រួលការចំនាយ និងអត្រាប្រមូលពន្ធ ដើម្បីត្រួតពិនិត្យ កែសម្រួល និងមានឥទ្ធិពលទៅលើសេដ្ឋកិច្ចជាតិដើម្បីជៀសវាងវិបត្តិសេដ្ឋកិច្ច។ គោលនយោបាយសារពើពន្ធនេះមានប្រភពចេញមកពីទ្រឹស្តីសេដ្ឋកិច្ច Keynesian ដែលក្នុងនោះលោក Keyne បានអះអាងថា រដ្ឋាភិបាលអាចមានឥទ្ធិពលទៅលើកម្រិតផលិតភាព

របស់ម៉ាក្រូសេដ្ឋកិច្ចតាមរយៈការបង្កើន ឬបន្ថយអត្រាពន្ធ និងចំណាយសាធារណៈ។[18] ក្នុងនោះ គោលនយោបាយសារពើពន្ធនេះទាមទារឲ្យប្រើប្រាស់ថវិកាជាតិ ដោយមានការអនុម័តយល់ព្រមពីសំណាក់សភាដំណាងរាស្ត្រ ឬសភាជាន់ខ្ពស់ទៅតាមបែបបទនៃប្រទេសផ្សេងគ្នា ព្រោះរដ្ឋជាតួអង្គសេដ្ឋកិច្ចដ៏មានឥទ្ធិពលមួយនៅក្នុងប្រព័ន្ធសេដ្ឋកិច្ច។ ប្រហាក់ប្រហែលទៅនឹងតួអង្គដទៃទៀតដែរ រដ្ឋជាអ្នកផលិតនូវសេវាកម្មសាធារណៈ ហើយរដ្ឋក៏មានតម្រូវការប្រើប្រាស់ផលិតផល និងសេវាកម្មនានាដែលមានដើម្បីផលិតឲ្យបាននូវសេវាកម្មសាធារណៈដើម្បីបំពេញចិត្តប្រជាពលរដ្ឋ។ ដូច្នេះរដ្ឋចាំបាច់ត្រូវមានកញ្ចប់ថវិកាជាតិក្នុងដៃដើម្បីបង្កើតនូវគោលនយោបាយថាតើគួរចំណាយទៅលើវិស័យអ្វី និងចំណាយដោយរបៀបណាដើម្បីឲ្យមានប្រសិទ្ធិភាព។ ជាមួយគ្នានេះដែរ រដ្ឋអាចបង្កើនកម្រិតផលិតផល ឬGDP បានតាមរយៈការកាត់បន្ថយអត្រាពន្ធដែលជាកាតព្វកិច្ចរបស់ពលរដ្ឋ ព្រោះនៅពេលកាត់បន្ថយអត្រាពន្ធ ពលរដ្ឋអាចមានលុយដើម្បីចំណាយទៅលើតម្រូវការបន្ថែមរបស់ខ្លួន ដែលវាធ្វើឲ្យមានការប្រែប្រួលនូវតម្រូវការនិងការផ្គត់ផ្គង់សរុប។ ក្នុងករណីនេះនយោបាយសារពើពន្ធនេះជះឥទ្ធិពលយ៉ាងខ្លាំងទៅលើGDPសរុបរបស់ប្រទេស។ យ៉ាងណាមិញ គោលនយោបាយសារពើពន្ធនេះត្រូវបានសេដ្ឋវិទូអះអាងថា វាមានឥទ្ធិពលទៅលើពលរដ្ឋដែលមានប្រាក់ចំណូលកម្រិតមធ្យមជាងអ្នកដែលមានប្រាក់ចំណូលទាប និងអ្នកមានប្រាក់ចំណូលខ្ពស់ ព្រោះបើយើងគិតពីការប្រែប្រួលអត្រាពន្ធ អ្នកដែលមានទំនោរក្នុងការប្រែប្រួលការចំណាយនៅពេលមានការប្រែប្រួលអត្រាពន្ធនេះគឺ អ្នកដែលមានប្រាក់ចំណូលមធ្យមព្រោះពួកគាត់ជាប់កាតព្វកិច្ចពន្ធ ហើយអ្នកដែលមានប្រាក់ចំណូលទាប ភាគច្រើនមិនជាប់កាតព្វកិច្ចពន្ធនោះទេ រីឯអ្នកដែលមានប្រាក់ចំណូលខ្ពស់ មិនសូវជាមានការប្រែប្រួលការចំនាយពេលកាត់បន្ថយពន្ធនោះទេព្រោះពួកគេមានលទ្ធភាពក្នុងការចំណាយលើតម្រូវការពួកគេរួចមកហើយ។ ជាមួយគ្នានេះ គោលនយោបាយសារពើពន្ធមានវត្ថុបំណង ៣សំខាន់ៗគឺ៖

- ភាពមានការងារធ្វើពេញលេញ (Full Employment)
- ចីរភាពកំណើនសេដ្ឋកិច្ចក្នុងរយៈពេលវែង
- ស្ថេរភាពកម្រិតថ្លៃ។

ជាមួយគ្នានេះដែរ បើតាមទស្សនៈរបស់លោកបណ្ឌិត ហុង ជួន ណារ៉ុន ទិសដៅគោលនយោបាយសារពើពន្ធត្រូវបានបែងចែកជា ២គឺ៖ ក្នុងរយៈពេលមធ្យម និងក្នុងរយៈពេលវែង។ ទិសដៅ

[18] ដកស្រង់ចេញពីគេហទំព័រដែលមានអាស័យដ្ឋាន៖ https://www.investopedia.com/insights/what-is-fiscal-policy/

រយៈពេលមធ្យម គឺដើម្បីពង្រឹងការប្រមូលចំណូល និងតម្រង់ទិសចំណាយ ដើម្បីឆ្លើយតបនឹងអាទិភាព ចំណាយសម្រាប់កាត់បន្ថយភាពក្រីក្រ។ រីឯទិសដៅរយៈពេលវែងនៃគោលនយោបាយសារពើពន្ធ គឺដើម្បីធានាកម្រិតចំណាយឲ្យមានសង្គតិភាពជាមួយនឹងស្ថេរភាពម៉ាក្រូសេដ្ឋកិច្ច ដើម្បីរក្សាឲ្យបាន នូវសារពើពន្ធដែលមានចីរភាពមួយ មានតុល្យភាពគ្នាទៅនឹងកំណើនជាលំដាប់ ក្នុងការបែងចែក ថវិកាសម្រាប់វិស័យសង្គម និងសេដ្ឋកិច្ច តាមរយៈការធ្វើវិចារណកម្មចំណាយសាធារណៈ និងពង្រីក មូលដ្ឋានយកពន្ធ បង្ការការធ្លុះធ្លាយ និងពង្រឹងរដ្ឋបាលគយ និងពន្ធដារដើម្បីប្រមូលចំណូលបន្ថែម[19]។

❖ គោលនយោបាយសារពើពន្ធបែងចែកជា ២គឺ៖

- គោលនយោបាយពង្រីកសារពើពន្ធ(Expansionary Fiscal Policy)៖ ការបង្កើនចំណាយរបស់រដ្ឋ ឬការកាត់បន្ថយអត្រាពន្ធ វាបានធ្វើឲ្យគោលនយោបាយសារពើពន្ធពង្រីកខ្លួនបានយ៉ាងល្អ។ ជាពិសេសក្នុងពេលដែលវិបត្តិសេដ្ឋកិច្ចធ្លាក់ចុះ ការធ្វើបែបនេះវាអាចអូសទាញសេដ្ឋកិច្ចឲ្យមានការងើបឡើង ឬអាចធ្វើឲ្យវិបត្តិសេដ្ឋកិច្ចមានភាពធូរស្រាលមួយកម្រិត។
- គោលនយោបាយរឹតត្បិតសារពើពន្ធ(Contractionary Fiscal Policy)៖ គេប្រើប្រាស់គោលនយោបាយបែបនេះត្រូវបានគេធ្វើឡើងនៅពេលដែលសេដ្ឋកិច្ចមានកំណើនខ្លាំងហួសរហូតដល់គ្រប់គ្រងលែងបាន ដែលគេប្រៀបធៀបបាតុភូតសេដ្ឋកិច្ចបែបនេះទៅនឹងពពុះសាប៊ូ ព្រោះវាប៉ោងឡើងខ្លាំង លឿនពេក និងងាយបែកដូចពពុះសាប៊ូនៅពេលត្រូវខ្យល់។

## ២.៣. ផលិតផលក្នុងស្រុកសរុបដុល(ផសស)

គ្រប់គ្នាតែងតែលឺ អ្នកសេដ្ឋកិច្ចនិយាយអំពីកំណើនសេដ្ឋកិច្ចរបស់ប្រទេសនេះរបស់ប្រទេស នោះ។ ដើម្បីវាស់ឲ្យបានថាសេដ្ឋកិច្ចមានកំណើនប៉ុន្មាន ឬមានការថយចុះប៉ុន្មាន ពួកគេប្រើប្រាស់ បច្ចេកទេសគណនាផលិតផលក្នុងស្រុកសរុបដុលនេះហើយ ដើម្បីធ្វើជាសូចនាករសេដ្ឋកិច្ចវាស់វែង កំណើន។

[19] ដកស្រង់ចេញពីសៀវភៅ «សេដ្ឋកិច្ចកម្ពុជា» មាគ៌ាឆ្ពោះទៅរកភាពភ្លឺស្វាង របស់លោកបណ្ឌិត ហុង ជួន ណារ៉ុន ឆ្នាំ ២០១៥

### ២.៣.១. សារៈសំខាន់នៃផសស

ផលិតផលក្នុងស្រុកសរុបដុល ជាតម្លៃទីផ្សារនៃទំនិញ ឬសេវាកម្មទាំងអស់នៅក្នុងសេដ្ឋកិច្ច ដែលបានផលិតនៅក្នុងប្រទេសមួយ នៅរយៈពេលមួយច្បាស់លាស់[20]។ វាជាទំហំនៃការចំណាយ ឬចំណូលរបស់ប្រទេសមួយ ដែលភាគច្រើនត្រូវបានគេវាស់ក្នុងរយៈពេល ១ឆ្នាំ។ ដោយសារតែនៅក្នុងសេដ្ឋកិច្ច មានផលិតផល និងសេវាកម្មច្រើនប្រភេទរាប់មិនអស់ ទើបគេធ្វើការវាស់វែងទំហំផសស នេះជាទំហំទឹកប្រាក់(គិតជាឯកតាលុយ)។ ផសស ត្រូវបានសេដ្ឋវិទូជាច្រើនចាត់ទុកជាសូចនាករដ៏ប្រពៃមួយក្នុងការវាស់វែង និងប៉ាន់ប្រមាណពីសុខុមាលភាពនៃសេដ្ឋកិច្ច និងកម្រិតជីវភាពនៃប្រជាជន ដោយហេតុថានៅក្នុង ផសស នេះ វាបានបង្ហាញគ្រប់តួអង្គទាំងអស់នៃសេដ្ឋកិច្ចទាំង វិស័យសាធារណៈ វិស័យឯកជន និងគ្រួសារថែមទៀតផង។ ហេតុនេះហើយ ទើបសេដ្ឋវិទូនិយមប្រើប្រាស់ និងបង្កើតសូចនាករសេដ្ឋកិច្ចនានាដោយធៀបនឹងផសស ដូចជា៖ កំណើន FDI ធៀបនឹងផសស, ផសសក្នុងម្នាក់, ប្រាក់កម្ចីបរទេសធៀបនឹងផសសជាដើម។

ពេលខ្លះគេអាចប្រៀបប្រដូចសេដ្ឋកិច្ចទៅនឹងគោលគំនិត Zero-Sum Game ដែលបកស្រាយថា ផលចំណេញរបស់បុគ្គលម្នាក់គឺជា ការបាត់បង់របស់បុគ្គលម្នាក់ទៀត។ វាស្រដៀងគ្នាទៅនឹងសកម្មភាពនៅក្នុងសេដ្ឋកិច្ចដែរ។ ទាល់តែមានសកម្មភាពដោះដូរទើបមានការកើតឡើងនូវសកម្មភាពគណនេយ្យ ពោលគឺការចំណាយរបស់បុគ្គលម្នាក់ត្រូវតែជាចំណូលរបស់បុគ្គលម្នាក់ទៀត។ ស្របពេលដែល ផសស ត្រូវបានសេដ្ឋវិទូសន្មត់ថាជា ចំណាយសរុប និងជាចំណូលសរុប វាបានធ្វើឲ្យគេអាចគណនា ផសស តាមបែបចំណូល ឬចំណាយ ក្នុងពេលតែមួយ។ យ៉ាងណាមិញ ដោយមានភាពស្មុគស្មាញក្នុងការកំណត់ ផសស តាមបែបចំណូល សេដ្ឋវិទូនិយមគណនា ផសស តាមបែបចំណាយ។ គួរបញ្ជាក់ផងដែរថា កិច្ចការស្រាវជ្រាវមួយនេះ នឹងប្រើប្រាស់ម៉ូឌែល ផសស តាមបែបចំណាយផងដែរ ដើម្បីធ្វើការវិភាគពីឥទ្ធិពលរបស់សមាហរណកម្មសេដ្ឋកិច្ចមកលើសេដ្ឋកិច្ចប្រទេសកម្ពុជា។

### ២.៣.២. ធាតុផ្សំនៅក្នុងផសស

រូបមន្តគណនា ផសស តាមបែបចំណាយគឺ៖ $GDP = C + G + I + (X - M)$

- ❖ អថេរដែលមានឥទ្ធិពលផ្ទាល់លើ ផសស ក្នុងម៉ូឌែលនេះ មាន៖
  - C៖ ជាចំណាយលើទំនិញ ឬសេវាកម្មរបស់គ្រួសារ ឬបុគ្គលម្នាក់

[20] ដកស្រង់ចេញពីសៀវភៅកម្មវិធីសិក្សាមុខវិជ្ជា ម៉ាក្រូសេដ្ឋកិច្ច របស់ អ.ស សាស្ត្រាចារ្យ ឡុង ម៉ាមីឌី ឆ្នាំសិក្សា ២០១៥-២០១៦

- G៖ ជាចំណាយលើទំនិញ ឬសេវាកម្មរបស់រដ្ឋ
- I៖ ជាចំណាយទៅលើការវិនិយោគរបស់ក្រុមហ៊ុនឯកជន
- X៖ ជាទំហំនាំចេញរបស់ប្រទេស
- M៖ ជាទំហំនាំចូលរបស់ប្រទេស

❖ អថេរដែលមានឥទ្ធិពលប្រយោលលើ ផសស ក្នុងម៉ូឌែលនេះ មានដូចជា៖

- F៖ ជាចំណាយមួយដែលរដ្ឋឧបត្ថម្ភទៅឲ្យមន្ត្រី ឬទៅឲ្យគម្រោងណាមួយ
- T៖ ជាចំណូលរបស់រដ្ឋដែលបានមកពីការប្រមូលពន្ធ។ បើ T កើនឡើងនោះនឹងធ្វើឲ្យ C ថយចុះព្រោះប្រជាពលរដ្ឋត្រូវបង់ពន្ធបន្ថែម

## ៣. ប្រទេសកំពុងអភិវឌ្ឍន៍

ប្រទេសកំពុងអភិវឌ្ឍន៍ជាប្រទេសដែលប្រជាជនអាចរកប្រាក់ចំណូលបានតិច និងទទួលបានសេវាកម្មសាធារណៈពីរដ្ឋាភិបាលតិច បើប្រៀបធៀបនឹងប្រទេសកំពុងអភិវឌ្ឍន៍។ ក្នុងនោះ ប្រជាជនរបស់ប្រទេសកំពុងអភិវឌ្ឍន៍អាចរកចំណូលបានតិចជាង ២ដុល្លាអាមេរិកក្នុងមួយថ្ងៃ។[21] បើតាមរបាយការណ៍របស់ទីភ្នាក់ងារបន្ទុកស្ថានការ និងទស្សនៈវិស័យ សេដ្ឋកិច្ចពិភពលោក ឆ្នាំ ២០១៤ គេបានបែងចែកប្រទេសជានានាជា ៣ប្រភេទគឺ ប្រទេសអភិវឌ្ឍន៍, ប្រទេសកំពុងផ្លាស់ប្តូរសេដ្ឋកិច្ច និងប្រទេសកំពុងអភិវឌ្ឍន៍។ ជាមួយគ្នានេះ បើតាមការបែងចែករបស់បន្ទុកស្ថានការនេះ គេសង្កេតឃើញថាប្រទេសកំពុងអភិវឌ្ឍន៍នាពេលបច្ចុប្បន្ននេះ មាននៅលើទ្វីបអាស៊ី, ទ្វីបអាព្រិច, និងទ្វីបអាមេរិកឡាទីន។ យ៉ាងណាមិញប្រទេសកំពុងអភិវឌ្ឍន៍នាពេលបច្ចុប្បន្ននឹងទទួលបានផលចំនេញពាណិជ្ជកម្មនៅពេលដែលពួកគេចូលគ្នាជាបណ្តុំ ឬប្លុកពាណិជ្ជកម្ម ឬចូលជាសមាជិករបស់អង្គការពាណិជ្ជកម្មផ្សេងៗដូចជាអង្គការពាណិជ្ជកម្មពិភពលោកជាដើម។ បើតាមគេហទំព័ររបស់អង្គការពាណិជ្ជកម្មពិភពលោក អង្គការនេះបានអះអាងថាសមាជិករបស់ខ្លួនជាអ្នកប្រកាស់ខ្លួនថាជាប្រទេសកំពុងអភិវឌ្ឍន៍ដោយខ្លួនឯង ដើម្បីទទួលបានផលចំនេញពាណិជ្ជកម្ម។ នៅក្នុងអង្គការពាណិជ្ជកម្មនេះ មានគោលការណ៍អំណោយផលដល់ប្រទេសកំពុងអភិវឌ្ឍន៍គឺតម្រូវឲ្យប្រទេសអភិវឌ្ឍន៍ដាក់ពន្ធនាំចូលតិចជាងផលិតផលដែលនាំចូលដោយប្រទេសអភិវឌ្ឍន៍ ដើម្បីជម្រុញការនាំចេញ និងការវិនិយោគដល់ប្រទេសកំពុងអភិវឌ្ឍន៍។

[21] ដកស្រង់ចេញពីគេហទំព័រដែលមានអាស័យដ្ឋាន៖ https://study.com/academy/lesson/developing-countries-definition-examples.html

# ជំពូកទី២

# ប្រទេសកំពុងអភិវឌ្ឍន៍ និងសមាហរណកម្ម

## ១. លក្ខណៈដូចគ្នានៃសេដ្ឋកិច្ចប្រទេសកំពុងអភិវឌ្ឍន៍

ប្រទេសកំពុងអភិវឌ្ឍន៍ ឬបើនិយាយឲ្យអាក្រក់ស្តាប់ ប្រទេសក្រីក្រ ជាប្រទេសដែលមានការខ្វះខាតស្ទើរគ្រប់វិស័យ ហើយសំបូរទៅដោយប្រជាជនក្រីក្រ និងខ្វះចំណេះដឹង។ សេដ្ឋវិទូជាច្រើនយល់ខុសគ្នាទៅលើនិយមន័យនៃប្រទេសកំពុងអភិវឌ្ឍន៍។ យ៉ាងណាមិញ បើនិយាយពីសេដ្ឋកិច្ច គេសង្កេតឃើញថាប្រទេសកំពុងអភិវឌ្ឍន៍មានចំណុច ឬសុចនាករសេដ្ឋកិច្ច មួយចំនួនដែលដូចគ្នាដែលមានដូចខាងក្រោម៖

### ១.១. កម្រិត GDP ក្នុងម្នាក់ទាប និងអត្រានៃភាពក្រីក្រខ្ពស់

GDP ក្នុងមនុស្សម្នាក់ៗទាប គឺជាលក្ខណៈសម្គាល់មួយដ៏សំខាន់នៅក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ច។ វាមានន័យថាមនុស្សជាមធ្យមមិនអាចរកប្រាក់បានគ្រប់គ្រាន់ក្នុងការចាយវាយ ការវិនិយោគ ឬសន្សំប្រាក់។ ដូច្នេះវាបង្កើតបានជាវដ្តនៃភាពក្រីក្រដែលប្រជាជនភាគច្រើនត្រូវជួបប្រទះ។ គេសង្កេតឃើញថាបណ្តាប្រទេសកំពុងអភិវឌ្ឍន៍មានភាគរយនៃប្រជាជនដែលមានភាពក្រីក្រខ្ពស់។ ទោះបីជាយ៉ាងណាក៏ដោយ វិសាលភាពនៃភាពក្រីក្រដែលមាននៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍មិនត្រូវបានឆ្លុះបញ្ចាំងយ៉ាងពេញលេញនៅក្នុងប្រាក់ចំណូលក្នុងមនុស្សម្នាក់ដែលគ្រាន់តែជាប្រាក់ចំណូលជាមធ្យមនិងរួមបញ្ចូលទាំងប្រាក់ចំណូលរបស់អ្នកមានផងដែរ។ វិសមភាព ឬគម្លាតនៃប្រាក់ចំណូលដ៏ធំ ក្នុងការបែងចែកប្រាក់ចំណូលនៅក្នុងសេដ្ឋកិច្ចបានធ្វើឱ្យជីវិតរស់នៅរបស់ប្រជាជនកាន់តែវេទនា។ ប្រជាជនភាគច្រើននៃប្រទេសទាំងនេះរស់នៅក្រោមបន្ទាត់ភាពក្រីក្រ។

### ១.២. ភាពអាស្រ័យលើវិស័យកសិកម្ម និងការប្រើប្រាស់ធនធានធម្មជាតិច្រើនលើសលប់

តាមរយៈការសង្កេត ជាទូទៅប្រទេសកំពុងអភិវឌ្ឍន៍គឺជាប្រទេសកសិកម្ម។ ប្រជាជនប្រមាណ ៦០% ទៅ ៧៥% នៃប្រជាជនសរុបពឹងផ្អែកលើកសិកម្ម និងផលិតកម្មផ្ទាល់ខ្លួន(មិនដើម្បីធ្វើពាណិជ្ជកម្ម)។ លើសពីនេះទៅទៀតប្រហែល ប្រាក់ចំណូលប្រមាណជា ៣០% ទៅ ៥០% នៃចំណូលជាតិរបស់ប្រទេសទាំងនេះគឺទទួលបានពីវិស័យកសិកម្មតែឯង។ យោងទៅតាមការប៉ាន់ប្រមាណដែលធ្វើឡើងដោយអង្គការពលកម្មអន្តរជាតិ កម្លាំងពលកម្មប្រមាណជា ៦១% នៃប្រទេសកំពុងអភិវឌ្ឍន៍ដែលមានប្រាក់ចំណូលទាបមានការងារធ្វើនៅក្នុងវិស័យកសិកម្ម មានតែកម្លាំងពលកម្មប្រមាណ ១៩% ដែលបម្រើការនៅក្នុងវិស័យឧស្សាហកម្ម និង ២០% នៅក្នុងវិស័យសេវាកម្ម (ក្នុងតារាងទី ៣)។ ផ្ទុយទៅវិញនៅក្នុងប្រាក់ចំណូលខ្ពស់ពោលគឺប្រទេសអភិវឌ្ឍន៍តែ ៤% នៃកម្លាំងពល

កម្មរបស់ពួកគេតែប៉ុណ្ណោះដែលបម្រើការក្នុងវិស័យកសិកម្ម ខណៈដែល ២៦% នៃកម្លាំងពលកម្មរបស់ពួកគេធ្វើការនៅក្នុងឧស្សាហកម្ម និង ៧០%នៅក្នុងសេវាកម្ម។

តារាងទី ៣៖ ការបែងចែកកម្លាំងពលកម្មតាមវិស័យ

| Countries | Agriculture | Industry | Services |
|---|---|---|---|
| Low-income countries | 61 | 19 | 20 |
| Middle-income countries | 22 | 34 | 44 |
| High-Income countries | 4 | 26 | 70 |

ប្រភពពីគេហទំព័រ http://www.economicsdiscussion.net/developing-economy/characteristics-developing-economy/common-characteristics-of-developing-countries-economics/29990

មួយវិញទៀត នៅក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ច ប្រទេសកំពុងអភិវឌ្ឍន៍ប្រើប្រាស់ធនធានធម្មជាតិដែលមានស្រាប់យ៉ាងច្រើន តាមរយៈការលក់ សម្បទាន ឬក្នុងទម្រង់ផ្សេងទៀត។ ស្របពេលដែលប្រទេសអភិវឌ្ឍន៍អភិរក្សធនធានធម្មជាតិរបស់ពួកគេ ធនធានធម្មជាតិនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍បានក្លាយទៅជាមុខសញ្ញា និងក្លាយជាធនធានកម្រដែលមានតម្លៃខ្ពស់ ជាពិសេសធនធានធម្មជាតិដែលមិនងាយនឹងបង្កើតឡើងវិញដូចជា រ៉ែ ព្រៃឈើ និងខ្សាច់ជាដើម។ ដោយសារតែ ការលក់ធនធានធម្មជាតិ មិនចាំបាច់មានចំណាយវិនិយោគច្រើនដូចវិស័យផ្សេងៗទៀត វាកាន់តែលើកទឹកចិត្តឲ្យប្រទេសកំពុងអភិវឌ្ឍន៍ ឬរដ្ឋលក់នូវប្រភពធនធានកម្រនេះដើម្បីយកលុយមកអភិវឌ្ឍសេដ្ឋកិច្ច។

### ១.៣. ផលិតភាពតូច និងឧស្សាហកម្មដែលផ្តោតលើកម្លាំងពលកម្ម

ដោយសារតែមានការចូលរួមពីបច្ចេកវិទ្យាតិច ផលិតភាពនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍មានសភាពតូចបើប្រៀបធៀបនឹងប្រទេសកំពុងអភិវឌ្ឍន៍។ ជាមួយគ្នានេះដែរ ការចូលក្នុងរបស់កម្លាំងពលកម្មច្រើនលើសលប់ទៅក្នុងវិស័យកសិកម្មក៏ជះឥទ្ធិពលទៅដល់ផលិតភាពរបស់ប្រទេសផងដែរ ព្រោះផលិតផលកសិកម្មប្រើប្រាស់ពេលវេលាយូរ ហើយមានតម្លៃទាប បើប្រៀបធៀបនឹងតម្លៃនៃផលិតផលកែច្នៃ។ ម៉្យាងវិញទៀត ដោយសារតែ មានការចូលរួមតិចពីបច្ចេកវិទ្យាតិច ឬមានការវិវត្តន៍យឺតយ៉ាវ វាបានធ្វើឲ្យឧស្សាហកម្មនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ជាប្រភេទឧស្សាហកម្មផ្តោតលើកម្លាំងពលកម្ម (Labor-incentive Industry)។

### ១.៤. អត្រាកំណើតខ្ពស់ ឬប្រជាជនច្រើន

លក្ខណៈទូទៅមួយទៀតនៃបណ្តាប្រទេសកំពុងអភិវឌ្ឍន៍គឺពួកគេមានអត្រាកំណើនប្រជាជនខ្ពស់ ឬប្រជាជនច្រើន។ ដោយសារតែមានភាពជឿនលឿនក្នុងវិស័យពេទ្យ និងវេជ្ជសាស្ត្រ ដែលធ្វើ

ឲ្យអត្រាមរណៈថយចុះ ជារឿយៗបញ្ហាកំណើនប្រជាជន កើតឡើងដោយសារតែបញ្ហាកង្វះការយល់ដឹង កង្វះការរៀបចំផែនការគ្រួសារ ការខ្វះការអប់រំសុខភាពផ្លូវភេទ និងគោលគំនិតរបស់ប្រជាជនដែលយល់ថា «មានកូនកាន់តែច្រើនអាចបង្កើតកម្លាំងពលកម្មកាន់តែច្រើនសម្រាប់គ្រួសារដើម្បីរកប្រាក់ចំណូល និងធ្វើកសិកម្ម»។ ឧទាហរណ៍ដូចជា ប្រទេសឥណ្ឌា ប៉ាគីស្ថាន និងបង់ក្លាដេស មានប្រជាជនកើនឡើងរាប់លាននាក់ និងអត្រាកំណើនប្រជាជនកើនឡើងខ្ពស់ បើយើងធ្វើការប្រៀបធៀបនឹងប្រទេសអាមេរិចឡាទីនមួយចំនួន ចំនួនប្រជាជនសរុបក្នុងប្រទេសអាមេរិកឡាទីនខ្លះ មានចំនួនតិចជាងចំនួនប្រជាជននៅក្នុងទីក្រុងមួយរបស់ប្រទេសឥណ្ឌា ឬប្រទេសចិនផង។ ប្រទេសនៅតំបន់ ជាពិសេស នៅអាស៊ីខាងត្បូង និងអាស៊ីបូព៌ាមានប្រជាជនច្រើន។ ជាមួយគ្នានេះដែរបើតាមតួលេខនៅក្នុងតារាងទី ៤ បានបង្ហាញថា កំណើនប្រជាជននៅក្នុងបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ដែលមានប្រាក់ចំណូលទាបមានចំនួន ២.៣% ក្នុងមួយឆ្នាំ (គិតពីឆ្នាំ ១៩៩០ ដល់ ២០០៩) ហើយប្រទេសកំពុងអភិវឌ្ឍន៍ដែលមានប្រាក់ចំណូលមធ្យមមានចំនួន ១.៣% ក្នុងមួយឆ្នាំ(ក្នុងអំឡុងពេលដូចគ្នា)។ ផ្ទុយទៅវិញអត្រាកំណើនប្រជាជននៅក្នុងបណ្តាប្រទេសដែលមានប្រាក់ចំណូលខ្ពស់ (ពោលគឺប្រទេសអភិវឌ្ឍន៍) មានចំនួន ០.៧% ក្នុងមួយឆ្នាំ ដែលនេះមានន័យថាចំនួនប្រជាជននៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍បានកើនឡើងយ៉ាងឆាប់រហ័សបើប្រៀបធៀបទៅនឹងប្រទេសអភិវឌ្ឍន៍។

តារាងទី ៤៖ ការកើនឡើងនៃប្រជាជន(គិតពីឆ្នាំ ១៩៩០ ដល់២០០៩)

| Countries | Population in 2009 Millions | Average annual population growth rate 1990-2009 (per cent) | Dependency ratio (% of working age population) | | Crude death rate per 1,000 people (2009) | Crude birth rate per 1000 people (2009) |
|---|---|---|---|---|---|---|
| | | | Young 2009 | Old 2009 | | |
| World | 6,775 | 1.3 | 42 | 12 | 8 | 20 |
| Low Income | 4,846 | 2.3 | 69 | 6 | 11 | 34 |
| Middle Income | 4,813 | 1.3 | 41 | 10 | 8 | 19 |
| Low & Middle Income | 5,659 | 1.4 | 45 | 9 | 8 | 21 |
| High Income | 1,117 | 0.7 | 26 | 23 | 8 | 12 |

ប្រភពពីគេហទំព័រ http://www.economicsdiscussion.net/developing-economy/characteristics-developing-economy/common-characteristics-of-developing-countries-economics/29990

### ១.៥. ភាពបត់បែននៃថ្លៃ

ចំពោះប្រទេសអភិវឌ្ឍន៍ដែលជាប្រទេសប្រជាធិបតេយ្យ ច្បាប់ និងបទបញ្ញត្តិនានានៅក្នុងប្រទេសមានភាពធូររលុងជាងបើយើងប្រៀបធៀបទៅនឹងប្រទេសអភិវឌ្ឍន៍។ ផ្នែកជាច្រើននៃសេដ្ឋកិច្ច និងអាជីវកម្មមិនទាន់[22]ត្រូវបានគេយកទៅចងក្រងដាក់នៅក្រោមច្បាប់នោះទេ ដែលអ្នកសេដ្ឋកិច្ចភាគច្រើនសន្មត់ប្រទេសនៃអាជីវកម្មប្រភេទនេះថាជាអាជីវកម្មក្រៅផ្លូវការ[23] និងមិនបានរាប់ចូលទៅក្នុងសូចនាករសេដ្ឋកិច្ចរបស់ប្រទេសនោះទេ ក្នុងខណៈពេលដែលចំណូលពីអាជីវកម្មផ្លូវការមានភាគរយ ឬប្រភាគតិចជាងចំណូលដែលបានមកពីអាជីវកម្មមិនផ្លូវការនៅក្នុងសេដ្ឋកិច្ច។ ការដែលមិនបានចាប់យកនូវអាជីវកម្មក្រៅផ្លូវការទាំងនោះយកមកចងក្រងដាក់នៅក្រោមច្បាប់ វាធ្វើឲ្យគេមិនអាចចំណាត់បានច្បាស់លាស់ពីថ្លៃដើមនៃការវិនិយោគ, ការផ្គត់ផ្គង់ និងតម្រូវការ, រួមទាំងកត្តាផលិតកម្មផ្សេងទៀតបានដែលជាហេតុធ្វើឲ្យ ថ្លៃនៃកត្តាផលិតកម្ម និងថ្លៃនៃកត្តាវិនិយោគនៅក្នុងអាជីវកម្មប្រភេទនេះមានភាពបត់បែនខ្លាំងទៅតាមភាពមិននឹងនរនៃទីផ្សារ។ កាលណាប្រភាគនៃចំណូលដែលបានមកពីអាជីវកម្មក្រៅផ្លូវការនៅតែច្រើនជាងអាជីវកម្មផ្លូវការ នោះភាពបត់បែននៃថ្លៃនឹងនៅតែកើតមានដែលធ្វើឲ្យគេពិបាកក្នុងការព្យាករណ៍ និងប៉ាន់ប្រមាណសេដ្ឋកិច្ច។

### ១.៦. វិសមភាពនៃការអភិវឌ្ឍន៍

ប្រទេសកំពុងអភិវឌ្ឍន៍មានផ្នែកជាច្រើននៅក្នុងប្រទេសដែលត្រូវការអភិវឌ្ឍន៍ ប៉ុន្តែរដ្ឋមិនមានលទ្ធភាពក្នុងការបង្កើតគម្រោងអភិវឌ្ឍន៍ឲ្យបានគ្រប់តំបន់ទាំងអស់នោះទេ។ ក្នុងដំណាក់លូតលាស់ដំបូងនៃសេដ្ឋកិច្ច គម្រោងអភិវឌ្ឍន៍ភាគច្រើនត្រូវបានគេដាក់ទៅកាន់តំបន់មានសក្តានុពលសេដ្ឋកិច្ចដែលមានប្រជាជនច្រើន, លក្ខខណ្ឌភូមិសាស្ត្រអំណោយផល និងមានសកម្មភាព ឬចរន្តសេដ្ឋកិច្ចខ្លះរួចទៅហើយដែលគេអាចទាញឲ្យមានកំណើនសេដ្ឋកិច្ចបាន។ ពោលគឺ គម្រោងអភិវឌ្ឍន៍ត្រូវបានគេដាក់ចេញទៅនៅតំបន់ទីប្រជុំជន។ ជាទូទៅគម្រោងអភិវឌ្ឍន៍ត្រូវបានគេដាក់ចេញជាកញ្ចប់ដែលមានទាំងការអភិវឌ្ឍន៍ប្រព័ន្ធរដ្ឋបាល, ហេដ្ឋារចនាសម្ព័ន្ធ, ការវិនិយោគរបស់ឯកជន ឬរដ្ឋ ក៏ដូចជាកត្តាផលិតកម្មផ្សេងទៀតក្នុងពេលតែមួយ ដែលនេះធ្វើឲ្យតំបន់ទីប្រជុំជនមានសំទុះសេដ្ឋកិច្ចយ៉ាងលឿន និងឆាប់រហ័ស ហើយធ្វើឲ្យប្រជាជននៅក្នុងតំបន់នោះមានការប្រែប្រួលជីវភាព

[22] អាជីវកម្មក្រៅផ្លូវការជាអាជីវកម្មដែលមិនត្រូវបានហាមឃាតដោយរដ្ឋ ហើយមិនត្រូវបានរដ្ឋចងក្រងដាក់ឲ្យនៅក្រោមច្បាប់ណាមួយ ឬស្ថាប័នដែនសមត្ថកិច្ចណាមួយធ្វើការត្រួតពិនិត្យ ឬតាមដាន។ អាជីវកម្មផ្លូវការជាប្រភេទអាជីវកម្មដែលទទួលស្គាល់ដោយរដ្ឋ ហើយរដ្ឋមានលទ្ធភាពក្នុងការចុះបញ្ជីអាជីវកម្មយ៉ាងត្រឹមត្រូវ និងស្របច្បាប់។

[23] បើនៅក្នុងប្រទេសកម្ពុជាមានដូចជា៖ អាជីវកម្មលក់លៀសហាល ឬអាហារតាមផ្លូវ, ប៉ះកង់តាមផ្លូវសាធារណៈ, រត់ម៉ូតូឌុបជាដើម, លក់សម្ភារៈតាមonline...

យ៉ាងឆាប់រហ័ស។ បន្តិចម្តងៗ ប្រជាជននឹងធ្វើចំណាកស្រុកពីតំបន់ដាច់ស្រយាលមកតំបន់ទីប្រជុំជនដែលធ្វើឲ្យតំបន់ទីប្រជុំជនកាន់តែរីកធំឡើងៗ និងមានតម្រូវការសេដ្ឋកិច្ចច្រើនឡើងៗពីមួយថ្ងៃទៅមួយថ្ងៃ ដែលវាជាកត្តាជម្រុញឲ្យតំបន់ទីប្រជុំជនកាន់តែមានការអភិវឌ្ឍន៍ និងរីកចម្រើនជាងតំបន់ជនបទ ឬដាច់ស្រយាល។ គេតែងសង្កេតឃើញនៅតំបន់ទីប្រជុំជនមានការកើនឡើងនូវហេដ្ឋារចនាសម្ព័ន្ធ អគារធំៗ ស្ពឹមស្អែ ពោលគឺមានសព្វគ្រប់បែបយ៉ាង ខុសអីតែតំបន់ជនបទ និងតំបន់ដាច់ស្រយាលដែលពោរពេញទៅដោយដីទំនេរទុកចោល ផ្ទះសម្បែងចាស់ៗ និងប្រជាជនដែលមានវ័យចាស់ជរា និងភាពទន់ខ្សោយនៃសកម្មភាព និងចរន្តសេដ្ឋកិច្ច។

## ២. ប្រទេសកំពុងអភិវឌ្ឍន៍ចូលសមាហរកម្មសេដ្ឋកិច្ច

ដូចដែលបានរៀបរាប់មកពីខាងលើ ប្រទេសកំពុងអភិវឌ្ឍន៍ជាប្រទេសដែលប្រជាជនអាចរកប្រាក់ចំណូលបានតិច និងទទួលបានសេវាកម្មសាធារណៈពីរដ្ឋាភិបាលតិច បើប្រៀបធៀបនឹងប្រទេសអភិវឌ្ឍន៍។ យ៉ាងណាមិញ ទោះបីជាក្នុងលក្ខខណ្ឌបែបនេះក៏ដោយ រដ្ឋមួយសម្រេចចិត្តធ្វើសមាហរណកម្មសេដ្ឋកិច្ចជាមួយនឹងប្រទេសណាមួយ ឬប្លុកណាមួយដោយមើលឃើញពីផលប្រយោជន៍នៃការធ្វើសមាហរណកម្មនោះ។

### ២.១. កត្តាជម្រុញឲ្យប្រទេសកំពុងអភិវឌ្ឍន៍ចូលសមាហរណកម្មសេដ្ឋកិច្ច

យើងអាចបែងចែកមូលហេតុដែលជម្រុញឲ្យប្រទេសកំពុងអភិវឌ្ឍន៍ចូលសមាហរណកម្មសេដ្ឋកិច្ចជា ៣ គឺ៖

#### ២.១.១. ការធ្វើពាណិជ្ជកម្ម

ការអភិវឌ្ឍន៍សេដ្ឋកិច្ចគឺជារបៀបវីរៈសំខាន់បំផុតសម្រាប់ប្រទេសនានាទូទាំងពិភពលោក មិនថាប្រទេសអភិវឌ្ឍន៍ ឬប្រទេសកំពុងអភិវឌ្ឍន៍នោះទេ។ ការនាំយកផលិតផលសម្រេចក្នុងស្រុករបស់ខ្លួនទៅលក់នៅក្រៅប្រទេសនឹងនាំមកនូវការកើនឡើងនូវប្រាក់ចំនេញ ការងារ ព្រមទាំងបង្កើននូវសកម្មភាពសេដ្ឋកិច្ចទៅលើវិស័យដែលពាក់ព័ន្ធទៀតផង ដូចជាអ្វីដែលលោកអតីតប្រធានាធិបតេយ្យអាមេរិក បារ៉ាក់ អូបាម៉ា បាននិយាយនៅក្នុងកម្មវិធីទូរទស្សន៍មួយនៅសហរដ្ឋអាមេរិកកាលពីខែមិថុនា ឆ្នាំ២០១៦មុនពេលដែលអាណត្តិរបស់លោកត្រូវបានបញ្ចប់ថា «The more we sell abroad, the more higher paying-job we provide here at home» បានន័យថា «បើយើងលក់ទៅក្រៅប្រទេស បានកាន់តែច្រើន វានឹងធ្វើឲ្យមានការងារផ្តល់ប្រាក់ខែកាន់តែច្រើននៅក្នុងប្រទេសយើង»។ តាមរយៈការលុបបំបាត់ចោលនូវរនាំងពាណិជ្ជកម្ម ពោលគឺពន្ធនាំចូល និងការអនុគ្រោះពន្ធលើប្រទេសកំពុងអភិវឌ្ឍន៍ វាផ្តល់ភាពងាយស្រួលដល់ប្រទេសកំពុងអភិវឌ្ឍន៍ដើម្បីនាំយកទំនិញ

ដែលមានតម្លៃទាបជាង(ប្រៀបធៀបនឹងទំនិញរបស់ប្រទេសអភិវឌ្ឍន៍) ទៅលក់លើទីផ្សាររបស់ប្រទេសអភិវឌ្ឍន៍ដែលមានសភាពទូលាយជាង(ព្រោះប្រជាជនរបស់ប្រទេសអភិវឌ្ឍន៍មានប្រាក់ចំណូលខ្ពស់ដែលអាចចំណាយទៅលើទំនិញច្រើនប្រភេទនៅក្នុងទីផ្សារដែលមាន)។ ការធ្វើពាណិជ្ជកម្មនៅក្នុងសមាហរណកម្មបែបនេះនឹងនាំមកនូវការកើនឡើងនូវប្រាក់ចំណូលដល់ប្រទេសកំពុងអភិវឌ្ឍន៍ជាមួយនឹងទំនិញប្រកួតប្រជែងរបស់គេ(ទំនិញដែលមាន Comparative Advantage)។

តារាងទី ៥៖ ទំហំពាណិជ្ជកម្មទំនិញ និង GDP ពិត ចាប់ពីឆ្នាំ ២០១៤ ដល់២០១៩(ព្យាករណ៍) (គិតជា%)

Annual % change

| | 2014 | 2015 | 2016 | 2017 | 2018P | 2019P |
|---|---|---|---|---|---|---|
| **Volume of world merchandise trade b** | 2.7 | 2.5 | 1.8 | 4.7 | 4.4 | 4.0 |
| **Exports** | | | | | | |
| Developed economies | 2.1 | 2.3 | 1.1 | 3.5 | 3.8 | 3.1 |
| Developing economies c | 2.7 | 2.4 | 2.3 | 5.7 | 5.4 | 5.1 |
| North America | 4.6 | 0.8 | 0.6 | 4.2 | 4.5 | 4.5 |
| South and Central America and the Caribbean | -2.1 | 1.8 | 1.9 | 2.9 | 2.8 | 2.6 |
| Europe | 1.6 | 2.9 | 1.1 | 3.5 | 3.6 | 2.9 |
| Asia | 4.5 | 1.5 | 2.3 | 6.7 | 5.7 | 5.0 |
| Other regions d | -1.0 | 5.5 | 2.6 | 2.3 | 4.7 | 4.4 |
| **Imports** | | | | | | |
| Developed economies | 3.4 | 4.3 | 2.0 | 3.1 | 4.1 | 3.3 |
| Developing economies c | 2.4 | 0.6 | 1.9 | 7.2 | 4.8 | 4.4 |
| North America | 4.3 | 5.4 | 0.1 | 4.0 | 5.7 | 5.0 |
| South and Central America and the Caribbean | -2.7 | -6.4 | -6.8 | 4.0 | 3.9 | 5.7 |
| Europe | 3.0 | 3.7 | 3.1 | 2.5 | 3.5 | 2.8 |
| Asia | 3.7 | 4.0 | 3.5 | 9.6 | 5.9 | 4.7 |
| Other regions d | 0.5 | -5.6 | 0.2 | 0.9 | 0.4 | 1.8 |
| **Real GDP at market exchange rates** | 2.7 | 2.7 | 2.3 | 3.0 | 3.2 | 3.1 |
| Developed economies | 2.0 | 2.3 | 1.6 | 2.3 | 2.4 | 2.2 |
| Developing economies c | 4.3 | 3.7 | 3.6 | 4.3 | 4.6 | 4.6 |
| North America | 2.6 | 2.7 | 1.5 | 2.4 | 2.8 | 2.7 |
| South and Central America and the Caribbean | 0.9 | -0.9 | -2.1 | 1.0 | 2.3 | 2.8 |
| Europe | 2.0 | 2.3 | 1.9 | 2.6 | 2.4 | 2.1 |
| Asia | 4.1 | 4.2 | 4.1 | 4.5 | 4.5 | 4.4 |
| Other regions d | 2.5 | 1.1 | 2.2 | 2.0 | 2.8 | 2.9 |

ប្រភពពីអង្គការពាណិជ្ជកម្មពិភពលោក

**២.១.២. ការអភិវឌ្ឍន៍**

បើយើងពិនិត្យទៅមើលពីប្រវត្តិសាស្ត្រពិភពលោកឲ្យស៊ីជម្រៅ ក្រោយពីយុគនៃអាណានិគម និងសង្គ្រាមលោកលើកទី ២ត្រូវបានបញ្ចប់ ប្រទេសដែលធ្លាប់នៅក្រោមអាណានិគមរបស់បរទេស សុទ្ធសឹងជាប្រទេសកំពុងអភិវឌ្ឍន៍។ ក្រោយពីអាណានិគមត្រូវបានបញ្ចប់ទៅ ប្រទេសដែលធ្លាប់នៅក្រោមនឹមអាណានិគមបរទេសត្រូវរងការបំផ្លេចបំផ្លាញ និងជួបប្រទះភាពក្រីក្រដោយសារតែក្រុមប្រទេសអាណានិគមទាំងនោះកេងប្រវ័ញ្ច និងស្រូបទាញយកនូវធនធានអស់យ៉ាងច្រើនសន្ធឹកសន្ធាប់ដើម្បីបម្រើដល់នយោបាយសក្តិភូមិ និងនយោបាយវាតទីនិយមរបស់ក្រុមប្រទេសដែលដាក់អាណានិគមទាំងនោះ។ ស្របជាមួយគ្នានេះដែរ ប្រទេសកំពុងអភិវឌ្ឍន៍ជាច្រើនក៏បានរងគ្រោះ និងឆ្លងកាត់នូវសង្គ្រាមលោកលើកទី ២ ដែលបន្សល់នូវភាពខ្ទេចខ្ទាំទាំងផ្នែកសេដ្ឋកិច្ច និងហេដ្ឋារចនាសម្ព័ន្ធនានា ដែលធ្វើឲ្យប្រទេសរបស់ពួកគេពិបាកនឹងអភិវឌ្ឍ។ ក្រៅពីឆ្លងកាត់នូវអាណានិគម និងសង្គ្រាមលោកដ៏ជូរចត់ហើយនោះ ភាគច្រើននៃប្រទេសកំពុងអភិវឌ្ឍន៍ក៏បានឆ្លងកាត់នូវសង្គ្រាមត្រជាក់មួយទៀតដែលបានបែងចែកពិភពលោកជា ២ផ្សេងគ្នាដោយមនោគមន៍វិជ្ជា កុំម្មុយនីស្ត និងសេរី ទាំងសេដ្ឋកិច្ច និងនយោបាយ។ ការបែងចែកនេះជះឥទ្ធិពលយ៉ាងខ្លាំងទៅលើដំណើរការអភិវឌ្ឍន៍របស់ប្រទេសកំពុងអភិវឌ្ឍន៍ព្រោះវាអាស្រ័យទៅលើម៉ូឌែលសេដ្ឋកិច្ច និងការដឹកនាំដែលប្រទេសនោះសម្រេចចិត្តដើរតាម។ ដោយសារតែមូលហេតុនៃភាពខ្ទេចខ្ទាំពុំរៃដោយសារសង្គ្រាមនេះហើយទើបបានជាប្រទេសកំពុងអភិវឌ្ឍន៍ត្រូវស្វែងរកដំណោះស្រាយក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ចឲ្យបានសមស្របនឹងបរិបទរបស់ប្រទេសខ្លួន និងបរិបទនៃសេដ្ឋកិច្ចអន្តរជាតិ។ ហេតុដូច្នេះហើយទើបពួកគេជ្រើសរើសយកការធ្វើសមាហរណកម្មសេដ្ឋកិច្ចជាមួយប្រទេសអភិវឌ្ឍន៍ និងសមាហរណកម្មសេដ្ឋកិច្ចទៅក្នុងប្លុកសេដ្ឋកិច្ចធំៗ ដូចជា WTO ជាដើម ស្របពេលដែលបរិបទនៃសេដ្ឋកិច្ចពិភពលោកក្រោយសង្គ្រាមត្រជាក់ផ្តោតទៅលើសមាហរណកម្មសេដ្ឋកិច្ច។

**២.១.៣. នយោបាយ និងសន្តិសុខ**

ប្រទេសកំពុងអភិវឌ្ឍន៍ជាប្រទេសក្រីក្រ ហើយប្រទេសនេះត្រូវយកចិត្តទុកដាក់អភិវឌ្ឍទៅលើគ្រប់វិស័យ ដែលក្នុងនោះក៏មានវិស័យសន្តិសុខជាតិផងដែរ។ អស្ថេរភាពនៃប្រព័ន្ធនយោបាយអន្តរជាតិជាកត្តាគម្រាមកំហែងមួយដ៏ធំដល់សន្តិសុខ និងការអភិវឌ្ឍន៍របស់ប្រទេសដែលមានសេដ្ឋកិច្ចទន់ខ្សោយ។ ហេតុដូច្នេះ ដើម្បីឲ្យមានអធិបតេយ្យភាពនៅក្នុងនយោបាយអន្តរជាតិ ចង់ ឬមិនចង់ប្រទេសនានាដែលមានការយល់ឃើញដូចគ្នា ត្រូវបោះដៃដាក់គ្នាទៅវិញទៅមក និងរួមគ្នាដើម្បីប្រឆាំងនឹងនយោបាយដែលគម្រាមកំហែងដល់សន្តិសុខរបស់ខ្លួន។ វាដូចទៅនឹងក្នុង

ករណីសមាហរណកម្មសេដ្ឋកិច្ចអាស៊ាន។ យើងគួរគប្បីកុំភ្លេចថា នៅក្នុងអំឡុងពេលដែលអាស៊ានចាប់ផ្ដើម បង្កើត ពិភពលោកកំពុងស្ថិតនៅក្នុងសង្គ្រាមត្រជាក់ ដែលកាលនោះតំបន់អាស៊ីអាគ្នេយ៍ជាសមរភូមិមួយដ៏សំខាន់នៅក្នុងពេលនោះ។ បើទោះបីជានៅក្នុងសន្ធិសញ្ញាទីក្រុងបាងកកបានរៀបរាប់ពីគោលបំណងអភិវឌ្ឍសេដ្ឋកិច្ចរបស់សមាជិកក៏ដោយក្តី ក៏នៅពីក្រោយសន្ធិសញ្ញានេះមានគោលបំណងមួយដ៏ធំ គឺទប់ស្កាត់ការរីកសាយភាយនូវមនោគមន៍វិជ្ជាកុំម្មុយនីស្ត និងដើម្បីការពារនយោបាយក្នុងស្រុក ក៏ដូចជាខឿនសេដ្ឋកិច្ចសេរីរបស់ខ្លួនពីការគម្រាមគំហែងនៃមនោគមវិជ្ជាកុំម្មុយនីស្ត និងទ្រឹស្តីទីផ្សារផែនការនៅក្នុងតំបន់ផងដែរ។ ប្រទេសដែលមានការអភិវឌ្ឍន៍លឿនដូចជាថៃឡង់ដ៍ និងសិង្ហបុរីជាដើមមិនចង់ឲ្យប្រទេសរបស់ខ្លួនធ្លាក់ទៅជាជនរងគ្រោះនៃសង្គ្រាមត្រជាក់នោះទេ ហេតុដូច្នេះទើបពួកគេ និងប្រទេសស្ថាបនិកអាស៊ាន ៣ ទៀតនាំគ្នាបង្កើតនូវសហគមន៍អាស៊ាននេះឡើង ដើម្បីរួមគ្នាទប់ស្កាត់ឥទ្ធិពលកុំម្មុយនីស្តនៅក្នុងតំបន់។

## ២.២. ផលប្រយោជន៍របស់ប្រទេសកំពុងអភិវឌ្ឍន៍ចូលសមាហរណកម្មសេដ្ឋកិច្ច

កម្រិតនៃផលប្រយោជន៍នៃការចូលសមាហរណកម្មសេដ្ឋកិច្ចដែលទទួលបាន វាអាស្រ័យទៅលើប្រភេទនៃសមាហរណកម្ម, កម្រិតនៃការធ្វើសមាហរណកម្ម និងប្រទេសដែលជាសមាជិកនៃសមាហរណកម្មនោះ(ជាពិសេសចំនួននៃប្រទេសអភិវឌ្ឍន៍នៅក្នុងសមាហរណកម្ម) ព្រោះសមាហរណកម្មដែលមានតែប្រទេសកំពុងអភិវឌ្ឍន៍សុទ្ធក៏មិនជាផលល្អសម្រាប់ចីរភាពនៃសមាហរណកម្មនោះដែរ។ ប្រទេសកំពុងអភិវឌ្ឍន៍ចូលក្នុងសមាហរណកម្មដោយសង្ឃឹមថានឹងជម្រុញការនាំចេញទៅកាន់ប្រទេសសមាជិក ចុះបើសមាជិកទាំងអស់នៃសមាហរណកម្មនោះសុទ្ធសឹងតែជាអ្នកនាំចេញ តើនរណាជាអ្នកនាំចូល? ដូច្នេះ យើងអាចនិយាយបានថា ប្រទេសអភិវឌ្ឍន៍ និងប្រទេសកំពុងអភិវឌ្ឍន៍ជាប្រទេសបំពេញឲ្យគ្នានៅក្នុងសមាហរណកម្មសេដ្ឋកិច្ច។

### .២.២.១. ការបង្កើតពាណិជ្ជកម្ម ( Trade Creation )

ការបង្កើតពាណិជ្ជកម្ម (Trade Creation) សម្តៅទៅលើការដែលពាណិជ្ជកម្មរវាងប្រទេស និងប្រទេសធ្វើឡើងដោយមិនមានរបាំងពាណិជ្ជកម្ម ហើយនាំទៅរកពាណិជ្ជកម្មដែលផ្តល់ផលចំនេញដល់ប្រទេស។ ការបង្កើតពាណិជ្ជកម្ម និងធ្វើឲ្យប្រទេសមួយអាចស្វែងរកប្រភពផ្គត់ផ្គង់មួយដែលមានថ្លៃថោកជាងមុន។ ប្រទេសអភិវឌ្ឍន៍ត្រូវការចាំបាច់នូវការផ្គត់ផ្គង់ដែលមានតម្លៃទាបជាពិសេស គឺការផ្គង់ផ្គង់លើផលិតផលបច្ចេកវិទ្យា គ្រឿងចក្រ និងឧបករណ៍ផ្គត់ផ្គង់ដល់ឧស្សាហកម្មក្នុងស្រុក។ ការធ្វើសមាហរណកម្មសេដ្ឋកិច្ចរវាងប្រទេសដែលមានបច្ចេកវិទ្យាខ្ពស់ នឹងធ្វើឲ្យប្រទេសអភិវឌ្ឍន៍អាចនាំយកនូវបច្ចេកវិទ្យាទាំងនោះចូលក្នុងស្រុកដើម្បីអភិវឌ្ឍរបស់ពួកគេ ក្នុងតម្លៃទាបជាងបើ

ប្រៀបធៀបនឹងមុនពេលធ្វើសមាហរណកម្ម។ ម៉្យាងទៀត តាមរយៈការចុះសន្ធិសញ្ញានៅក្នុងសមាហរណកម្ម ប្រទេសអភិវឌ្ឍន៍បើកចិត្តទូលាយក្នុងការចែករំលែកបច្ចេកវិទ្យារបស់ខ្លួនទៅឲ្យប្រទេសដែលជាសមាជិកសមាហរណកម្មសេដ្ឋកិច្ចរបស់ខ្លួនជាងប្រទេសដែលមិនមែនជាសមាជិក។

**២.២.២. បង្កើនវិនិយោគទុន**

ប្រទេសកំពុងអភិវឌ្ឍន៍ត្រូវការចាំបាច់នូវទុនដើម្បីវិនិយោគ មិនថាវិនិយោគទុនដែលមាននៅក្នុងស្រុកស្រាប់ និងលំហូរវិនិយោគទុនមកពីក្រៅប្រទេសនោះទេ។ វិនិយោគទុនក្នុងស្រុកអាចនាំមកនូវចីរភាព និងការអភិវឌ្ឍន៍សេដ្ឋកិច្ចក្នុងស្រុករយៈពេលវែងដោយភាពជឿជាក់ ស្របពេលដែលវិនិយោគទុនមកពីក្រៅស្រុកនាំមកនូវសំទុះនៃការអភិវឌ្ឍន៍សេដ្ឋកិច្ច, បច្ចេកវិទ្យាថ្មី, របៀបរបបនៃការធ្វើជំនួញបែបថ្មីដែលនឹងអាចនាំមកនូវភាពសំបូរបែបនៃឧស្សាហកម្ម និងមុខជំនួញនៅក្នុងប្រទេស ហើយរដ្ឋាភិបាលអាចធ្វើពិពិធកម្មសេដ្ឋកិច្ចរបស់ប្រទេសបាន។ នៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ ទុនវិនិយោគនៅក្នុងស្រុកមានចំនួនតិចជាងប្រទេសអភិវឌ្ឍន៍ ហេតុដូច្នេះហើយការវិនិយោគធំៗនៅក្នុងស្រុក ដូចជាហេដ្ឋារចនាសម្ព័ន្ធខ្នាតធំ ឧស្សាហកម្មខ្នាតធំជាដើម ត្រូវការវិនិយោគទុនពីក្រៅស្រុកដើម្បីចូលរួមជាកម្លាំងចលករក្នុងការធ្វើវាឲ្យបាន។

មួយវិញទៀត សមាហរណកម្មសេដ្ឋកិច្ចនឹងនាំមកនូវវិនិយោគទុន មិនថាពីប្រទេសសមាជិក និងប្រទេសមិនមែនជាសមាជិកឡើយ។ ប្រទេសកំពុងអភិវឌ្ឍន៍ជាប្រទេសដែលមានថ្លៃពលកម្មទាប បើធៀបនឹងប្រទេសអភិវឌ្ឍន៍។ ក្នុងលក្ខខណ្ឌអំណោយផលបែបនេះ វាទាក់ទាញអ្នកវិនិយោគនៃប្រទេសដទៃដើម្បីចូលមកវិនិយោគក្នុងប្រទេសកំពុងអភិវឌ្ឍន៍ដើម្បីនាំចេញយកទៅលក់នៅប្រទេសកំពុងអភិវឌ្ឍន៍។ ឧទាហរណ៍ជាក់ស្តែង នាពេលបច្ចុប្បន្ន អ្នកវិនិយោគទុនចិនជាច្រើនបានមកធ្វើការវិនិយោគលើវិស័យវាយនភ័ណ្ឌនៅកម្ពុជា ផលិតជាសម្លៀកបំពាក់នាំចេញទៅក្រៅប្រទេសដោយហេតុថាប្រទេសកម្ពុជាជាប្រទេសកំពុងអភិវឌ្ឍន៍ដែលទទួលបានការលើកលែងពន្ធគយពីសំណាក់ប្រទេសអភិវឌ្ឍន៍ ហើយប្រទេសនេះក៏ជាសមាជិកនៃសមាហរណកម្មអាស៊ានដែលជាសមាហរណកម្មមួយដ៏សំខាន់នៅក្នុងតំបន់ និងនៅលើឆាកអន្តរជាតិផងដែរ។

ដូចដែលទិន្នន័យនៅក្នុងតារាងទី ៦ បង្ហាញ FDI inflow នៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍មានប្រមាណ ៧៥២ ពាន់លានដុល្លាអាមេរិក នៅឆ្នាំ ២០១៥ កើនឡើងចំនួន ៤៨ ពាន់លានដុល្លាបើធៀបនឹងឆ្នាំ ២០១៤ ដែលមានអត្រាកំណើនប្រមាណ ៧%។ យ៉ាងណាមិញនៅឆ្នាំ ២០១៦ មានការធ្លាក់ចុះប្រមាណជា -១៤% ដោយសារតែការញាំញីដោយអំពើភាវរកម្មនៅទូទាំងពិភពលោក, ការប្រែប្រួល

នយោបាយពាណិជ្ជកម្មរបស់សហរដ្ឋអាមេរិក ក៏ដូចជាព្រឹត្តិការណ៍ Brexit[24] នៅក្នុងសហភាពអឺរ៉ុបផងដែរ។

តារាងទី ៦ ៖ ទំហំ និងអត្រាវិនិយោគទុនក្រៅប្រទេសដែលចូលមកក្នុងប្រទេស ពីឆ្នាំ ២០១៤ ដល់ ២០១៦ (គិតជា ពាន់លានដុល្លាអាមេរិក និង %)

**Table I.1. FDI inflows by group of economies and region, 2014–2016, and projections, 2017** (Billions of dollars and per cent)

| Group of economies/region | 2014 | 2015 | 2016 | Projections 2017 |
|---|---|---|---|---|
| **World** | **1 324** | **1 774** | **1 746** | **1 670 to 1 870** |
| **Developed economies** | **563** | **984** | **1 032** | **940 to 1 050** |
| Europe | 272 | 566 | 533 | 560 |
| North America | 231 | 390 | 425 | 360 |
| **Developing economies** | **704** | **752** | **646** | **660 to 740** |
| Africa | 71 | 61 | 59 | 65 |
| Asia | 460 | 524 | 443 | 515 |
| Latin America and the Caribbean | 170 | 165 | 142 | 130 |
| **Transition economies** | **57** | **38** | **68** | **75 to 85** |
| *Memorandum:* annual growth rate (per cent) | | | | |
| **World** | **-8** | **34** | **-2** | **(-4 to 7)** |
| **Developed economies** | **-18** | **75** | **5** | **(-9 to 2)** |
| Europe | -20 | 108 | -6 | ~5 |
| North America | -15 | 69 | 9 | ~-15 |
| **Developing economies** | **4** | **7** | **-14** | **(2 to 15)** |
| Africa | -4 | -14 | -3 | ~10 |
| Asia | 9 | 14 | -15 | ~15 |
| Latin America and the Caribbean | -3 | -3 | -14 | ~-10 |
| **Transition economies** | **-33** | **-34** | **81** | **(10 to 25)** |

*Source:* ©UNCTAD, FDI/MNE database (www.unctad.org/fdistatistics).

### ២.២.៣. ការកើនឡើងនៃជំនាញ

សមាហរណកម្មជាមួយប្រទេសអភិវឌ្ឍន៍ និងការហូរចូលនៃការវិនិយោគពីក្រៅប្រទេសនឹងបង្កើននូវបរិមាណផលិតផលសរុបរបស់ប្រទេស។ ការបង្កើននូវការផលិតនេះ និងនាំមកនូវសេដ្ឋកិច្ចនៃមាត្រដ្ឋាន(Economy of Scale)[25]ដល់ប្រទេសកំពុងអភិវឌ្ឍន៍ ក៏ដូចជាធ្វើឲ្យប្រទេសនេះកាន់តែពង្រឹងនូវជំនាញរបស់ខ្លួនផងដែរ។ បន្ទាប់មកទៀត ការសម្រេចបាននូវសេដ្ឋកិច្ចនៃមាត្រដ្ឋាន

[24] Brexit ជាព្រឹត្តិការណ៍ដែលប្រជាជននៃចក្រភពអង់គ្លេសសម្រេចធ្វើប្រជាមតិដកចក្រភពអង់គ្លេសចេញពីសហភាពអឺរ៉ុបដែលវាជារបត់សេដ្ឋកិច្ចមួយដ៏ធំក្នុងសេដ្ឋកិច្ចសហភាពអឺរ៉ុប និងពិភពលោកទាំងមូលផងដែរ។

[25] សេដ្ឋកិច្ចនៃមាត្រដ្ឋាន(Economy of Scale) សម្តៅទៅលើបែបបទនៃសេដ្ឋកិច្ចដែលថ្លៃដើមធ្លាក់ចុះនៅពេលដែលឯកតាផលិតកើនឡើង។

ក្នុងរយៈពេលដ៏សមរម្យមួយនឹងធ្វើឲ្យប្រទេសកំពុងអភិវឌ្ឍន៍សម្រេចបាននូវសេដ្ឋកិច្ចនៃបទពិសោធន៍មួយទៀត(Economy of Experience)[26]។ ការកើនឡើងនៃសេដ្ឋកិច្ចនៃបទពិសោធន៍នឹងធ្វើឲ្យប្រទេសអភិវឌ្ឍន៍កាន់តែមានជំនាញទៅលើផលិតផលណាមួយដែលខ្លួនមានជំនាញស្រាប់ ហើយវានឹងធ្វើឲ្យសេដ្ឋកិច្ចជាតិកើនឡើងយ៉ាងគួរឲ្យទុកចិត្តក្នុងរយៈពេលវែងជាតិផងដែរ។

**២.២.៤. ការកើនឡើងនៃទម្ងន់នៃការចរចារ** ( Increase of Bargaining power )

ប្រទេសកំពុងអភិវឌ្ឍន៍ជាប្រទេសដែលទន់ខ្សោយទាំងផ្នែកសេដ្ឋកិច្ច និងនយោបាយ។ នៅលើឆាកអន្តរជាតិ ជាពិសេសនៅក្នុងកិច្ចប្រជុំ ប្រទេសកំពុងអភិវឌ្ឍន៍មិនសូវត្រូវបានគេយកចិត្តទុកដាក់ប៉ុន្មានទេ បើទោះបីជាអ្វីដែលប្រទេសកំពុងអភិវឌ្ឍន៍កំពុងធ្វើ និងនិយាយមានផលប្រយោជន៍ទៅដល់ការអភិវឌ្ឍន៍នៃសេដ្ឋកិច្ចអន្តរជាតិយ៉ាងណាក៏ដោយ។ ដោយឡែក តាមរយៈសមាហរណកម្មសេដ្ឋកិច្ច និងការដែលប្រទេសកំពុងអភិវឌ្ឍន៍ចូលរួមជាមួយគ្នាជាក្រុមប្រទេស ធ្វើឲ្យសម្លេងរបស់ក្រុមប្រទេសកំពុងអភិវឌ្ឍន៍ត្រូវបានគេយកចិត្តទុក ព្រោះចង់ ឬមិនចង់ប្រទេសកំពុងអភិវឌ្ឍន៍មិនមែនមានតែឯងដូចលើកមុនឡើយ។ ជាក់ស្តែង ការចូលទៅក្នុងសមាជិកអាស៊ានរបស់ប្រទេសកម្ពុជាបានធ្វើឲ្យប្រទេសកំពុងអភិវឌ្ឍន៍មួយនេះហាក់ដូចជាមានទម្ងន់ជាងមុននៅលើឆាកអន្តរជាតិ ពោលគឺកម្ពុជាអាចនិយាយទៅកាន់ពិភពលោក ហើយក៏អាចធ្វើការសម្រេចចិត្ត ក្នុងនាមជាសមាជិកអាស៊ានដែលមាន ១០ប្រទេស និងតំណាងឲ្យប្រជាជនប្រមាណជា ៧០០លាននាក់នោះឯង។ មួយវិញទៀតនៅក្នុងក្របខណ្ឌ WTO ក៏មានការបែងចែកគ្នារវាងក្រុមប្រទេសអភិវឌ្ឍន៍ និងក្រុមប្រទេសកំពុងអភិវឌ្ឍន៍ដូចគ្នា។ យើងអាចឃើញយ៉ាងច្បាស់នៅក្នុងការចរចារនៅជុំ DOHA Round ដែលក្រុមប្រទេសទាំង ២មិនយល់ព្រមទៅលើការធ្វើសមាហរណកម្មលើផ្នែកឧស្សាហកម្ម និងកសិកម្ម។ យ៉ាងណាមិញ គេសង្កេតឃើញថា ក្នុងពេលបច្ចុប្បន្ននេះមានការកើនឡើងនូវឥទ្ធិពលរបស់ក្រុមប្រទេស BRIC(ប្រេស៊ីល, រុស្ស៊ី, ឥណ្ឌា, និងចិន) ដែលដើរតួជាអ្នកដឹកនាំ និងចរចារឲ្យក្រុមប្រទេសកំពុងអភិវឌ្ឍន៍នៅក្នុង WTO នេះផងដែរ។

[26] សេដ្ឋកិច្ចនៃបទពិសោធន៍(Economy of Experience) សម្តៅលើការកើនឡើងនៃផលិតកម្មនៅពេលដែលពលកម្មមានបទពិសោធន៍កាន់តែច្រើន

ក្រាហ្វិកទី ៥ ៖គំនូសបំព្រួញនៃការកើនឡើងនូវទម្ងន់នៃការចរចារ







## ២.៣. ផលអវិជ្ជមានរបស់ប្រទេសកំពុងអភិវឌ្ឍន៍ចូលសមាហរណកម្មសេដ្ឋកិច្ច

ថ្វីត្បិតតែ សមាហរណកម្មអាចនាំមកនូវផលប្រយោជន៍ដូចដែលបានរៀបរាប់មកខាងលើ ពិតមែនក្តី តែវាក៏អាចនាំជាផលអវិជ្ជមានទៅដល់ប្រទេសកំពុងអភិវឌ្ឍន៍ដូចគ្នា។

### ២.៣.១. ការបង្វែរពាណិជ្ជកម្ម (Trade Diversion)

ការបង្វែរពាណិជ្ជកម្ម គឺជាស្ថានភាពមួយដែលសមាហរណកម្មបានបង្វែរប្រទេសពីការទទួលយកការផ្គត់ផ្គង់ដែលមានតម្លៃទាប ទៅរកការផ្គត់ផ្គង់ដែលមានតម្លៃខ្ពស់ជាងមុន។ និយាយឲ្យស្រួលស្តាប់គឺ ឈប់ឲ្យប្រទេសសមាហរណកម្មរកស៊ីជាមួយប្រទេសដែលមានកម្រិតនៃថ្លៃទំនិញ ឬសេវាកម្មទាប ហើយងាកទៅរកស៊ីជាមួយប្រទេសដែលមានតម្លៃទំនិញ និងសេវាកម្មខ្ពស់ជាង ដែលជាកំហាតនៃសេដ្ឋកិច្ច។ ក្នុងលក្ខខណ្ឌដែលសមាហរណកម្មសេដ្ឋកិច្ចនាំមកនូវការបង្កើតពាណិជ្ជកម្មជារឿងមួយល្អ ប៉ុន្តែបើការធ្វើសមាហរណកម្មសេដ្ឋកិច្ចនាំមកនូវការបង្វែរពាណិជ្ជកម្មវិញនោះ វានឹងនាំមកនូវផលវិបាកទៅវិញទេសម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍។ ប្រទេសកំពុងអភិវឌ្ឍន៍ថ្វីត្បិតតែជាប្រទេសដែលប្រឹងប្រែងនាំចេញច្រើនក៏ពិតមែន ប៉ុន្តែពួកគេក៏ត្រូវការនាំចូលនូវទំនិញមួយចំនួនដែលមិនអាចផលិតបាននៅក្នុងស្រុកផងដែរ។ ដូច្នេះហើយ ប្រសិនបើសមាហរណកម្មសេដ្ឋកិច្ចនាំប្រទេសកំពុងអភិវឌ្ឍន៍ឆ្ពោះទៅរកការបង្វែរសេដ្ឋកិច្ចដូចដែរបានរៀបរាប់ខាងលើនេះ ច្បាស់ណាស់ វាជាកំហាតរបស់សេដ្ឋកិច្ចប្រទេសទៅវិញទេ ព្រោះប្រទេសនេះនឹងជួបនូវបញ្ហាការឡើងនៃកម្រិតថ្លៃដែលប៉ះពាល់ដល់ជីវភាពប្រជាជន ក៏ដូចជាផលិតកម្មរបស់ក្រុមហ៊ុនឯកជន។

### ២.៣.២. ការបាត់បង់ចំណូលពន្ធ

ពិតណាស់ថា ការចូលទៅក្នុងសមាហរណកម្មវាអាចមានប្រយោជន៍ដល់វិស័យឯកជនច្រើនថ្វីបើ ការអភិវឌ្ឍន៍វិស័យឯកជនគឺជាបំណងសំខាន់របស់រដ្ឋដើម្បីទ្រទ្រង់ដល់ខឿនសេដ្ឋកិច្ចជាតិ។ យ៉ាងណាមិញ ចំពោះរដ្ឋខ្លួនឯងផ្ទាល់ ក៏ទទួលរងនូវភាពអវិជ្ជមានពីសមាហរណកម្មសេដ្ឋកិច្ចផងដែរ។ ចំណូលរបស់រដ្ឋនៃប្រទេសកំពុងអភិវឌ្ឍន៍មួយភាគធំអាស្រ័យទៅលើពន្ធ ដែលមានដូចជាពន្ធនាំចូល, ពន្ធលើប្រាក់បៀវត្សន៍, ពន្ធអាជីវកម្ម និងពន្ធតម្លៃបន្ថែមជាដើម។ នៅពេលដែលមានការទម្លាក់ ឬលុបបំបាត់ចោលនូវពន្ធនាំចូល សមាហរណកម្មសេដ្ឋកិច្ចធ្វើឲ្យមានការថយចុះ ឬបាត់បង់ចំណូលពន្ធនាំចូល បើទោះបីជាសមាហរណកម្មនេះត្រូវបានធ្វើឡើងដោយផ្នែកក្តី។ ការបាត់បង់ចំណូលពន្ធនាំចូល ឬការធ្លាក់ចុះនៃការប្រមូលពន្ធ(បើនិយាយជារួម)នឹងធ្វើឲ្យរដ្ឋរិះរកវិធីផ្សេងៗដើម្បីមកគ្រប់គ្រងតុល្យការចំណាយរបស់ខ្លួន ដែលក្នុងករណីនេះរដ្ឋអាច ខ្ចីកម្ចីពីបរទេស, លក់នូវធនធានដែលខ្លួនមាន[27], បង្កើនអត្រាពន្ធទៅលើពន្ធដទៃទៀតដែលមាន, ឬបង្កើតការយកពន្ធទៅលើផលិតផល ឬសេវាកម្មណាមួយដែលមិនធ្លាប់យកពីមុនមក។ ការសម្រេចចិត្តជ្រើសរើសវិធីណា

[27] ព្រោះចំណូលរបស់រដ្ឋមាន ២គឺៈចំណូលជាពន្ធ និងចំណូលមិនមែនពន្ធ(ការធ្វើអាជីវកម្មលើធនធានដែលមាន ឬក្រុមហ៊ុនរដ្ឋ)

មួយក្នុងចំណោមវិធីខាងលើ នឹងបង្កើតបានជាឥទ្ធិពលទៅលើប្រព័ន្ធពន្ធ និងប្រព័ន្ធសេដ្ឋកិច្ចប្រទេសក្នុងរយៈពេលវែង ហើយវានឹងអាចប៉ះពាល់ដល់ផលប្រយោជន៍របស់ក្រុមហ៊ុនឯកជនក្នុងស្រុកមួយចំនួនដែលត្រូវបានគេយល់ឃើញថាជាការបាត់បង់នៅក្នុងសមាហរណកម្មផងដែរ។

**២.៣.៣. កំណែទម្រង់ស្ថាប័ន**

ការធ្វើសមាហរណកម្មសេដ្ឋកិច្ចទាមទារជាចាំបាច់ក្នុងការមានដូចគ្នា ឬស្រដៀងគ្នានូវប្រព័ន្ធគ្រប់គ្រង ប្រព័ន្ធរដ្ឋបាល ប្រព័ន្ធគណនេយ្យ និងប្រព័ន្ធអាជីវកម្មផ្សេងៗទៀត។ ដូចនេះការចូលខ្លួនទៅក្នុងសមាហរណកម្មទាមទារដាច់ខាតឲ្យប្រទេសដែលជាសមាជិកធ្វើការបង្កើតនូវប្រព័ន្ធស្តង់ដារមួយដែលអាចប្រើប្រាស់បាននៅគ្រប់ប្រទេសដែលជាសមាជិក។ ចំពោះប្រទេសអភិវឌ្ឍន៍ប្រព័ន្ធគ្រប់គ្រង និងរដ្ឋបាលរបស់គេភាគច្រើនត្រូវបានចងក្រងប្រទាក់ក្រឡាគ្នាបានយ៉ាងល្អពីផ្នែកមួយទៅផ្នែក ដែលវាធ្វើឲ្យមានភាពងាយស្រួលក្នុងការធ្វើកំណែទម្រង់នៅត្រង់ចំណុចណាមួយដែលចាំបាច់។ យ៉ាងណាមិញប្រព័ន្ធគ្រប់គ្រង ក៏ដូចជាប្រព័ន្ធរដ្ឋបាលនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍នៅមានចន្លោះប្រហោងច្រើន អាចមានភាពស្មុគស្មាញដែលពិបាកនឹងធ្វើការកែប្រែ ពោលគឺគេត្រូវកែប្រែម្តងមួយចំណុចៗ បន្តិចម្តងៗយូរខែឆ្នាំ ទើបអាចទទួលបានលទ្ធផលប្រសើរមួយ។ ម៉្យាងវិញទៀត ប្រព័ន្ធគ្រប់គ្រងនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ភាគច្រើនជាប្រព័ន្ធដែលមិនទាន់សម័យដែលខុសពីប្រព័ន្ធគ្រប់គ្រងរបស់ប្រទេសអភិវឌ្ឍន៍ដែលមានប្រើប្រាស់នូវបច្ចេកវិទ្យា និងប្រព័ន្ធពត៌មានវិទ្យាជាជំនួយ។ ដូចនេះដើម្បីឲ្យមានភាពស៊ីចង្វាក់គ្នា ចង់ ឬមិនចង់ប្រទេសកំពុងអភិវឌ្ឍន៍ចាំបាច់ត្រូវធ្វើកំណែទម្រង់លើប្រព័ន្ធរបស់ខ្លួនដែលវាអាចមានផលប៉ះពាល់ ព្រោះវាអាចថ្មីខ្លាំងពេកសម្រាប់មន្ត្រីរបស់ខ្លួនដែលពិបាកយល់ និងពិបាកសម្របខ្លួន ហើយនិងត្រូវចំណាយលុយ និងពេលវេលាច្រើនក្នុងការធ្វើកំណែទម្រង់ប្រព័ន្ធគ្រប់គ្រងនេះ។

## ៣. សមាហរណកម្មសេដ្ឋកិច្ចរបស់ប្រទេសកំពុងអភិវឌ្ឍន៍នៅក្នុងអង្គការសេដ្ឋកិច្ច និងប្លុកសេដ្ឋកិច្ចធំៗ

ក្រោយពីការបញ្ចប់ទៅនៃយុគនៃអាណានិគម មានប្រទេសកំពុងអភិវឌ្ឍន៍ជាច្រើនលេចមុខមកទាមទារនូវសំណង និងការទទួលខុសត្រូវពីប្រទេសអតីតអាណានិគម។ យ៉ាងណាមិញ ប្រទេសអតីតអាណានិគមហាក់មិនខ្វល់ខ្វាយពីការទាមទាររបស់ប្រទេសកំពុងអភិវឌ្ឍន៍ទេ។ លុះក្រោយសង្គ្រាមត្រជាក់ គេសង្កេតឃើញមានការកើនឡើងនូវចំនួនប្រទេស ដែលប្រទេសខ្លះបានប្រកាសខ្លួនជាប្រទេសកំពុងអភិវឌ្ឍន៍ និងជាប្រទេសដែលបានផ្តាច់ខ្លួនពីប្រទេសអតីតសមាជិកសូវៀត។ គឺក្នុងពេលនេះហើយដែលគេសង្កេតឃើញប្រទេសកំពុងអភិវឌ្ឍន៍ជាច្រើនចាប់ផ្តើមភ្ជាប់ខ្លួនទៅនឹងសមាហរណកម្មសេដ្ឋកិច្ចក្នុងតំបន់ ឬអង្គការសេដ្ឋកិច្ចពិភពលោក តួយ៉ាងអង្គការពាណិជ្ជកម្មពិភពលោកយ៉ាងស៊ីជម្រៅជាងពេលណាៗទាំងអស់។ វាមិនមែនជាការចៃដន្យនោះទេដែលប្រទេសកំពុងអភិវឌ្ឍន៍សមាហរណកម្មខ្លួនទៅក្នុងប្លុកសេដ្ឋកិច្ច ឬអង្គការសេដ្ឋកិច្ចនោះ។ ស្របពេលដែលក្រុមប្រទេសកំពុងអភិវឌ្ឍន៍ព្យាយាមយកឲ្យបាននូវសមាជិកភាពនៅក្នុងសមាហរណកម្មទាំងនោះ ប្លុកសេដ្ឋកិច្ច និងសមាហរណកម្មទាំងនោះក៏បានបើកទ្វារទទួលក្រុមប្រទេសកំពុងអភិវឌ្ឍន៍ផងដែរ មិនដូចពេលមុនដែលពួកគេប្រកាន់ខ្ជាប់នូវលក្ខខណ្ឌតឹងរឹង មិនព្រមឲ្យក្រុមប្រទេសកំពុងអភិវឌ្ឍន៍ចូលនោះទេ។ នេះជារបត់សេដ្ឋកិច្ចអន្តរជាតិដ៏សំខាន់មួយដែលប្រទេសទាំងអស់ដឹងពីសារៈសំខាន់នៃប្រទេសអភិវឌ្ឍន៍ ក៏ដូចជាប្រទេសកំពុងអភិវឌ្ឍន៍ ហើយពួតដៃគ្នាកសាងពិភពលោកដ៏សន្តិភាព និងប្រកបដោយសហប្រតិបត្តិការមួយជាមួយគ្នា។

ដូចដែលតារាងទី ៧ បានបង្ហាញនៅខាងក្រោមនេះ យើងសង្កេតឃើញថា មានប្រទេសជាច្រើនបានចូលក្នុងGATT និងWTOនៅចន្លោះឆ្នាំ ១៩៩០ និង២០០០ ពោលគឺនៅក្រោយសង្គ្រាមត្រជាក់ត្រូវបានបញ្ចប់ ដែលនេះយើងមិនអាចបដិសេធនូវហេតុផលនយោបាយដែលជម្រុញឲ្យមានការចូលរួមសមាហរណកម្មនោះបានទេ។

## តារាងទី ៧៖ សមាជិកភាពថ្មីរបស់ GATT និង WTO ចាប់ពីឆ្នាំ ១៩៨៥ ដល់ ២០១០

**TABLE 2.4**

**New Members of the General Agreement on Tariffs and Trade/World Trade Organization, 1985–2010**

| | | | |
|---|---|---|---|
| Albania | 2000 | Latvia | 1999 |
| Angola | 1994 | Lesotho | 1998 |
| Antigua and Barbuda | 1987 | Liechtenstein | 1994 |
| Armenia | 2003 | Lithuania | 2001 |
| Bahrain | 1993 | Macao | 1991 |
| Botswana | 1987 | Mali | 1993 |
| Brunei Darussalam | 1993 | Mexico | 1986 |
| Bulgaria | 1996 | Moldova | 2001 |
| Cambodia | 2004 | Mongolia | 1997 |
| Cape Verde | 2008 | Morocco | 1987 |
| China | 2001 | Mozambique | 1992 |
| Chinese Taipei | 2002 | Namibia | 1992 |
| Costa Rica | 1990 | Nepal | 2004 |
| Croatia | 2000 | Oman | 2000 |
| Djibouti | 1994 | Panama | 1997 |
| Dominica | 1993 | Papua New Guinea | 1994 |
| Ecuador | 1996 | Paraguay | 1994 |
| El Salvador | 1991 | Qatar | 1994 |
| Estonia | 1999 | Saint Kitts and Nevis | 1994 |
| Fiji | 1993 | Saint Lucia | 1993 |
| Former Yugoslavia Republic of Macedonia | 2003 | Saint Vincent and the Grenadines | 1993 |
| | | Saudi Arabia | 2005 |
| Georgia | 2000 | Slovak Republic | 1993 |
| Grenada | 1994 | Slovenia | 1994 |
| Guatemala | 1991 | Solomon Islands | 1994 |
| Guinea | 1994 | Swaziland | 1993 |
| Guinea Bissau | 1994 | Tonga | 2007 |
| Honduras | 1994 | Ukraine | 2008 |
| Hong Kong | 1986 | United Arab Emirates | 1994 |
| Jordan | 2000 | Venezuela | 1990 |
| Kyrgyz Republic | 1998 | Vietnam | 2007 |

*Source:* World Trade Organization (wto.org).

# ជំពូកទី៣

# កំណែទម្រង់គោលនយោបាយសារពើពន្ធ - ករណីសិក្សាប្រទេសកម្ពុជា

ទោះបីជាប្រទេសកំពុងអភិវឌ្ឍន៍ប្រើប្រាស់ម៉ូឌែលសេដ្ឋកិច្ចទីផ្សារសេរីដូចជ មានលក្ខខណ្ឌទូទៅដូចគ្នាមួយចំនួនក្តី យ៉ាងណាមិញលក្ខខណ្ឌលម្អិតនៃគោលនយោបាយសារពើពន្ធ លក្ខខណ្ឌសេដ្ឋកិច្ច និងកម្មវិធីកំណែទម្រង់គោលនយោបាយសារពើពន្ធរបស់ប្រទេសពួកគេមានភាពខុសគ្នាពីមួយទៅមួយហើយមិនអាចនិយាយជារួមនោះទេ ដែលនេះជាហេតុដែលការស្រាវជ្រាវនេះត្រូវលើកយកប្រទេសណាមួយមកធ្វើជាករណីសិក្សាតែម្តង់ ពោលគឺប្រទេសកម្ពុជា។

## ១. សមាហរណកម្មសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា

សមាហរណកម្មរបស់ប្រទេសកម្ពុជាចូលទៅក្នុងពិភពលោកត្រូវបានគេចាប់ផ្តើមរាប់ចាប់ពីឆ្នាំ១៩៨៩ គឺឆ្នាំដែលរដ្ឋាភិបាលរបស់ប្រទេសកម្ពុជាចាប់ផ្តើមស្វែងរកការផ្សះផ្សារជាតិ និងទទួលយកកងទ័ពមួកខៀវរបស់អង្គការសហប្រជាជាតិចូលមកស្វែងរកសន្តិភាពនៅក្នុងប្រទេស។ មុខមាត់របស់ប្រទេសកម្ពុជាត្រូវបានផ្លាស់ប្តូរកាន់តែខ្លាំងនៅពេលដែលប្រទេសចូលជាសមាជិកអាស៊ាននៅថ្ងៃទី ៣០ មេសា ឆ្នាំ១៩៩៩។ ក្រោយពីការចូលជាសមាជិកនេះហើយ កម្ពុជានៅតែបន្តធ្វើសមាហរណកម្មកាន់តែស៊ីជម្រៅបន្ថែមទៀតទៅក្នុងអន្តរជាតិ។ បន្ទាប់ពីការដាក់ពាក្យស្នើសុំធ្វើជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោកនៅថ្ងៃទី ២២ កក្កដា ឆ្នាំ២០០៣ កម្ពុជាក៏បានក្លាយជាសមាជិកនៃ WTO យ៉ាងពេញលេញនៅថ្ងៃទី ១៣ តុលា ២០០៤ ក្រោយពីរដ្ឋាភិបាលកម្ពុជាបានធ្វើសច្ចានុម័តគោរព និងធ្វើតាមលក្ខខ័ណ្ឌរបស់អង្គការនេះ។ ក្រៅពីសមាហរណកម្មសេដ្ឋកិច្ចធំៗទាំង ២នេះកម្ពុជាក៏បានបន្តចូលទៅក្នុងសមាហរណកម្មសេដ្ឋកិច្ច និងនយោបាយផ្សេងទៀតជាបន្តបន្ទាប់។ យ៉ាងណាមិញដើម្បីឲ្យបានផលចំណេញអប្បបរមា និងងាយស្រួលក្នុងការធ្វើគោលនយោបាយជាតិឲ្យប្រសិទ្ធិភាពស្របនឹងសមាហរណកម្មនោះ កម្ពុជាបានផ្តល់អាទិភាព[28]ទៅលើសមាហរណកម្មក្នុងតំបន់ និងក្នុងពិភពលោកដូចខាងក្រោម៖

- សមាហរណកម្មតំបន់ និងអនុតំបន់៖
  1. អាស៊ាន(អាទិភាពជាពិសេស)
  2. កម្មវិធីមហាអនុតំបន់មេគង្គ (GMS)
  3. តំបន់អភិវឌ្ឍន៍ត្រីកោណ កម្ពុជា-ឡាវ-វៀតណាម និង កម្ពុជា-ឡាវ-ថៃ

[28] ដកស្រង់ចេញពី «យុទ្ធសាស្ត្រចតុកោណ» ដំណាក់កាលទី ១»

4. យុត្តិសាស្ត្រសហប្រតិបត្តិការសេដ្ឋកិច្ចរវាង កម្ពុជា ឡាវ មីយ៉ាន់ម៉ា និងថៃ
5. ទស្សនទាន «ប្រទេសបួន-សេដ្ឋកិច្ចមួយ»
6. កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចអាយ៉ាវឌី-ចាវប្រ៉ាយ៉ា-មេគង្គ (ACMECS)[29]
7. កិច្ចប្រជុំអាស៊ី-អឺរ៉ុប (ASEM)[30]

❖ សមាហរណកម្មអន្តរជាតិ៖

1. តំបន់ពាណិជ្ជកម្មសេរីអាស៊ាន
2. អង្គការពាណិជ្ជកម្មអន្តរជាតិ
3. អង្គការសហប្រតិបត្តិការសេដ្ឋកិច្ចអាស៊ី-ប៉ាស៊ីហ្វិក (APEC)[31]

## ២. លក្ខខណ្ឌទូទៅនៃប្រព័ន្ធម៉ាក្រូសេដ្ឋកិច្ចប្រទេសកម្ពុជា ឆ្នាំ ២០០៨ ដល់ ២០១៧

បច្ចុប្បន្ន ប្រទេសកម្ពុជា ជាប្រទេសកំពុងអភិវឌ្ឍន៍មួយនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ ដែលមានប្រជាជនប្រមាណ ១៦លាននាក់។ ក្រោយការកែប្រែស្ថានការណ៍បន្ទាប់ពីមានការធ្លាក់ចុះនូវកំណើនសេដ្ឋកិច្ចក្នុងស្រុកនៅក្នុងឆ្នាំ ២០០៨ (ដោយសារវិបត្តិសេដ្ឋកិច្ចអន្តរជាតិ) ក្នុងរយៈពេល ៥ ឆ្នាំចុងក្រោយនេះ រដ្ឋាភិបាលនៃប្រទេសកម្ពុជាបានសម្រេចបាននូវកំណើនសេដ្ឋកិច្ចដែលមានភាពគួរឲ្យជឿជាក់មួយដែលស្ថិតនៅរង្វង់ ៧% ប្រកបដោយសមធម៌។ ក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ចនេះ វាបានពឹងផ្អែកទៅលើភាពរឹងមាំនៃវិស័យមួយចំនួនដូចជា៖ វិស័យសំណង់, ការបន្តកំណើននៃវិស័យកាត់ដេរ និងវិស័យកសិកម្ម, ការស្ទុះងើបឡើងនៃវិស័យទេសចរណ៍, និងវិស័យពាណិជ្ជកម្មជុំ និងរាយ។ ជាមួយគ្នានេះផងដែរ សមាជិកអាស៊ានមួយនេះ បានឆ្លងកាត់ដំណាក់កាលជាប្រវត្តិសាស្ត្រមួយនៅឆ្នាំ ២០១៥ ដែលបានប្រែក្លាយមុខមាត់ប្រទេសពី ប្រទេសដែលមានចំណូលទាប ទៅជាប្រទេសមានចំណូលមធ្យមកម្រិតទាប (ផលិតផលក្នុងស្រុកសរុប ឬផសស គិតក្នុងមនុស្សម្នាក់បានកើនឡើងពី ១ ០៤២ ដុល្លាអាមេរិក នៅឆ្នាំ ២០១៣ ទៅ ១ ៤៣៥ ដុល្លាអាមេរិកនៅឆ្នាំ ២០១៧) ហើយក៏ត្រូវបានគេប្រសិទ្ធនាមថាជា «ខ្លាសេដ្ឋកិច្ចអាស៊ី» នៅឆ្នាំ ២០១៦ ទៀតផង។ តាមស្ថិតិរបស់ធនាគារពិភពលោក អត្រានៃភាពក្រីក្រនៅក្នុងប្រទេសកម្ពុជានៅក្នុងឆ្នាំ ២០១៧ មានប្រមាណ ០.៣% ហើយ និងបានលុបចោលនូវភាពក្រីក្រគោកយ៉ាកទាំងស្រុងនៅក្នុងឆ្នាំ ២០១៧នេះផងដែរ។

[29, 28, 29] ដកស្រង់ចេញពី «យុទ្ធសាស្ត្រចតុកោណ» ដំណាក់កាលទី ២

ហិរញ្ញវត្ថុសាធារណៈកម្ពុជាក៏មានការអភិវឌ្ឍន៍គួរឲ្យកត់សម្គាល់ផងដែរ។ ក្នុងរយៈពេល ៥ ឆ្នាំចុងក្រោយនេះ ចំណូលរដ្ឋមានការកើនឡើងនៅចន្លោះពី ១៥% ទៅ ២០% ដែលក្នុងនោះចំណូលចរន្តនៃថវិកាជាតិ បានកើនឡើងពី ១៥.០៦% នៃផសសនៅឆ្នាំ ២០១៣ ទៅ ១៩.៦៥% នៃផសសក្នុងឆ្នាំ ២០១៧។ ជាមួយគ្នានេះ ថវិកាចំណាយសរុបរបស់រដ្ឋក៏បានកើនឡើងប្រមាណ ១.៨ ដង ផងដែរ។

តាមរយៈសូចនាករសេដ្ឋកិច្ចកម្ពុជាឆ្នាំ ២០០៨ យើងឃើញថាទំហំផលិតផលសរុបដុលរបស់ប្រទេសកម្ពុជាត្រូវបានគេព្យាករណ៍ថាមានប្រមាណជា ៩៩ ១១៦ ប៊ីលានរៀល ដែលមានកំណើនពិតប្រមាណ ៦.៩% ដែលមានផសស សម្រាប់មនុស្សម្នាក់កើនដល់ ១៥៦៨ ដុល្លាអាមេរិកជាមួយនឹងអតិផរណា ប្រមាណជា ៣.៥%។

តារាងទី ៨៖ សូចនាករសេដ្ឋកិច្ចប្រទេសកម្ពុជា ឆ្នាំ២០១៨

| សូចនាករសេដ្ឋកិច្ច | ២០១៦ | ២០១៧ | ២០១៨ |
|---|---|---|---|
| | អនុវត្ត | ប៉ាន់ស្មាន | ព្យាករណ៍ |
| ផសស តាមថ្លៃបច្ចុប្បន្ន (ប៊ីលានរៀល) | ៨០ ៥៥៨ | ៨៩ ៥០៩ | ៩៩ ១១៦ |
| កំណើនពិតនៃ ផសស (%) | ៧, ០% | ៦, ៩% | ៦, ៩% |
| ផសស សម្រាប់មនុស្សម្នាក់ (ដុល្លារអាមេរិក) | ១ ៣០២ | ១ ៤៣៥ | ១ ៥៦៨ |
| អតិផរណា (ជាមធ្យមប្រចាំឆ្នាំ) | ៣, ០% | ៣, ៨% | ៣, ៥% |
| អត្រាប្តូរប្រាក់ (ដុល្លារអាមេរិក/ រៀល) | ៤ ០៥៦ | ៤ ០៣៧ | ៤ ០៣៧ |
| សមតុល្យគណនីចរន្ត (% នៃ ផសស) | -៨, ៣% | -៧, ៩% | -៨, ៤% |
| ទុនបម្រុងអន្តរជាតិ (លានដុល្លារអាមេរិក) | ៦ ៧៣១ | ៩ ០៥០ | ១០ ៥១៨ |
| ទុនបម្រុងអន្តរជាតិ (ចំនួនខែនៃការនាំចូល) | ៥, ៥ | ៦, ០ | ៦, ៥ |

ប្រភពពី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុកម្ពុជា

### ២.១. ដំណាក់កាលនៃការវិវត្តន៍នៃសេដ្ឋកិច្ច

ចាប់តាំងពីការអនុវត្តន៍កំណែទម្រង់ដើម្បីផ្លាស់ប្តូរនយោបាយសេដ្ឋកិច្ចពីផែនការប្រមូលផ្តុំមកជាមូលដ្ឋានគ្រឹះនៃសេដ្ឋកិច្ចទីផ្សារសេរី ការអភិវឌ្ឍន៍សេដ្ឋកិច្ចរបស់ប្រទេសកម្ពុជាត្រូវបានបែងចែកជា ៣ដំណាក់កាលខុសៗគ្នាគឺៈ

- ដំណាក់កាលស្តារ និងនីតិសម្បទា (ឆ្នាំ១៩៨៩ ដល់១៩៩៨)
- ដំណាក់កាលស្ថាបនាឡើងវិញ (ឆ្នាំ១៩៩៩ ដល់២០០៣)
- ដំណាក់កាលហក់ឡើងនៃសេដ្ឋកិច្ច (ឆ្នាំ២០០៤ ដល់២០០៨)

### ២.២. ការប្រែប្រួលរចនាសម្ព័ន្ធសេដ្ឋកិច្ច

រចនាសម្ព័ន្ធសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជាមានការអភិវឌ្ឍន៍ជាប្រចាំ ពីពេលមួយទៅពេលមួយ។ នៅក្នុងការសិក្សាពីការការអភិវឌ្ឍន៍សេដ្ឋកិច្ចរបស់លោកបណ្ឌិត ហុង ជួន ណារ៉ុន ការអភិវឌ្ឍន៍របស់សេដ្ឋកិច្ចកម្ពុជាមានការចូលរួម ពីការធ្វើពពិធកម្មនៃវិស័យសេដ្ឋកិច្ច និងវិភាគទានយ៉ាងសំខាន់ពីវិស័យកសិកម្ម។ ប៉ុន្តែបើយើងមើលទៅលើទិន្នន័យប៉ុន្មានឆ្នាំចុងក្រោយដែលចុះផ្សាយដោយ ក្រុមធនាគារពិភពលោក យើងឃើញថាមានការប្រែប្រួលច្រើននៅក្នុងរចនាសម្ព័ន្ធសេដ្ឋកិច្ចនេះ។ តាមរយៈការបង្ហាញរបស់ក្រាហ្វិកទី ៦ យើងឃើញថា ភាពសំខាន់នៃវិស័យវាយនភណ្ឌ និងវិស័យកសិកម្មត្រូវបានថយចុះ ហើយវាជំនួសមកវិញនូវការកើនឡើងនៃវិស័យសេវាកម្ម និងវិស័យសំណង់ ក្នុងខណៈពេលដែលការអភិវឌ្ឍន៍សេដ្ឋកិច្ចរក្សាបាននៅរង្វង់ ៧%ដដែល។

ក្រាហ្វិកទី ៦៖ ការចូលរួមនៃវិស័យផ្សេងៗក្នុងការកើនឡើងនៃ GDP ប្រទេសកម្ពុជា (គិតពីឆ្នាំ ២០១០ ដល់២០១៦)




ប្រភព៖ ក្រុមធនាគារពិភពលោក ២០១៧

## ៣. ប្រព័ន្ធសារពើពន្ធកម្ពុជា

បើតាមមាត្រា ១៦ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈនៃប្រទេសកម្ពុជា «ពន្ធអាករ និងចំណូលសារពើពន្ធផ្សេងៗ ត្រូវបានកំណត់ដោយច្បាប់ និងត្រូវប្រមូល និងត្រួតពិនិត្យដោយរដ្ឋមន្ត្រីក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ អត្រាពន្ធ អាករ មូលដ្ឋានជាប់ពន្ធ ការលើកលែងពន្ធ និងវិវាទដែលទាក់ទងនឹងការកំណត់ការប្រមូល និងការត្រួតពិនិត្យពន្ធ ត្រូវកំណត់នៅក្នុងក្របខ័ណ្ឌ និងតាមបែបបទដែលមានចែងនៅក្នុងច្បាប់ដែលទាក់ទងដល់ប្រភេទពន្ធ និងអាករនីមួយៗ»[32]។ ការប្រមូលពន្ធរបស់កម្ពុជាចូលថវិការដ្ឋចែកជា ២ធំៗ គឺ៖ ពន្ធគយ(Custom ឬ Tariff) និងពន្ធដារ(Taxtion)។ ក្នុងនោះ ពន្ធគយស្ថិតនៅក្រោមសមត្ថកិច្ចរបស់អគ្គនាយកដ្ឋានពន្ធគយ និងរដ្ឋាករកម្ពុជា ហើយពន្ធដារស្ថិតនៅក្រោមសមត្ថកិច្ចរបស់អគ្គនាយកដ្ឋានពន្ធដារ ដែលអគ្គនាយកដ្ឋានទាំង ២នេះស្ថិតនៅក្នុងការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុរបស់កម្ពុជា។

[32] ដកស្រង់ចេញពីសៀវភៅ «សេដ្ឋកិច្ចកម្ពុជា» មាគ៌ាឆ្ពោះទៅរកអនាគតដ៏ភ្លឺស្វាង វឌ្ឍនភាព បញ្ហាប្រឈម និង ទស្សនវិស័យទៅអនាគត របស់លោកបណ្ឌិត ហង់ ជួន ណារ៉ុន ឆ្នាំ២០១៥

### ៣.១. ពន្ធគយ

ពន្ធគយគឺជាពន្ធបន្ថែមអាករ កម្រៃ ឬបន្ទុកផ្សេងទៀតដែលយកលើទំនិញស្របតាមបញ្ញត្តិណាមួយនៃច្បាប់ និងបទបញ្ញត្តិផ្សេងទៀតដែលអនុញ្ញាត និងគ្រប់គ្រងដោយគយ[33]។ និយាយឲ្យខ្លីនិងស្រួលយល់ ពន្ធគយនេះគឺជាពន្ធនាំចូល ដែលត្រូវបានគេគិតតាមរូបមន្ត ២ ផ្សេងគ្នាគឺ ពន្ធដែលត្រូវបានគេគិតតាមតម្លៃ (Ad Valorem Duty) និងពន្ធដែលគិតតាមឯកតា។ ពន្ធនេះត្រូវស្ថិតនៅក្រោមសមត្ថកិច្ចរបស់អគ្គនាយកដ្ឋានពន្ធគយ និងរដ្ឋាករ របស់ក្រសួងសេដ្ឋកិច្ចកម្ពុជា(អគរ)។ តាមតារាងទី ៩ និងទី ១០ បានបង្ហាញថា អត្រាពន្ធគយនៅកម្ពុជាមានកម្រិតនៅចន្លោះពី ០% ទៅ ៣៥% អាស្រ័យទៅតាមប្រភេទទំនិញដែលបាននាំចូល។

តារាងទី ៩៖ អត្រាពន្ធគយនៅកម្ពុជា (គិតជា%នៃតម្លៃទំនិញ)

ប្រភេទពន្ធ និងអាករប្រមូលដោយគយមានដូចខាងក្រោម៖

| លរ. | ប្រភេទពន្ធនិងអាករ | អត្រាពន្ធ |
|---|---|---|
| I. នាំចូល | | |
| ១ | ពន្ធគយ | ០%; ៧%; ១៥%; ៣៥% |
| ២ | អាករពិសេស | ០%; ៤,៣៥%; ៥%; ១០%; ១៥%; ២៥%; ៣០%; ៤៥%; ៥០% |
| ៣ | អាករបន្ថែម | ០,០២$/លីត្រ លើប្រេងសាំង, ០,០៤$/លីត្រ ចំពោះប្រេងម៉ាស៊ូត |
| ៤ | អាករលើតម្លៃបន្ថែម | ១០% |
| II. នាំចេញ | | |
| ១ | អាករនាំចេញ | ០%, ៥%, ១០%, ១៥%, ២០%, ៥០% |

ប្រភព៖ តារាងពន្ធគយឆ្នាំ២០១២ បោះពុម្ពលើកទី៣ ខែមករា ឆ្នាំ២០១៥

[33] ដកស្រង់ចេញពីច្បាប់ស្តីពីគយរបស់កម្ពុជា

តារាងទី ១០៖ អត្រាពន្ធនាំចូលតាមប្រភេទមុខទំនិញសំខាន់ៗមួយចំនួន

**Applicable Rate of Import Duties in Cambodia (Major Commodities)**

| Applicable Rate | Major Commodities |
|---|---|
| 0% | Pharmaceutical products (HS Code 30), Printed books (HS Code 4901), Ores, slag and ash (HS Code26), Petroleum gases and other gaseous hydrocarbons (HS Code 2711) |
| 7% | Edible fruit and nuts (HS Code 8), Animal or vegetable fats and oil and their cleavage products (HS code 15), Sugar and sugar confectionery (HS Code 17), Raw hides and skins (other than fur skins) and leather (HS Code 41), Articles of jewelry and parts thereof, of precious metal or of metal clad with precious metal (HS Code 7113), Bicycles and other cycles (including delivery tricycles), not motorized (HS Code 8712), Musical instruments (HS Code 92) |
| 15% | Alcohol (other than beer) (HS Code 22), Motorcycle (HS Code 78711), Clocks and watches and parts of thereof (HS Code 91) |
| 35% | Manufactures if straw, of esparto or of other planting materials (HS Code 46), Electro-mechanical domestic appliances (HS Code 8509), Motor cars and other motor vehicles principally designed for the transport of persons (HS Code 8703) |

Note: HS codes shown in brackets are based on the Cambodian customs tariff table 2011.

It is advisable to inquire the customs authority about the exact tariff rate applicable to the import.

Source: General Department of Customs and Excise of Cambodia

ប្រភពពី ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

### ៣.២. ពន្ធដារ

ពន្ធដារគឺជាពន្ធក្នុងស្រុក ដែលត្រូវបានគេប្រមូលពីបណ្តាសហគ្រាស អាជីវកម្ម និងបុគ្គល។ វាស្ថិតនៅក្រោមដែនសមត្ថកិច្ចរបស់អគ្គនាយកដ្ឋានពន្ធដារ របស់ក្រសួងសេដ្ឋកិច្ច។ រដ្ឋាភិបាលបានបែងចែកការប្រមូលពន្ធដារជា ២ គឺការប្រមូលពន្ធចូលថវិការដ្ឋ(ថ្នាក់ជាតិ) និងការប្រមូលពន្ធចូលថវិកាខេត្ត ក្រុង(ថ្នាក់ក្រោមជាតិ)។ ក្នុងនោះ ពន្ធដែលត្រូវបានបង់ចូលថវិការដ្ឋមានដូចខាងក្រោម៖

- ពន្ធលើប្រាក់ចំណេញ
- ពន្ធកាត់ទុក
- ពន្ធអប្បបរមា
- ពន្ធលើប្រាក់បៀវត្ស
- អាករលើតម្លៃបន្ថែម

- អាករពិសេសលើទំនិញ និងសេវាមួយចំនួន។[34]

របបពន្ធដារនៅកម្ពុជា មាន ២គឺ៖ **របបស្វ័យប្រកាស**[35] និង**របបម៉ៅការ**[36]។ យ៉ាងណាមិញ របបម៉ៅការ (ដែលសំដៅលើពន្ធរបស់សហគ្រាសធុនតូច និងមធ្យម ដែលជាទូទៅពន្ធប្រភេទនេះជាការកំណត់ពន្ធតាមការពិភាក្សាគ្នារវាងភ្នាក់ងារប្រមូលពន្ធជាមួយម្ចាស់ ឬតំណាងអាជីវកម្ម) និងពន្ធលើផ្លូវម៉ូតូត្រូវបានរដ្ឋាភិបាលលុបចោលនៅឆ្នាំ ២០១៦ ដោយសារតែពន្ធរបរម៉ៅការ ប៉ះពាល់ដល់ប្រសិទ្ធិភាពនៃការប្រមូលពន្ធននៅក្នុងស្រុក និងដើម្បីសម្រាលបន្ទុកកាតព្វកិច្ចរបស់ជនក្រីក្រ និងកសិករ។

### ៣.៣. ការរៀបចំកញ្ចប់ថវិកាជាតិ

ថវិកាជាតិ គឺជាឧបករណ៍ដែលរដ្ឋាភិបាលប្រើប្រាស់សម្រាប់អនុវត្តគោលនយោបាយសារពើពន្ធ ដែលក្នុងនោះវាមានមុខងារសំខាន់ៗ ៤គឺ៖ ដើម្បីកៀរគរធនធាន, បែងចែកធនធាន, បែងចែកយុត្តិធម៌, និងធានាស្ថេរភាពម៉ាក្រូសេដ្ឋកិច្ចជាតិ[37]។ ថវិកាជាតិនេះមានអាណត្តិក្នុងពេលមួយឆ្នាំ គឺគិតពី ថ្ងៃទី ០១ ខែមករា នៃឆ្នាំសារពើពន្ធ រហូតដល់ថ្ងៃទី ៣១ ខែធ្នូ នៃឆ្នាំសារពើពន្ធ។

ការរៀបចំថវិកាជាតិត្រូវបានគេធ្វើឡើងដោយចែកជា ៣ដំណាក់កាលគឺ៖

- ការរៀបចំផែនការយុទ្ធសាស្ត្រថវិកា (ខែមីនា ដល់ឧសភា)៖ គ្រប់ក្រសួងស្ថាប័ន រៀបចំផែនការយុទ្ធសាស្ត្រថវិកា ហើយផ្ញើទៅក្រសួងសេដ្ឋកិច្ចដើម្បីធ្វើការពិនិត្យ
- ការរៀបកញ្ចប់ថវិកា (ខែមិថុនា ដល់កញ្ញា)៖ ក្រសួងសេដ្ឋកិច្ចរៀបចំសេចក្តីព្រាង និងសារាចរណ៍ណែនាំ និងនីតិវិធីផ្សេងៗ ហើយនិងបើកការប្រជុំពិភាក្សាជាមួយក្រសួង ស្ថាប័ន ពាក់ព័ន្ធ ហើយបូកសរុបចំណូល និងចំណាយរបស់រដ្ឋ ហើយរៀបចំសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុ
- ការអនុម័តថវិកា (ខែតុលា ដល់ធ្នូ)៖ ក្រសួងសេដ្ឋកិច្ចដាក់សេចក្តីព្រាងជូនទៅគណៈរដ្ឋមន្ត្រីដើម្បីសម្រេច ហើយដាក់បន្តទៅរដ្ឋសភាដើម្បីអនុម័តជាស្ថាពរ នៅមុនថ្ងៃទី ២៥ ធ្នូ។

---

[34] ចំពោះនិយមន័យជាក់លាក់ និងទិន្នបន្ថែមសូមមើលនៅក្នុងសៀវភៅ «សេដ្ឋកិច្ចកម្ពុជា» របស់លោកបណ្ឌិត ហុង ជួន ណារ៉ុន ទំព័រ ៤០៨ ត្រង់ចំណុច **២០.៤ ការពិពណ៌នាអំពីប្រភេទពន្ធនៅកម្ពុជា**

[35] អ្នកជាប់ពន្ធស្វ័យប្រកាស ជានីតិបុគ្គលដែលបានចុះបញ្ជីពាណិជ្ជកម្មនៅកម្ពុជា និងបុគ្គលទាំងឡាយណាដែលប្រកបធុរកិច្ចដែលទទួលផលរបរប្រចាំឆ្នាំចាប់ពី ៥០០លានរៀល ឡើងទៅសម្រាប់ការផ្គត់ផ្គង់ទំនិញ ចាប់ពី ២៥០លានរៀលឡើងទៅសម្រាប់ការផ្គត់ផ្គង់សេវាកម្ម និងចាប់ពី ១២៥លានរៀលឡើងទៅសម្រាប់ការធ្វើកិច្ចសន្យាជាមួយរដ្ឋ

[36] អ្នកជាប់ពន្ធម៉ៅការ ជាអ្នកជាប់ពន្ធតូចៗ ដែលស្ថិតក្រោមកម្រិតអប្បបរមា ដែលត្រូវចុះបញ្ជីជាអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស និងត្រូវបានកំណត់ឲ្យបង់ប្រាក់ពន្ធជាស្ថេរវន្ត ក្នុងរយៈពេលកំណត់ណាមួយ (៣ខែ ឬ ៦ខែ)នៃឆ្នាំប្រតិទិន

[37] ដកស្រង់ចេញពីសៀវភៅ «សេដ្ឋកិច្ចកម្ពុជា» មាគ៌ាឆ្ពោះទៅរកអនាគតដ៏ភ្លឺស្វាង វឌ្ឍនភាព បញ្ហាប្រឈម និង ទស្សនវិស័យទៅអនាគត របស់លោកបណ្ឌិត ហង់ ជួន ណារ៉ុន ឆ្នាំ២០១៥ ទំព័រ ៤២១

ការអនុម័តថវិកាជាតិ រដ្ឋាភិបាលក៏បានដាក់ស្នើថវិកាមួយចំនួនសម្រាប់ជាប្រាក់ឧបត្ថម្ភដល់រដ្ឋបាលថ្នាក់ក្រោមជាតិនៅតាមរាជធានី-ខេត្ត, ក្រុង-ស្រុក និងមូលនិធិឃុំ-សង្កាត់ផងដែរ (ចំណាយ F) បើទោះបីជាមានការចាត់ចែងលៃនូវចំណូលមួយផ្នែកទៅឲ្យរដ្ឋបាលថ្នាក់ក្រោមជាតិហើយក្តី។ ជាតួរលេខគ្រួសៗ ថវិកានេះមានប្រមាណជា ៥១៣ ២៨៣ លានរៀល (ឆ្នាំ២០១៦), ៦៣៨ ១៨៦ លានរៀល(ឆ្នាំ២០១៧) និង ៧៣៧ ៨៧០ លានរៀល(ឆ្នាំ២០១៨)[38]។

## ៤. ការធ្វើកំណែទម្រង់គោលនយោបាយសារពើពន្ធ

### ៤.១. វិសោធនកម្មលើច្បាប់ស្តីពីសារពើពន្ធ

នៅឆ្នាំ ២០០៣ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានធ្វើវិសោធនកម្មលើច្បាប់ស្តីពីសារពើពន្ធឆ្នាំ ១៩៩៧ ទៅលើបទបញ្ញត្តិពាក់ព័ន្ធនឹងការវិនិយោគមួយចំនួនដូចខាងក្រោម៖

- ការធ្វើវិសោធនកម្មលើរយៈពេលលោកលែងពន្ធ ចំពោះគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដែលទទួលការលើកលែងពន្ធ
- ការដាក់ឲ្យអនុវត្តនូវអត្រារំលស់ពិសេសចំនួន ៤០% ចំពោះគម្រោងវិនិយោគណាដែលមិនចង់អនុវត្តនូវរយៈពេលលើកលែងពន្ធលើប្រាក់ចំនេញ
- ការកែប្រែនូវប្រព័ន្ធរំលស់ដោយអនុវត្តនូវវិធីសាស្ត្ររំលស់ស្មើភាគ (Straight line method) ចំពោះអាគារ និងវិធីសាស្ត្ររំលស់ថយចុះជាលំដាប់ (Declining balance method) ចំពោះទ្រព្យសកម្មផ្សេងទៀត
- ការដាក់ឲ្យអនុវត្តនូវប្រព័ន្ធពន្ធកាត់ទុកលើប្រាក់ចំណេញបន្ថែមលើការបែងចែកភាគលាភ
- ការកាត់បន្ថយនូវអត្រាពន្ធកាត់ទុកលើអនិវាសនជន
- ការកាត់បន្ថយនូវអត្រាកាត់ទុកលើនិវាសនជន ដែលអត្រាត្រូវបានកាត់បន្ថយពី ១៥% មកនៅត្រឹម ៦% ចំពោះការប្រាក់ដែលធនាគារ ឬស្ថាប័នសញ្ជ័យធនក្នុងស្រុកបង់ឲ្យទៅអ្នកជាប់ពន្ធ និវាសនជន ដែលមានគណនីបញ្ញើមានកាលកំណត់ និងកាត់បន្ថយពី ៥% មកនៅត្រឹម ៤% ចំពោះការប្រាក់ដែលធនាគារ ឬស្ថាប័នសញ្ជ័យធនក្នុងស្រុកបង់ឲ្យទៅអ្នកជាប់ពន្ធនិវាសនជនដែលមានគណនីសន្សំគ្មានកាលកំណត់
- បង្កើនអត្រាពន្ធលើប្រាក់បៀវត្សរ៍សម្រាប់អនិវាសនជនពី ១៥% ដល់ ២០១%

[38] ដកស្រង់ចេញពីរបាយការណ៍ ថវិកាសង្ខេប របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុកម្ពុជា ឆ្នាំ២០១៦ ដល់ ២០១៨

- ការឈប់អនុវត្តពន្ធអប្បបរមា និងលើកលែងពីការបង់ប្រាក់រំដោះពន្ធលើប្រាក់ចំណេញប្រចាំខែតាមអត្រា ១% នៃផលរបរចំពោះគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដែលស្ថិតក្នុងរយៈពេលលើកលែងបាន
- ការកែលម្អនូវវិធានមួយចំនួនដើម្បីពង្រឹងការប្រមូលពន្ធ។

យ៉ាងណាមិញបើយើងមើលទៅលើទិន្នន័យនៃការប្រមូលពន្ធដោយអគ្គនាយកដ្ឋានពន្ធដារក្នុងចន្លោះឆ្នាំ ១៩៩៨ ដល់ ២០០៨ យើងឃើញថាមានការកើនឡើងដល់ទៅ ១១ដង គឺ ពី ១៥១.៨ ពាន់លានរៀល(ឆ្នាំ១៩៩៨) ដល់ទៅ ១ ៧៣៥ ពាន់លានរៀល(ឆ្នាំ២០០៨)។

តារាងទី ១១៖ ចំណូលពន្ធប្រមូលដោយអគ្គនាយកដ្ឋានពន្ធដារ (គិតជាពាន់លានរៀល)

*តារាង ២០.១. ចំណូលពន្ធប្រមូលដោះអគ្គនាយកដ្ឋានពន្ធដារ (ពាន់លានរៀល)*

| ឆ្នាំ | ១៩៩៨ | ១៩៩៩ | ២០០០ | ២០០១ | ២០០២ | ២០០៣ | ២០០៤ | ២០០៥ | ២០០៦ | ២០០៧ | ២០០៨ |
|---|---|---|---|---|---|---|---|---|---|---|---|
| ប្រាក់ចំណូលពន្ធ | ១៥១.៨ | ១៨៥.១ | ២៧០.៩ | ២៩២.៩ | ៣១៨.៨ | ៣៨៤.៣ | ៤៨១.១ | ៦៣៤.៣ | ៨៨៥៦ | ១,២៥៩ | ១,៧៣៥ |

*ប្រភព ៖ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ*

## ៤.២. ការទម្លាក់អត្រាពន្ធនាំចូល

ពន្ធនាំចូលរបស់កម្ពុជាត្រូវបានទម្លាក់ជាបន្តបន្ទាប់ដោយផ្អែកលើកិច្ចព្រមព្រៀងសមាហរកម្ម និងប្រព័ន្ធអនុគ្រោះពន្ធដែលកម្ពុជាបានចុះហត្ថលេខាយល់ព្រម។ ក្នុងនោះយើងឃើញមានកិច្ចព្រមព្រៀងចំនួន ៧នៅក្នុងបញ្ជីប្រព័ន្ធអនុគ្រោះពន្ធរបស់ អគរ ដែលមាន ប្រព័ន្ធអនុគ្រោះពាណិជ្ជកម្មទំនិញអាស៊ាន(ATIGA), កិច្ចសហប្រត្តិបត្តិការ សេដ្ឋកិច្ចទូលំទូលាយរវាងអាស៊ាន និងសាធារណរដ្ឋប្រជាមានិតចិន(ACFTA), កិច្ចសហប្រត្តិការសេដ្ឋកិច្ចទូលំទូលាយ រវាងអាស៊ាន និងសាធារណរដ្ឋកូរ៉េ(AKFTA), ភាពជាដៃគូសេដ្ឋកិច្ចទូលំទូលាយរវាង ប្រទេសជាសមាជិកអាស៊ាននិងប្រទេសជប៉ុន(AJCEP), តំបន់ពាណិជ្ជកម្មសេរីអាស៊ាន–អូស្រ្តាលី–ណូវ៉ែលហ្សេឡង់(AANZFTA), តំបន់ពាណិជ្ជកម្មសេរីរវាង ប្រទេសសមាជិកអាស៊ាន និងប្រទេសឥណ្ឌា(AIFTA), និង ភាពជាដៃគូសេដ្ឋកិច្ចគ្រប់ ទូលំទូលាយតំបន់(RCEP)។ ក្នុងចំនោះកិច្ចព្រមព្រៀងទាំង ៧នេះ ចំពោះ ATIGA កម្ពុជាបានលុបពន្ធនាំចូលលើគ្រប់ផលិតផលទាំងអស់ត្រឹមឆ្នាំ២០១៥ ជាបន្តបន្ទាប់ដោយមានភាពទន់ភ្លន់ដល់ឆ្នាំ២០១៨ តាមរយៈកម្មវិធីដូចខាងក្រោម ៖

- ៨០%នៃបន្ទាត់ពន្ធគយសរុបត្រូវបញ្ចុះមកនៅត្រឹម ០-៥% ត្រឹមថ្ងៃទី០១ ខែមករា ឆ្នាំ២០០៩
- ពន្ធនាំចូលលើផលិតផល Information and Communication Technology-ICT ត្រូវបញ្ចុះមក ០%ចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១០
- ពន្ធនាំចូលលើផលិតផលកសិកម្មមិនទាន់កែច្នៃ នៅក្នុងបញ្ជីរវេទយិត SLត្រូវកាត់បន្ថយ ឬលុបមក ០-៥% នៅឆ្នាំ២០១៧។
- ពន្ធនាំចូលលើផលិតផលកសិកម្មមិនទាន់កែច្នៃនៅក្នុងបញ្ជីរវេទយិតខ្ពស់ HSLត្រូវអនុវត្តតាមអត្រា MFN ជាធរមាន។
- ពន្ធនាំចូលលើផ្នែកសមាហរណកម្មអាទិភាព Priority Integration Sector-PIS ត្រូវលុបមក ០%នៅឆ្នាំ២០១២
- ពន្ធនាំចូលលើផ្នែកសមាហរណកម្មអាទិភាព Priority Integration Sector-PIS Negative List PIS-NL ត្រូវលុបមក០%នៅឆ្នាំ២០១៥។
- ព្រះរាជាណាចក្រកម្ពុជាអាចរក្សាទុកអត្រាពន្ធ ៥% ចំនួន ៧% នៃបន្ទាត់ពន្ធគយសរុប ឬ ស្មើនឹង ៦៦២ បន្ទាត់ពន្ធរហូតដល់ឆ្នាំ២០១៨។[39]

## ៤.៣. ទំនាក់ទំនងយ៉ាងស្អិតរមួតជាមួយនឹងកម្មវិធីជាតិនានា

កំណែទម្រង់គោលនយោបាយសារពើពន្ធរបស់ប្រទេសកម្ពុជា បានដើរទន្ទឹមគ្នាយ៉ាងជិតស្និទ្ធិជាមួយនឹងកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញសាធារណៈ[40] និងកំណែទម្រង់រដ្ឋបាលសាធារណៈ។ នៅចុងឆ្នាំ ២០០៤ រាជរដ្ឋាភិបាលកម្ពុជាបានអនុម័តដាក់ឲ្យប្រើប្រាស់នូវកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលជាកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដែលជាកម្មវិធីកំណែទម្រង់លម្អិតច្រើនឆ្នាំ និងជាកម្មវិធីជំនួយគោលនយោបាយសារពើពន្ធជារួមដើម្បីសម្រេចទិសដៅគោលនយោបាយសារពើពន្ធក្នុងរយៈពេលមធ្យម និងរយៈពេលវែងដូចដែលបានរៀបរាប់ក្នុងជំពូកទី ១។

[39] ដកស្រង់ចេញពី គេហទំព័ររបស់ អគរ

[40] ជាគោលនយោបាយសម្ដៅលើការគ្រប់គ្រង ផ្ដល់ឲ្យ ត្រួតពិនិត្យ និងអនុវត្តនូវហិរញ្ញវត្ថុរបស់ជាតិ ដែលត្រូវបានដាក់ឲ្យប្រើប្រាស់ចាប់ពីឆ្នាំ ២០០៤

❖ បុព្វហេតុនៃកំណែទម្រង់[41]គោលនិយោបាយខាងលើមានៈ

- ដំណើរការចូលខ្លួនយ៉ាងស៊ីជម្រៅនៅក្នុងសកលភាវូបនីយកម្ម និងការប្រកួតប្រជែងទាំងក្នុងតំបន់ និងក្នុងសាកលលោក
- ការផ្លាស់ប្តូររបបនយោបាយប្រជាធិបតេយ្យ សេរីពហុបក្ស និងសេដ្ឋកិច្ចទីផ្សារសេរី
- ការកើនឡើងយ៉ាងគំហុកនៃតម្រូវសេវាសាធារណៈក្នុងសង្គម (សេវាអប់រំ, ហេដ្ឋារចនាសម្ព័ន្ធ, សុខាភិបាល, សន្តិសុខ និងសណ្តាប់ធ្នាប់សង្គម)
- បដិវត្តន៍ឧស្សាហកម្ម ការរីកចម្រើន និងការចូលរួមនៃព័ត៌មានវិទ្យា
- ភាពស្មុគស្មាញនៃការិយាល័យធិបតេយ្យ
- ដើម្បីផ្លាស់ប្តូររបៀបរបបនៃការបំពេញការងារ

❖ ដំណាក់កាលនៃកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ មាន ៤ដំណាក់កាលគឺៈ

- ដំណាក់កាលនៃភាពជឿទុកចិត្តនៃថវិកា (ឆ្នាំ២០០៤ ដល់២០០៨)
- ដំណាក់កាលនៃគណនេយ្យភាពហិរញ្ញវត្ថុ (ឆ្នាំ២០០៩ ដល់២០១៥)
- ដំណាក់កាលនៃការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ (ឆ្នាំ ២០១៦ ដល់ ២០២០)
- ដំណាក់កាលនៃគណនេយ្យភាពចំពោះសមិទ្ធកម្ម (ឆ្នាំ ២០២១ ដល់២០២៥)។

### ៤.៤. ការវិវត្តន៍នៃប្រព័ន្ធថវិកាជាតិ

ប្រព័ន្ធថវិកាជាតិមានការវិវត្តន៍ពីពេលមួយទៅពេលមួយដោយមានការរៀបចំយ៉ាងច្បាស់លាស់ពីរដ្ឋាភិបាល ជាពិសេស ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុកម្ពុជា។ ដំណើនការនៃការវិវត្តន៍នៃប្រព័ន្ធថវិកាជាតិ តាមបែប «ឆ្លងស្ទឹង ស្ទាបដុំថ្មនេះ» ត្រូវបានបែងចែកជា ៤ដំណាក់កាលគឺៈ

❖ ប្រព័ន្ធថវិកាជាតិតាមបន្ទាត់ (ឆ្នាំ១៩៩៣ ដល់២០១៦)

- ផ្អែកលើធាតុចូលក្នុងថវិកា
- បង្កើនថវិកាឆ្នាំបន្ទាប់ដោយផ្អែកលើ មូលដ្ឋានឆ្នាំចាស់
- គ្រប់គ្រងបែបលម្អិត
- ការត្រួតពិនិត្យមុនចំណាយ

[41] ដកស្រង់ចេញពីបទបង្ហាញរបស់ ឯកឧត្តម គង់ សុភី អគ្គនាយកគោលនយោបាយមុខងារសាធារណៈ និងជាប្រធានលេខាធិការដ្ឋានគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ ថ្ងៃទី ០៧ មិថុនា ឆ្នាំ២០១៨

❖ ប្រព័ន្ធថវិកាជាតិតាមកម្មវិធី (ឆ្នាំ២០០៨ ដល់២០១៤)
- មានបូកបញ្ចូលថវិកាកម្មវិធីដោយផ្នែក
- រួមបញ្ចូលនូវចង្កោមសកម្មភាពគាំទ្រ
- សូចនាករកម្មវិធី
- សាកល្បង ៨ក្រសួង

❖ ប្រព័ន្ធថវិកាជាតិតាមកម្មវិធី និងសមិទ្ធផល (ឆ្នាំ២០១៥ ដល់២០២០)
- ថវិកាកម្មវិធីពេញលេញ
- គោលនយោបាយផ្សារភ្ជាប់នឹងថវិកា
- កំណត់ពិដានកញ្ចប់ថវិកាចង្កោមសកម្មភាពគាំទ្រកម្មវិធី
- សូចនាករលទ្ធផល និងសមិទ្ធកម្ម
- ការត្រួតពិនិត្យតាមដាន(របាយការណ៍សមិទ្ធកម្ម)

❖ សមិទ្ធផល និងកម្មវិធី (ឆ្នាំ២០២០ ដល់២០២៥)
- ថវិកាផ្អែកលើព័ត៌មាននៃសមិទ្ធកម្ម
- ពិដានកញ្ចប់ថវិកា
- កិច្ចព្រមព្រៀងការអនុវត្តកម្មវិធី
- ការត្រួតពិនិត្យតាមដាន និងវាយតម្លៃសមិទ្ធកម្ម

និយាយជារួម ប្រព័ន្ធថវិកាជាតិបានវិវត្តពីការផ្តោតលើការចាយថវិកាតាមតួលេខ ទៅជាការចាយថវិកាដោយផ្អែកលើកម្មវិធី។ និយាយឲ្យស្រួលស្តាប់ ពីមុន រដ្ឋាភិបាលដែលមានក្រសួងនានាជាភ្នាក់ងារ ធ្វើការចំណាយដោយផ្អែកលើបរិមាណកញ្ចប់ថវិកាដែលបានអនុម័តឲ្យ ប៉ុន្តែក្រោយមករដ្ឋាភិបាលដែលមានក្រសួងនានាជាភ្នាក់ងារដដែលនេះ ធ្វើការចំណាយដោយផ្អែកលើកម្មវិធីដែលបានធ្វើគម្រោងស្នើសុំ ពោលគឺធ្វើគម្រោងចំណាយជាមុនទើបក្រសួងសេដ្ឋកិច្ចផ្តល់ថវិកាឲ្យដោយវិភាគទៅតាមគម្រោងកម្មវិធីដែលបានស្នើសុំ។

## ៤.៥. ការវិវត្តន៍នៃថវិកាជាតិ

ក្រោយពីមានការកែទម្រង់ហិរញ្ញវត្ថុសាធារណៈ និងរដ្ឋបាលសាធារណៈយ៉ាងស៊ីជម្រៅតាមដំណាក់កាលនីមួយៗហើយនោះ ចំណាយ និងចំណូលរដ្ឋមានការប្រែប្រួលគួរឲ្យជាទីមោទនៈ ដូចដែលបង្ហាញនៅក្នុងតារាងទី ១២។ ចំណូល និងចំណាយជាតិកើនឡើងពីមួយឆ្នាំ ទៅមួយឆ្នាំដែលបង្ហាញពីការគ្រប់គ្រង ប្រមូល និងចាយវាយរបស់រដ្ឋ។

តារាងទី ១២៖ សង្ខេបចំណូល និងចំណាយជាតិតាមច្បាប់

| ឆ្នាំ | ចំណូល/ ចំណាយ | ចំនួនទឹកប្រាក់(លានរៀល) | ភាគរយធៀបនឹងផសស (%) |
|---|---|---|---|
| ២០១៦ | ចំណូល(ច្បាប់) | ១៤ ៣៥៩ ៣៦៩ | ១៧.៥៣ |
| | ចំណាយ(ច្បាប់) | ១៨ ២៨៣ ៧១៩ | ២២.៣២ |
| | អភិវេកចរន្ត | | ២.៩៣ |
| | ឱនភាព | | -៤.៧៩ |
| ២០១៧ | ចំណូល(ច្បា់ប់) | ១៦ ៦១៧ ៤២៨ | ១៨.៦៦ |
| | ចំណាយ(ច្បាប់) | ២១ ១៥១ ៩៨៥ | ២៣.៧៦ |
| | អភិវេកចរន្ត | | ២.៩៨ |
| | ឱនភាព | | -៥.០៧ |
| ២០១៨ | ចំណូល(ច្បាប់) | ១៨ ៥៨៧ ០០៣ | ១៨.៧៥ |
| | ចំណាយ(ច្បាប់) | ២៤ ៣៧៥ ១០២ | ២៤.៥៩ |
| | អភិរកចរន្ត | | ២.៤៨ |
| | ឱនភាព | | -៥.៨៤ |

សង្ខេបពី ថវិកាសង្ខេបជាតិ ឆ្នាំ ២០១៦ និងឆ្នាំ ២០១៨

## ៥. លទ្ធផលនៃកំណែទម្រង់

### ៥.១. ឱនភាព ឬឧត្តមភាព

រដ្ឋាភិបាលកម្ពុជាបានឆ្លងកាត់នូវកំណែទម្រង់ជាច្រើនផ្នែក និងជាច្រើនដំណាក់កាលផ្សេងៗគ្នា រហូតទទួលបាននូវចំណាយ ចំណូល និងការប្រើប្រាស់ដ៏គួរឲ្យទុកចិត្តដូចពេលបច្ចុប្បន្ន។ យ៉ាងណាមិញ បើតាមតួលេខដែលទទួលបានពីក្រុមធនាគារពិភពលោក(ក្រាហ្វិកទី ៧) បានបង្ហាញថា ការប្រមូល និងការប្រើប្រាស់ថវិកាជាតិរបស់រដ្ឋាភិបាលកម្ពុជាមានការកើនឡើងនូវប្រសិទ្ធិភាពជាងពេលមុនៗ បើទោះបីជានៅមានឱនភាពក្នុងអត្រាក្រោម ២% (ធៀបនឹងផសសកម្ពុជា ហើយរាប់បញ្ចូលជំនួយបរទេសទៅក្នុងថវិកាជាតិ) ក៏ដោយក្តី ព្រោះឱនភាពនៃការប្រើប្រាស់ថវិការដ្ឋាភិបាលបានថយចុះជាបន្តបន្ទាប់។

ក្រាហ្វិក ទី ៧៖ ឱនភាពសារពើពន្ធកម្ពុជា ឆ្នាំ២០០៨ ដល់ ២០១៦ (គិតជា%នៃ GDP)

**Figure 34: Sustained strong collection has resulted in a reduction in fiscal deficits.** (Percent of GDP)




Source: the Cambodian authorities and World Bank staff estimates

ប្រភពពី ធនាគារពិភពលោក

### ៥.២. ចីរភាពថវិកាជាតិ និងកម្មវិធីបរទេស

ជាមួយនឹងលក្ខខណ្ឌសន្តិភាព និងស្ថេរភាពនយោបាយ និងការអភិវឌ្ឍន៍សេដ្ឋកិច្ចដូចក្នុងពេលបច្ចុប្បន្ននេះ រាជរដ្ឋាភិបាលកម្ពុជាមានសុទិដ្ឋិនិយមយ៉ាងខ្លាំងទៅលើការគ្រប់គ្រង់នូវចំណូល និងចំណាយរបស់រដ្ឋនៅក្នុងរយៈពេលនៃកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈដំណាក់កាលទី ៣ និងទី ៤នេះ។

កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ជាកំណែទម្រង់ដ៏ប្រពៃ និងសំខាន់មួយដែលបានជួយជម្រុញឲ្យមានការគ្រប់គ្រង និងប្រើប្រាស់នូវថវិការដ្ឋ ពោលគឺជម្រុញប្រសិទ្ធភាពនៃគោលនយោបាយសារពើពន្ធ។ ដើម្បីកំណត់នូវចីរភាពនៃថវិកា រដ្ឋាភិបាលនៅតែប្តេជ្ញាយ៉ាងមុតមាំធ្វើការកែទម្រង់ប្រព័ន្ធរបស់ខ្លួនជាដំណាក់ៗ។ ជាមួយគ្នានេះដែរ ដើម្បីឆ្លើយតបនឹងការកើនឡើងយ៉ាងគំហុកនូវសេចក្តីត្រូវការនៃឥណទានហិរញ្ញវត្ថុ និងការរីកធំធាត់ទំហំនៃការចំណាយរដ្ឋនេះ ក៏ដូចជា

ទប់ស្កាត់កុំឲ្យមានការកើតឡើងនូវបញ្ហាចំណាយរដ្ឋច្រើនលើសលុប ក្រសួងសេដ្ឋកិច្ចបានកំណត់នូវពិដាននៃការកម្ចីបរទេសនៅត្រឹម ១ ប៊ីលាន អេសអេអែរ នៅឆ្នាំ២០១៨។

ម៉្យាងវិញទៀត តាមការអះអាងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ការកើនឡើងនូវប្រាក់កម្ចីបរទេសរបស់កម្ពុជា នឹងមិនបង្កើតបន្ទុកវណ្ណករដល់កម្ពុជានោះទេ ព្រោះដោយសារតែនៅពេលដែលសេដ្ឋកិច្ចរីកចម្រើន នោះកម្ពុជានឹងមានលទ្ធភាពក្នុងការសងបំណុលច្រើនជាងមុន។ ហើយម៉្យាងវិញទៀត កម្ពុជាបានខ្ចីលុយបរទេស ដោយផ្អែកលើគោលការណ៍សំខាន់ៗ ៤គឺះ

- កម្ចីក្នុងទំហំសមស្របនៃតម្រូវការ
- កម្ចីឥណទានដែលមានកម្រិតសម្បទាន និងលក្ខខណ្ឌអនុគ្រោះ
- កម្ចីសម្រាប់តែវិស័យអាទិភាពទ្រទ្រង់ចីរភាពនៃកំណើន និងវិស័យផលិតភាពសេដ្ឋកិច្ច
- ការប្រើប្រាស់កម្ចីប្រកបដោយតម្លាភាព គណនេយ្យភាព ប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាពខ្ពស់។

គួរបញ្ជាក់ផងដែរថា ក្នុងឆ្នាំ ២០១៨នេះ រដ្ឋាភិបាលកម្ពុជាបានចំណាយថវិកាជាតិដែលអនុម័តប្រមាណ ៧៣៧ ៣៩៣ លានរៀល កើនឡើងបើធៀបនឹងឆ្នាំ ២០១៧ (៦៦៥ ៥១៤ លានរៀល) ដើម្បីទូទាត់កម្ចីបរទេសផងដែរ។ តែយើងក៏មិនអាចមិនអាចធ្វើមិនដឹងមិនលឺ ពីចំនួនបំណុលសាធារណៈ ឬ បំណុលដែលកម្ពុជាជាខ្ចីបរទេស និងដែលអាចប៉ះពាល់ដល់ថវិកាជាតិនោះទេ។ តាមទិន្នន័យក្នុងតារាងទី ១៦ យើងឃើញថាកម្ចីបរទេសដែលកម្ពុជាបានខ្ចីនោះមានប្រមាណ ៦ ២៣៣.២ លានដុល្លាអាមេរិក ដែលក្នុងនោះ មានបំណុលចាស់ប្រមាណ ៩.៩% នៃកម្ចីសរុប។ កម្ពុជាជំពាក់បំណុលចិត្តច្រើនជាងគេនៅក្នុងនេះ ដែលមានប្រមាណ ៤៧.៥% នៃកម្ចីសរុប។ រឿងមួយដែលសាធារណៈជននាំគ្នាមានការព្រួយបារម្ភ ហើយយើងមិនអាចរលងនោះគឺហានិភ័យនៃបំណុលសាធារណៈ[42] នេះហើយ។ យ៉ាងណាមិញបើតាមការ សំយោគនូវការអះអាងរបស់ធនាគារពិភពលោក និងបិរមាណបំណុលសាធារណៈនោះ បញ្ហាបំណុលរបស់ប្រទេសកម្ពុជាមិនទាន់ឈានដល់កម្រិត ប្រកាសអាសន្ននៅឡើយទេ ព្រោះបំណុលសាធារណៈកម្ពុជា (ក្រាហ្វិកទី ៨) ស្ថិតនៅក្នុងចន្លោះ ៣០% ទៅ ៤០%នៃផសសប្រទេស[43]។

---

[42] បំណុលសាធារណៈនេះបានចោទជាបញ្ហាសេដ្ឋកិច្ច នយោបាយ និងសង្គមយ៉ាងខ្លាំងទៅលើប្រទេសមួយចំនួនដូចជាប្រទេសហ្ក្រិក អ៊ីតាលី និងអេស្ប៉ាញជាដើម

[43] ធនាគារពិភពលោកបានអះអាងថា បំណុលសាធារណៈរបស់ប្រទេសមួយស្ថិតនៅក្នុងហានិភ័យនៅពេលដែលបំណុលនោះមានទំហំ ស្មើនឹង ៧០%នៃ ផសសប្រទេស ដោយឡែកកម្ពុជាមាន ផសស ប្រមាណ ២០ ពាន់លានដុល្លាអាមេរិក នៅឆ្នាំ២០១៦

ក្រាហ្វិកទី ៨៖ ស្ថិតិចំនួនទឹកប្រាក់បំណុលបរទេសរបស់កម្ពុជា (គិតជាលានដុល្លាអាមេរិក)




ប្រភពពី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ក្រាហ្វិកទី ៩៖ ស្ថិតិបំណុលសាធារណៈកម្ពុជាធៀបនឹងផសស(គិតជា %)




ប្រភពពី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## ៦. បញ្ហាប្រឈម និងហានិភ័យនៃសេដ្ឋកិច្ចកម្ពុជា

ទោះបីជាសេដ្ឋកិច្ចប្រទេសកម្ពុជាសម្រេចបានកំណើនក្នុងរង្វង់ ៧% ក្នុងរយៈពេលខ្លី និងមធ្យមក៏ដោយក្តី ក៏សេដ្ឋកិច្ចរបស់ប្រទេសនេះនៅជួបបញ្ហាប្រឈមដែលគួរឲ្យកត់សម្គាល់ ដែលមានដូចជា៖

- ❖ កត្តាខាងក្នុង
  - ការកើនឡើងនូវតម្រូវការនៃចំណាយរដ្ឋ ជាពិសេស ការចំណាយជាបន្ទុកទៅលើមន្ត្រី
  - និន្នាការនៃការកើនឡើងថ្លៃប្រេង និងថ្លៃម្ហូបអាហារ
  - ថ្លៃអគ្គិសនីខ្ពស់, ប្រព័ន្ធដឹកជញ្ជូននៅខ្សោយ, និន្នាការនៃកំណើនប្រាក់ឈ្នួលអប្បបរមា និងបែបបទនីតិវិធីស្មុគស្មាញ
- ❖ កត្តាខាងក្រៅ
  - កំណើនយឺតនៃប្រទេសអភិវឌ្ឍន៍
  - ការចាកចេញរបស់ចក្រភពអង់គ្លេសពីសហភាពអឺរ៉ុប និងភាពស្រពិចស្រពិលនៃអនាគតសហភាពអឺរ៉ុប
  - ការរឹតបណ្តឹងគោលនយោបាយរូបិយវត្ថុ និងភាពមិនប្រកដប្រជានៃគោលនយោបាយពាណិជ្ជកម្មសហរដ្ឋអាមេរិក
  - ការថមថយកំណើនសេដ្ឋកិច្ចរបស់ប្រទេសចិន
  - បញ្ហាភូមិសាស្ត្រនយោបាយ និងភូមិសាស្ត្រសេដ្ឋកិច្ចរបស់ពិភពលោក។[44]

[44] ដកស្រង់ចេញពីរបាយការណ៍ «ថវិកាសង្ខេប ឆ្នាំ២០១៨» របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុកម្ពុជា

# ជំពូកទី៤

# ជំពូកពិភាក្សា

ដូចដែលបានរៀបរាប់នៅក្នុងជំពូកទី ១ ការសិក្សាស្រាវជ្រាវនេះ នឹងត្រូវបានពិភាក្សាតាមដោយប្រើប្រាស់ម៉ូឌែល ផសស តាមចំណាយ $GDP = C + G + I + (X - M)$ ដោយធៀបទៅនឹងពន្ធនាំចូល ព្រោះពន្ធនាំចូលជាឥទ្ធិពលដែលសមាហរណកម្មមានទៅលើប្រទេសនានាជាចម្បង។

## ១. ការពិភាក្សានៅលើចំណាយ C

ចំណាយ C ជាការចំណាយរបស់គ្រួសារ ឬបុគ្គលនៅក្នុងសេដ្ឋកិច្ចទៅលើទំហំទំនិញ ឬសេវាកម្មក្នុងស្រុកផ្សេងៗដែលមាននៅក្នុងសេដ្ឋកិច្ច។ ដូចដែលយើងដឹងហើយថា ស្ទើរគ្រប់ទំនិញ ឬសេវាកម្មទាំងអស់ ត្រូវបានដាក់បន្ទុកពន្ធប្រមូលចូលរដ្ឋ ជាពិសេសគឺទំនិញនាំចូល។ ដោយសារមានឥទ្ធិពលពីសមាហរណកម្ម(ដូចការបង្ហាញនៅក្នុងចំណុច ៤.២ ក្នុងជំពូកទី ៣) ការទម្លាក់ពន្ធនាំចូល បានធ្វើឲ្យថ្លៃធ្លាក់ថ្លៃបើប្រៀបធៀបនឹងមុនពេលធ្វើសមាហរណកម្ម។ ការធ្លាក់ចុះនៃថ្លៃទំនិញនេះ នឹងធ្វើឲ្យគ្រួសារមានទំនោរក្នុងការចំណាយបន្ថែម ដែលធ្វើឲ្យ ចំណាយ C កើនឡើង។

$$\text{សមាហរណកម្មសេដ្ឋកិច្ច} => T_{\nabla} => C^{\Delta}$$

## ២. ការពិភាក្សានៅលើចំណាយ G

ចំណាយ G ជាចំណាយរបស់រដ្ឋទៅលើទំនិញ ឬសេវាកម្មដើម្បីបម្រើសេវាសាធារណៈជូនប្រជាពលរដ្ឋ។ ក្នុងករណីប្រទេសកម្ពុជា សមាហរណកម្មជាបុព្វហេតុមួយដែលធ្វើឲ្យមានកំណែទម្រង់រដ្ឋបាល និងកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ។ កំណែទម្រង់ទាំង ២នេះ ជាកំណែទម្រង់ដែលមានភាពជិតស្និទ្ធិនឹងកំណែទម្រង់សារពើពន្ធ។ វាមានឥទ្ធិពលលើប្រព័ន្ធគណនីយភាព ឬចំណូលចំណាយរបស់រដ្ឋ ដូចដែលក្នុងតារាងទី ១២ បានបង្ហាញ ពីការកើនឡើងនៃចំណាយរបស់រដ្ឋជាបន្តបន្ទាប់។

$$\text{សមាហរណកម្មសេដ្ឋកិច្ច} => \text{កំណែទម្រង់សារពើពន្ធ} => G^{\Delta}$$

## ៣.ការពិភាក្សានៅលើចំណាយ I

ចំណាយ I ជាចំណាយរបស់គ្រួសារ ក្រុមហ៊ុន ឬសមាគ្រាសដើម្បីជាប្រយោជន៍ដល់ការវិនិយោគ ឬការរកស៊ីរបស់ខ្លួន។ ចំណាយ I អាចជាចំណាយរបស់ក្រុមហ៊ុនក្នុងស្រុក ហើយក៏អាចជាចំណាយរបស់ក្រុមហ៊ុនក្រៅស្រុកចាក់ចូលមកក្នុងសេដ្ឋកិច្ចជាតិ ដែលគេស្គាល់ថាជាវិនិយោគផ្ទាល់ពីបរទេសផងដែរ។ តាមរយៈសមាហរណកម្មសេដ្ឋកិច្ច ប្រទេសកំពុងអភិវឌ្ឍន៍ដូចប្រទេសកម្ពុជានឹងអាចក្លាយជាកូនក្រមុំដែលមានអ្នកវិនិយោគទុនតាមចែចូវច្រើនដើម្បីមករកស៊ីនៅក្នុងស្រុក។

វាបានប្រែក្លាយឲ្យប្រទេសកំពុងអភិវឌ្ឍន៍ក្លាយជាប្រទេសដែលមានសក្តានុពល ជាពិសេសលើផលិតកម្ម និងការនាំចេញ ដោយសារតែតម្លៃថោកនៃកត្តាផលិតកម្ម(ពលកម្ម) និងអត្រាអនុគ្រោះពន្ធ។

តាមទិន្នន័យនៅក្នុងតារាងទី ១៣ វិនិយោគផ្ទាល់ពីបរទេសត្រូវបានគេប៉ាន់ប្រមាណថាមានចំនួន ២ ៥៣៨ លានដុល្លាអាមេរិក ហើយ មានចំនួនប្រមាណ ២ ៩៥៩ លានដុល្លាអាមេរិក នៅក្នុងឆ្នាំ ២០១៨(ការព្យាករណ៍) ដែលបង្ហាញពីការកើនឡើងជាវិជ្ជមាននៅក្នុង ផសស។ ដូច្នេះ យើងអាចសន្និដ្ឋានបានថា៖

$$\text{សមាហរណកម្មសេដ្ឋកិច្ច} \Rightarrow I^{\Delta}$$

តារាងទី ១៣៖ ការប៉ាន់ស្មានទំហំពាណិជ្ជកម្ម និងការវិនិយោគរបស់កម្ពុជា

**តារាងទី២÷ តារាងប៉ាន់ស្មានទំហំពាណិជ្ជកម្ម និងវិនិយោគផ្ទាល់ពីបរទេស**

| | ២០១៧ ប៉ាន់ស្មាន | ២០១៨ ព្យាករណ៍ | ២០១៩ ព្យាករណ៍ |
|---|---|---|---|
| ការនាំចេញ (លានដុល្លារអាមេរិក) | ១០.៨៤៩ | ១២.១២៣ | ១៣.៧២៤ |
| ការនាំចូល (លានដុល្លារអាមេរិក) | ១៤.២២១ | ១៥.៩១៣ | ១៧.៩៣៨ |
| ឱនភាពសមតុល្យពាណិជ្ជកម្ម | ៣.៣៧១ | ៣.៧៩០ | ៤.២១៤ |
| ការនាំចេញ (កំណើនប្រចាំឆ្នាំ) | ១៧,៥% | ១១,៧% | ១៣,២% |
| ការនាំចូល (កំណើនប្រចាំឆ្នាំ) | ១២,៤% | ១១,៩% | ១២,៧% |
| វិនិយោគផ្ទាល់ពីបរទេស (លានដុល្លារអាមេរិក) | ២.៥៣៨ | ២.៩៥៩ | ៣.៥០៥ |
| វិនិយោគផ្ទាល់ពីបរទេស (កំណើនប្រចាំឆ្នាំ) | ១៧,២% | ១៦,៦% | ១៨,៥% |

ប្រភព៖ ការប៉ាន់ស្មាននិងព្យាកររបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ខែកុម្ភៈ ឆ្នាំ២០១៨

## ៤. **ការពិភាក្សានៅលើចំណាយ** (X-M)

X ជាទំហំនៃការនាំចេញទំនិញ ឬសេវាកម្មទៅក្រៅប្រទេស រីឯ M ជាទំហំនៃការនាំចូល។ សមាហរណកម្មសេដ្ឋកិច្ចបានធ្វើជម្រុញពាណិជ្ជកម្ម (ទាំងការនាំចេញ និងនាំចូល) របស់ប្រទេស និងពិភពលោក។ ករណីប្រទេសកម្ពុជា តាមការបង្ហាញរបស់តារាងទី ១៤ ការនាំចេញ និងនាំចូលរបស់ប្រទេសកម្ពុជាបានកើនឡើងពីមួយឆ្នាំ ទៅមួយឆ្នាំ បើទោះបីជាមានឱនភាពនៃជញ្ជីងពាណិជ្ជកម្ម

ក៏ដោយក្តី។ ចំពោះករណីឱនភាពនេះ ការហូរចូលនៃការវិនិយោគអាចជាឧបករណ៍មួយយ៉ាង សំខាន់ដើម្បីជួយដោះស្រាយបញ្ហានេះ ដើម្បីកាត់បន្ថយឱនភាព។

តារាងទី ១៨៖ ស្ថិតិនៃការនៃចេញ និងនាំចូល (គិតជា លានដុល្លាអាមេរិក)

| | ២០០៨ | ២០១០ | ២០១៣ | ២០១៦ |
|---|---|---|---|---|
| នាំចេញ | ៤ ៣៥៨.៥៣ | ៥ ៥៨៣.៥៥ | ៦ ៦៦៥.៩០ | ១០ ០៧៣.១៣ |
| នាំចូល | ៤ ៩១៧.០១ | ៤ ៩២៣.២៦ | ៨ ២៣១.៥៥ | ១២ ៣៧១.០១ |

សង្ខេបចេញពី ស្ថិតិពាណិជ្ជកម្មរបស់ក្រសួងពាណិជ្ជកម្ម ឆ្នាំ ២០០៨-២០១៦

សមាហរណកម្មសេដ្ឋកិច្ច $=> |X - M|^{\Delta}$

## ៥. ការសន្ទត់ជារួម

តាមរយៈពិភាក្សានៅខាងលើ សមាហរណកម្មមានឥទ្ធិពលវិជ្ជមានទៅលើគ្រប់ធាតុចូលទាំងអស់នៃ ផសស។ ធាតុចូលមួយចំនួនទទួលនូវឥទ្ធិពលដោយប្រយោលដែលមានដូចជា ចំណាយ C និងចំណាយ G ស្របពេលដែលចំណាយ I និង X-M ទទួលរងនូវឥទ្ធិពលផ្ទាល់ពីសមាហរណកម្មសេដ្ឋកិច្ច។ ឥទ្ធិពលវិជ្ជមាននេះធ្វើឲ្យមានកំណើនសេដ្ឋកិច្ច ព្រោះដូចដែលបានរៀបរាប់ពីលើរួមមកហើយថា ផសស ជាសូចនាករមួយវាស់វែងពីកំណើនសេដ្ឋកិច្ច។ រួមជាមួយនឹងការសន្ទត់នេះ ក្រាហ្វិកទី ៦ បានបង្ហាញយ៉ាងច្បាស់នូវអត្រាកំណើន ក្នុងរង្វង់ ៧% ដែលគួរជាទីមោទនៈមួយរបស់សេដ្ឋកិច្ចកម្ពុជា។

សមាហរណកម្មសេដ្ឋកិច្ច $=> GDP^{\Delta}$

# សេចក្តីសន្និដ្ឋាន និងអនុសាសន៍

## ១. សេចក្តីសន្និដ្ឋាន

តាមរយៈការសិក្សាស្រាវជ្រាវពី សមាហរណកម្មសេដ្ឋកិច្ច និងកំណែទម្រង់គោលនយោបាយម៉ាក្រូសេដ្ឋកិច្ចរបស់កម្ពុជា ក្នុងដែនកំណត់ទៅករណីសិក្សារបស់ប្រទេសកម្ពុជានេះ យើងសង្កេតឃើញថា ការធ្វើសមាហរណកម្មសេដ្ឋកិច្ចរបស់ប្រទេសនៅលើពិភពលោកកើតចេញពីបុព្វហេតុ និងឆន្ទៈនយោបាយជាមុន ហើយត្រូវឆ្លងកាត់ ៥ដំណាក់កាលគឺៈ តំបន់ពាណិជ្ជកម្មសេរី, សហភាពពន្ធគយរួម, ទីផ្សាររួម, សហភាពសេដ្ឋកិច្ច, និងសមាហរណកម្មសេដ្ឋកិច្ចទាំងស្រុង ជាបន្តបន្ទាប់ទើបអាចសម្រេចបាននូវសមាហរណកម្មសេដ្ឋកិច្ចស៊ីជម្រៅមួយ។

សមាហរណកម្មសេដ្ឋកិច្ចអាចនាំមកនៅផលវិជ្ជមាន និងផលអវិជ្ជមានដល់ប្រទេសកំពុងអភិវឌ្ឍន៍។ ដោយឡែក ក្នុងលក្ខខណ្ឌរបស់ប្រទេសកម្ពុជាឥទ្ធិពលនៃសមាហរណកម្មសេដ្ឋកិច្ចបានជះឥទ្ធិពលផ្ទាល់ និងប្រយោលមកលើគោលនយោបាយសារពើពន្ធរបស់ប្រទេសកម្ពុជា។ ឥទ្ធិពលផ្ទាល់គឺនៅលើការទម្លាក់អត្រាពន្ធនាំចូលបន្តិចម្តងៗដូចដែលបានកំណត់នៅក្នុងកិច្ចព្រមព្រៀង។ រីឯឥទ្ធិពលដោយប្រយោល គឺនៅត្រង់ថាសមាហរណកម្មសេដ្ឋកិច្ចបានធ្វើឲ្យរដ្ឋធ្វើកំណែទម្រង់ក្នុងស្រុកគឺ កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុជាតិ និងកំណែទម្រង់រដ្ឋបាល ដែលកំណែទម្រង់ទាំង ២ នេះ បានធ្វើឲ្យមានការប្រែប្រួលដល់ការគ្រប់គ្រងសារពើពន្ធជាតិគួរឲ្យកត់សម្គាល់។

ជាមួយគ្នានេះដែរតាមរយៈការសិក្សាទៅលើករណីប្រទេសកម្ពុជា យើងទទួលបានមេរៀនល្អៗជាច្រើនដែលអាចធ្វើជាគម្រូមួយសម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍ដទៃទៀត។ យើងអាចកំណត់បានថា ដើម្បីបង្កើនចំណូលរដ្ឋ រដ្ឋាភិបាលកម្ពុជាត្រូវៈ

- មានឆន្ទៈ និងការប្តេជ្ញាចិត្តខ្ពស់ពីសំណាក់អ្នកដឹកនាំ
- ធ្វើកំណែទម្រង់ផ្ទៃក្នុងរដ្ឋបាលរបស់ខ្លួន ជាជាងការតម្លើងអត្រាពន្ធនាំចូលដែលនឹងក្លាយជាបន្ទុករបស់ប្រជាពលរដ្ឋ ដើម្បីបង្កើនចំណូលរដ្ឋ
- ប្រើប្រាស់គោលនយោបាយ និងកម្មវិធីគួបផ្សំ ដូចជាកម្មវិធីកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ និងកំណែទម្រង់រដ្ឋបាល ដើម្បីជម្រុញឲ្យកំណែទម្រង់កាន់តែប្រសើរ និងមានប្រសិទ្ធិភាព
- ធ្វើការអភិវឌ្ឍន៍ និងកំណែទម្រង់ប្រទេសដោយវឌ្ឍនភាព មិនបង្ខំ និងប្រកបដោយភាពជឿជាក់ និងទស្សនៈវិស័យវែងឆ្ងាយ
- ប្រើប្រាស់យុទ្ធសាស្ត្រ «ឆ្លងស្ទឹង ស្ទាបថ្ម» ដើម្បីវាយតម្លៃលើលទ្ធផលដែលសម្រេចបានស្របពេលដែលកំពុងអភិវឌ្ឍន៍។

- ពេញចិត្តលើសមាហរណកម្ម តែក៏មិនផ្ដេកផ្ដួលអាស្រ័យទៅលើសមាហរណកម្មខ្លាំងទេ
- «កែទម្រង់រស់ មិនកែទម្រង់គឺស្លាប់» កែទម្រង់ទាំងផ្នែករដ្ឋបាល ការគ្រប់គ្រងហិរញ្ញវត្ថុ និងកែទម្រង់ទីផ្សារដើម្បីបង្កើនឯករាជ្យភាពរបស់ខ្លួននៅក្នុងវិស័យសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

មួយវិញទៀត តាមរយៈការពិភាក្សាទៅលើធាតុចូល ៤ នៃ ផសស សមាហរណកម្មសេដ្ឋកិច្ចបានជះឥទ្ធិពលវិជ្ជមានដោយផ្ទាល់ និងដោយប្រយោលស្របពេលគ្នាទៅលើសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា ដែលជាលទ្ធផលបង្កើតបានជាកំណើនសេដ្ឋកិច្ចដ៏មានទំនុកចិត្តមួយនៅក្នុងរង្វង់ ៧%។

ជាចុងក្រោយតាមរយៈការសិក្សាស្រាវជ្រាវលើប្រធានបទ «សមាហរណកម្មសេដ្ឋកិច្ច និងកំណែទម្រង់គោលនយោបាយម៉ាក្រូសេដ្ឋកិច្ចប្រទេសកំពុងអភិវឌ្ឍន៍ - ករណីសិក្សាប្រទេសកម្ពុជា» នេះ បានបង្ហាញឲ្យឃើញនូវការសិក្សាបន្តទៀតដូចជា៖ ឥទ្ធិពលរបស់កំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ, ឥទ្ធិពលរបស់វិនិយោគទុនបរទេស, កំណែទម្រង់ពន្ធគយក្នុងក្របខ័ណ្ឌអាស៊ាន, ការធ្វើពាណិជ្ជកម្មរបស់កម្ពុជាជាមួយជាមួយប្រទេសមហាអំណាច, និងផលចំណេញកម្ពុជាក្នុងគំនិតផ្ដួចផ្ដើមតំបន់ «ផ្លូវសូត្រ»ជាដើម។

## ២. អនុសាសន៍

ដើម្បីចូលរួមជាបច្ច័យក្នុងការអភិវឌ្ឍន៍ប្រទេស ការស្រាវជ្រាវនេះបានបង្ហាញជាអនុសាសន៍មួយចំនួន ដូចខាងក្រោម៖

- គួរធ្វើសមាហរណកម្មដោយប្រុងប្រយ័ត្ន និងធ្វើពិពិធកម្មវិស័យសេដ្ឋកិច្ចរបស់ខ្លួនស្របពេលដែលសេដ្ឋកិច្ចកំពុងលូតលាស់ខ្លាំង
- ពង្រឹងទីផ្សារក្នុងស្រុក និងពង្រីកសង្វាក់ផលិតកម្មក្នុងស្រុករបស់ខ្លួនដើម្បីបង្កើនឯករាជ្យភាពសេដ្ឋកិច្ចរបស់ខ្លួនជៀសវាងការពឹងផ្អែកទៅលើទីផ្សារអន្តរជាតិជ្រុល
- ត្រូវមានភាពម្ចាស់ការលើវាសនាខ្លួនឯង ប្រកបដោយទស្សនៈវិស័យវែងឆ្ងាយ ក្នុងការអភិវឌ្ឍន៍ប្រទេស កុំរំពឹងទៅលើការនាំផ្លូវរបស់ប្រទេសមេខ្យល់ណាមួយ
- គ្រប់គ្រងលើការចំណាយរបស់ខ្លួនឲ្យបានច្បាស់លាស់ ពោលគឺចំណាយឲ្យមានខ្ទង់ ចំណាយឲ្យត្រូវចំណុច និងចំណាយឲ្យត្រូវគម្រោង និងផែនការ
- រដ្ឋាភិបាលគួរបង្កើតប្រព័ន្ធអប់រំ បណ្ដុះបណ្ដាលបន្ថែម និងដាក់កម្រិតឲ្យមន្ត្រីរាជការចូលរួមជាពិសេសគឺមន្ត្រីចាស់ៗ ព្រោះកំណែទម្រង់នឹងមិនស្ថិតស្ថេរនោះទេ ប្រសិនបើមានតែកំណែទម្រង់ប្រព័ន្ធ ហើយមន្ត្រីរបស់ខ្លួនមិនផ្លាស់ប្ដូរផ្នត់គំនិតចាស់ និងមិនបំពាក់ជំនាញថ្មីនោះ

- ប្រជាពលរដ្ឋគួរមានសុទិដ្ឋិនិយម និងភាពជឿជាក់ទៅលើរដ្ឋាភិបាលរបស់ខ្លួន ហើយព្យាយាមបង្កើនចំណេះដឹង និងជំនាញរបស់ខ្លួន ដែលបន្តិចម្តងៗវានឹងធ្វើឲ្យសេដ្ឋកិច្ច និងទីផ្សារក្នុងស្រុករបស់ខ្លួនកាន់តែរឹងមាំ
- ជាចុងក្រោយ ខ្ញុំយល់ឃើញថាកម្ពុជាគួរតែគិតគូរក្នុងការចូលខ្លួនទៅក្នុងសមាហរណកម្ម និងកម្មវិធីដែលផ្តល់ផលប្រយោជន៍ឲ្យប្រទេសបន្ថែមទៀត ជាពិសេសសមាហរណកម្មក្នុងតំបន់ តួយ៉ាងដូចជា កម្មវិធី «ផ្លូវមួយ ខ្សែក្រវ៉ាត់មួយ» ឬត្រូវបានគេស្គាល់ថា «ផ្លូវសូត្រ» ព្រោះមានអ្នកសិក្សាស្រាវជ្រាវជាច្រើនបានយល់ថា កម្មវិធីដែលផ្តួចផ្តើមដោយមហាយក្សចិននេះនឹងផ្តល់ផលប្រយោជន៍ច្រើនដល់កម្ពុជា ជាពិសេសកម្ពុជាគឺជំនួយមិនកំណត់លក្ខខណ្ឌ។ យ៉ាងណាមិញ ខ្ញុំសូមមិនបរិយាយច្រើនទៅលើចំណុចនេះទេ ដើម្បីទុកសម្រាប់ការសិក្សាក្រោយៗទៀត៕

# ឯកសារយោង


Aaron Forsythe. (2012). *Fiscal Policy - Macroeconomics*. យកមកវិញពី economics.fundamentalfinance.com: http://economics.fundamentalfinance.com/fiscal-policy.php

ASEAN Secretariat. (2017). *ASEAN Economic Progress 1967-2017.*

Ayesha J. (គ្មានថ្ងៃ). *Common Characteristics of Developing Countries | Economics*. យកមកវិញពី Economicsdiscussion.net: http://www.economicsdiscussion.net/developing-economy/characteristics-developing-economy/common-characteristics-of-developing-countries-economics/29990

*Characteristics of Developing Economies*. (គ្មានថ្ងៃ). យកមកវិញពី Intelligenteconomist: https://www.intelligenteconomist.com/characteristics-of-developing-economies/

Dave. (២០១៧, មិថុនា ៥). *ភាពខុសគ្នារវាងពាក្យ Politics និង Policy*. យកមកវិញពី អាឡាដាំង: https://www.ahladang.com/archives/9831

Deepak Nayyar. (គ្មានថ្ងៃ). Macroeconomics in developing countries . ក្នុង *BNL Quarterly Review* (ទំព័រ 249).

*Developing Countries: Definition & Examples*. (គ្មានថ្ងៃ). យកមកវិញពី Study.com: https://study.com/academy/lesson/developing-countries-definition-examples.html

*Development: Who are the developing countries in the WTO?* (គ្មានថ្ងៃ). យកមកវិញពី World Trade Organization: https://www.wto.org/english/tratop_e/devel_e/d1who_e.htm

*European Union GDP Annual Growth Rate 1996-2018*. (គ្មានថ្ងៃ). យកមកវិញពី Tradingeconomics: https://tradingeconomics.com/european-union/gdp-annual-growth-rate

*Evolution of ASEAN*. (គ្មានថ្ងៃ). យកមកវិញពី Ministry of Foreign Affairs of the kingdom of Thailand: http://www.mfa.go.th/asean/en/organize/62208-Evolution-of-ASEAN.html

*GATT, Its Purpose, History, with Pros and Cons*. (គ្មានថ្ងៃ). យកមកវិញពី thebalance.com: https://www.thebalance.com/gatt-purpose-history-pros-cons-3305578

*GDP growth (annual %) Data*. (គ្មានថ្ងៃ). យកមកវិញពី The World Bank: https://data.worldbank.org/indicator/NY.GDP.MKTP.CD?end=2017&locations=KH&start=2007

*Great Depression: Causes & Effects*. (គ្មានថ្ងៃ). យកមកវិញពី History.com: https://www.history.com/topics/great-depression

*History - ASEAN*. (គ្មានថ្ងៃ). យកមកវិញពី Asean.org: http://asean.org/asean/about-asean/history/

Katarzyna Śledziewska. (គ្មានថ្ងៃ). Theory of Economic Integration.

Leslie Kramer. (2018 , January 11). *What is Fiscal Policy?* យកមកវិញពី Investopedia: https://www.investopedia.com/insights/what-is-fiscal-policy/

Leslie Kramer. (2018, January 11). *What is Fiscal Policy?* យកមកវិញពី Investopedia: https://www.investopedia.com/insights/what-is-fiscal-policy/

*Macroecnomics*. (គ្មានថ្ងៃ). យកមកវិញពី Investopedia: https://www.investopedia.com/terms/m/macroeconomics.asp

*Macroeconomics Before the Great Depression*. (គ្មានថ្ងៃ). យកមកវិញពី andrew.cmu.edu: https://www.andrew.cmu.edu/course/88-301/classical_model/classical_model.html

Madhuri Thakur. (2014, May 02). *Macroeconomics Problems Interest Rate Inflation & Unemployment*. យកមកវិញពី Educba.com: https://www.educba.com/macroeconomics-problems/

Michal FILO, Daniel MADARÁSZ, Sabrina VAN DER HEIDE. (April 3, 2011). Evolution of European Integration.

NGOV Penghuy. (2011). ASEAN Economic Integration and Cambodia's Industrial Policies.

Peter Bondarenko. (គ្មានថ្ងៃ). *Macroeconomics*. យកមកវិញពី Britannica: https://www.britannica.com/topic/macroeconomics

Peter Bondarenko. (គ្មានថ្ងៃ). *Microeconomics*. យកមកវិញពី Britannica: https://www.britannica.com/topic/microeconomics

R. H. S. Samaratunga and E. A. Weerasinghe. (2002). Economic Integration: A Review of the Concept. *Journal of Management Science 1 (1&2)*, 168-196.

Sok Siphana. (គ្មានថ្ងៃ). Cambodia enters the WTO: Lessons learned for Least Developed Countries.

Tejvan Pettinger. (2012, November 28). *Horizontal Integration Definition*. យកមកវិញពី Economicshelp.org: https://www.economicshelp.org/blog/glossary/horizontal-integration/

Tejvan Pettinger. (2015, January 24). *Vertical Integration*. យកមកវិញពី Economicshelp.org: https://www.economicshelp.org/blog/2251/uncategorized/vertical-integration/

*The history of the European Union*. (គ្មានថ្ងៃ). យកមកវិញពី Europa.eu: https://europa.eu/european-union/about-eu/history_en

The WTO and GATT: A Principled History. (គ្មានថ្ងៃ).

Thomas Oatley. (2012). *International Political Economy 5 edition.*

*Trade and Custom*. (គ្មានថ្ងៃ). យកមកវិញពី Council for the Development of Cambodia: http://www.cambodiainvestment.gov.kh/investors-information/trade-and-custom.html

*Understadning the two: Non-tariff barriers: red tape, etc*. (គ្មានថ្ងៃ). យកមកវិញពី World Trade Organization: https://www.wto.org/english/thewto_e/Whatis_e/tif_e/agrm9_e.htm

United Nations. (2014). *Country classification.* World Economic Situation and Prospects.

*What is the WTO?* (គ្មានថ្ងៃ). យកមកវិញពី wto.org: https://www.wto.org/english/thewto_e/whatis_e/whatis_e.htm

World Bank Group. (April 2017). *Cambodia Economic Update.*

World Economic Situation and Prospects 2014. (2014). *Country classification.*

WTO Members and Accession Candidates. (2013).

ក្រសួងពាណិជ្ជកម្មកម្ពុជា. (២០០៨ ដល់ ២០១៦). *ស្ថិតិពាណិជ្ជកម្ម.*

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុកម្ពុជា. (គ្មានថ្ងៃ). ក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និង គោលនយោបាយហិរញ្ញវត្ថុសាធារណៈសម្រាប់ការរៀបចំសេដក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៩.

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុកម្ពុជា. (គ្មានថ្ងៃ). *ថវិកាសង្ខេបឆ្នាំ ២០១៦.*

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុកម្ពុជា. (គ្មានថ្ងៃ). *ថវិកាសង្ខេបឆ្នាំ ២០១៨.*

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុកម្ពុជា. (គ្មានថ្ងៃ). *ថវិកាសង្ខេបឆ្នាំ២០១៧.*

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុកម្ពុជា. (គ្មានថ្ងៃ). *ថវិកាសង្ខេប ឆ្នាំ២០១៨.*
គណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈក្រសួងមុខងារសាធារណៈ. (០៧ ខែមិថុនា ឆ្នាំ២០១៨). បុព្វហេតុ សមិទ្ធផល និងទស្សនវិស័យនៃកំណែទម្រង់រដ្ឋបាលសាធារណៈ.
ទីស្តីការគណៈរដ្ឋមន្ត្រី. (ខែមេសា ឆ្នាំ២០១៦). *របាយការណ៍សង្ខេបស្តីពីសមិទ្ធផលសំខាន់ៗមួយចំនួនរបស់រដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១២-២០១៦.*
*ពន្ធ និង អាករ.* (គ្មានថ្ងៃ). យកមកវិញពី អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា: http://www.customs.gov.kh/%E1%9E%81%E1%9F%92%E1%9E%9B%E1%9E%B9%E1%9E%98%E1%9E%9F%E1%9E%B6%E1%9E%9A%E1%9E%96%E1%9E%B6%E1%9E%80%E1%9F%8B%E1%9E%96%E1%9F%90%E1%9E%93%E1%9F%92%E1%9E%92%E1%9E%85%E1%9F%92%E1%9E%94%E1%9E%B6%E1%9E%94/%E1%9E%96%E1%9E%93%E1%9F%92%E1
រាជរដ្ឋាភិបាលកម្ពុជា. (២០០៧). *ច្បាប់ស្តីពីគយ.*
សាស្ត្រាចារ្យ ឡុង ម៉ាមីឌី. (២០១៥ - ២០១៦). *ម៉ាក្រូសេដ្ឋកិច្ច.*
សេក បណ្ឌិត. (២០១៥, តុលា ២២). *រដ្ឋាភិបាលប្រកាសលុបចោលពន្ធលើរបបមៅការនិងពន្ធផ្លូវម៉ូតូចាប់ពីឆ្នាំ២០១៦.* យកមកវិញពី Radio Free Asia: https://www.rfa.org/khmer/news/social-economy/reform-tax-from-2016-10222015014558.html
ហង់ ជួន ណារ៉ុន បណ្ឌិត. (២០១៥). *សេដ្ឋកិច្ចកម្ពុជា - មាគ៌ាឆ្ពោះទៅរកអនាគតដ៏ភ្លឺស្វាង វឌ្ឍនភាព បញ្ហាប្រឈម និងទស្សនវិស័យទៅអនាគត.*
អគ្គនាយកដ្ឋានថវិកាក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុកម្ពុជា. (គ្មានថ្ងៃ). បទបង្ហាញស្តីពីប្រព័ន្ធថវិកានៅកម្ពុជា.
អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ. (០៧ ខែមិថុនា ឆ្នាំ២០១៨). កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

# ឧបសម្ព័ន្ធ

ឧបសម្ព័ន្ធទី ១៖ សូចនាករម៉ាក្រូ និងហេដ្ឋារចនាសម្ព័ន្ធរបស់ប្រទេសដែលមានចំណូលទាប

**Table 1. Selected Macro and Structural Indicators for LIDCs**

| | **LIDC average** | Fragile states | Frontier markets | Commodity exporters | EM average |
|---|---|---|---|---|---|
| Agricultural sector share (in percent of GDP), 2012 | **27.4** | 36.3 | 21.9 | 29.8 | 8.3 |
| Informality (percent employed in informal sector), 2005-10 | **51.1** | 57.6 | 57.6 | 62.7 | 35.8 |
| | | | | | |
| Electric power consumption (kWh per capita, 2011) | **517.9** | 197.2 | 500.5 | 536.8 | 3313.0 |
| Quality of overall infrastructure (score, 7=best), 2013 | **2.6** | 2.2 | 2.8 | 2.4 | 4.0 |
| Institutional quality (average rank of Fraser index, 1=highest), 2010 | **104.3** | 123.4 | 90.1 | 114.4 | 70.6 |
| | | | | | |
| Trade openness (exports plus imports, in percent of GDP), 2010 | **81.0** | 78.8 | 76.0 | 67.0 | 91.9 |
| Financial development (private credit as in percent of GDP), 2012 | **24.8** | 15.7 | 34.0 | 18.6 | 50.0 |
| | | | | | |
| Net official development assistance (in percent of GDP), 2012 | **9.3** | 12.4 | 5.8 | 8.3 | 3.6 |
| Foreign direct investment inflows (in percent of GDP), 2013 | ***2.9*** | *1.8* | *5.0* | *3.0* | *1.2* |
| Revenue (excl. grants, in percent of GDP), 2013 | **22.0** | 21.3 | 20.6 | 19.9 | 30.4 |
| Standard deviation of revenue (in percent of GDP), 2000-13 | **3.6** | 4.3 | 2.8 | 4.3 | 3.1 |
| | | | | | |
| Poverty rate (percent of population < $1.25/day), 2005-10 | **40.6** | 51.8 | 44.1 | 51.1 | 6.6 |
| Income inequality (Gini coefficient), 2005-10 | **41.5** | 42.0 | 43.8 | 41.3 | 41.4 |
| Infant mortality rate (per 1000 live births), 2010 | **52.7** | 62.6 | 44.5 | 62.2 | 18.2 |
| Average years of schooling, 2010 | **5.3** | 4.4 | 6.0 | 4.6 | 8.7 |

Sources: WEO, WDI, ILO, and IMF staff estimates.
Note: Group aggregates are calculated based on simple (un-weighted) averages. EM refers to the group of non-LIDCs that belong to the WEO category of EMDCs.

ឧបសម្ព័ន្ធទី ២៖ ចំណែកនៃការងារក្រៅផ្លូវការក្នុងសេដ្ឋកិច្ច(គិតជា % ធៀបនឹង GDP)

**Figure 31: While remaining strong, domestic collection appears to have stagnanted as a percentage of GDP.**




Source: the Cambodian authorities

## ឧបសម្ព័ន្ធទី ៣៖ តុល្យការ និងលំហូរវិនិយោគទុន

**Table 3: Balance of Trade and Net FDI Inflow of ASEAN**

| Country | | Trade | | Net FDI Inflow during 2001-2010[c], Million USD | FDI Inflows/Gross Fixed Capital Formation[d] during 2001-2010, % |
|---|---|---|---|---|---|
| | | Export/GDP 2009, % | Import/GDP 2009, % | | |
| ASEAN 6 | Brunei | 67.6[a] | 27.8[a] | 7,358 | 67.3 |
| | Indonesia | 24.1 | 21.3 | 46,372 | 3.3 |
| | Malaysia | 96.4 | 74.9 | 47,279 | 13.7 |
| | Philippines | 31.7 | 30.8 | 15,146 | 8.6 |
| | Singapore | 220.5[b] | 202.6[b] | 198,802 | 59.0 |
| | Thailand | 68.4 | 57.9 | 67,685 | 13.6 |
| CLMV | Cambodia | 59.6 | 62.7 | 4,377 | 29.6 |
| | Laos PDR | 32.7[b] | 44.4[b] | 1,501 | 15.3 |
| | Myanmar | na | na | 4,615 | 23.2 |
| | Vietnam | 68.3 | 78.6 | 42,072 | 17.1 |

Source: World Bank, World Development Indicators, Accessed June 23, 2011. UNCTAD (2011), World Investment Report. Annex Table 1 and Table 5.

Note: a. Data for 2007 (WDI); b. Data for 2008 (WDI); c. Total net FDI inflow during 2001-2010; d. Average of FDI inflows as percentage of gross fixed capital formation during 2001-2010.

## ឧបសម្ព័ន្ធទី ៤. ការធ្លាក់ចុះនៃការនាំចេញផលិតផលវាយនភណ្ឌ

**Figure 1: While remaining strong, garment exports have eased.** (US$ million)




Source: the Cambodian authorities

ឧបសម្ព័ន្ធ ៥៖ ការវិវត្តន៍នៃប្រព័ន្ធថវិកា

